

# ចំនួនកុំផ្លិច

## COMPLEX NUMBERS

ថ្នាក់ទី ១២ • GRADE 12

ទ្រឹស្តីសង្ខេប • វិធីសាស្ត្រគណនា • វិញ្ញាសាពហុជ្រើសរើស (MCQ)

ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) និងប្រឡងសិស្សពូកែ

អ្នករៀបរៀង ៖ លោកគ្រូ ខែម ពុទ្ធី

បោះពុម្ពលើកទី១ ឆ្នាំ ២០២៦

# គណៈកម្មការរៀបរៀង និងត្រួតពិនិត្យ

| | |
|---|---|
| **គណៈកម្មការរៀបរៀង** | លោកគ្រូ ខែម ពុទ្ធី |
| | លោកគ្រូ ឡាយ ចាន់ហេន |
| **ត្រួតពិនិត្យខ្លឹមសារ** | លោកគ្រូ ឡាយ ចាន់ហេន |
| **រៀបចំខ្លឹមសារ** | លោកគ្រូ ខែម ពុទ្ធី |
| **រចនាគម្រប និងទំព័រ** | លោកគ្រូ ខែម ពុទ្ធី |
| **រូបភាព និងតារាង** | លោកគ្រូ ខែម ពុទ្ធី |
| **កែសម្រួលអក្ខរាវិរុទ្ធ** | លោកគ្រូ ខែម ពុទ្ធី |
| **គណៈកម្មការពិនិត្យចុងក្រោយ** | លោកគ្រូ ខែម ពុទ្ធី |
| | លោកគ្រូ ឡាយ ចាន់ហេន |

សៀវភៅនេះត្រូវបានរៀបចំឡើងយ៉ាងសម្រិតសម្រាំង សម្រាប់សិស្សានុសិស្សថ្នាក់ទី១២ ក្នុងការស្វ័យសិក្សា និងត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) ព្រមទាំងការប្រឡងសិស្សពូកែទូទាំងប្រទេស។

**ព័ត៌មានសៀវភៅ**

កំណែសាកល្បង © ២០២៦

**ចំនួនកុំផ្លិច ថ្នាក់ទី១២**

COMPLEX NUMBERS GRADE 12

រៀបរៀងដោយ **លោកគ្រូ ខែម ពុទ្ធី**

សម្រាប់បោះពុម្ពផ្សាយ៖ **បណ្ណាគារអង្គរ**

# សេចក្តីឧទ្ទិស

សៀវភៅ «**ចំនួនកុំផ្លិច**» នេះ
សូមឧទ្ទិសជូនចំពោះ៖

ភរិយាជាទីស្រឡាញ់

**ង៉ែត សុគន្ធា**

និង

កូនស្រីជាទីស្រឡាញ់

**ខែម សោភា**

ដែលជាកម្លាំងចិត្ត និងជាប្រភពនៃសុភមង្គលដ៏កក់ក្តៅ
ក្នុងដំណើរជីវិត និងការស្រាវជ្រាវរបស់ខ្ញុំបាទជានិច្ចនិរន្តរ៍។

**លោកគ្រូ ខែម ពុទ្ធី**

# អារម្ភកថា

គណិតវិទ្យា គឺជាវិទ្យាសាស្ត្រមួយដែលមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពត្រិះរិះពិចារណា និងការដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ក្នុងចំណោមមែកធាងជាច្រើននៃគណិតវិទ្យា ការសិក្សាអំពី «**ចំនួនកុំផ្លិច**» គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់បំផុតមួយនៃគណិតវិទ្យា ដែលសិស្សានុសិស្សថ្នាក់ទី១២ ចាំបាច់ត្រូវតែស្វែងយល់ឱ្យបានច្បាស់លាស់។ ចំនួនកុំផ្លិចមិនត្រឹមតែជាស្ពានចម្លងដ៏រឹងមាំក្នុងការដោះស្រាយសមីការពិជគណិតដែលគ្មានឫសក្នុងសំណុំចំនួនពិតប៉ុណ្ណោះទេ តែថែមទាំងជាគន្លឹះក្នុងការយល់ដឹងអំពីទម្រង់ត្រីកោណមាត្រ រូបមន្តដឺម័រ ឫសទី $n$ នៃចំនួនកុំផ្លិច និងការអនុវត្តក្នុងធរណីមាត្រផងដែរ។

ដោយយល់ឃើញពីសារៈសំខាន់នេះ និងកត់សម្គាល់ឃើញពីការលំបាករបស់សិស្សានុសិស្សមួយចំនួនក្នុងការស្វែងយល់អំពីការគណនា និងដោះស្រាយលំហាត់ចំនួនកុំផ្លិច ខ្ញុំបាទបានខិតខំស្រាវជ្រាវ និងចងក្រងសៀវភៅ «**ចំនួនកុំផ្លិច**» នេះឡើង។ សៀវភៅនេះត្រូវបានរៀបចំឡើងយ៉ាងសម្រិតសម្រាំង ដោយបែងចែកជា ៥ ជំពូករួមមាន៖ **មេរៀនសង្ខេប វិធីសាស្ត្រក្នុងការគណនា លំហាត់មានដំណោះស្រាយ និងលំហាត់ប្រតិបត្តិសម្រាប់អនុវត្ត** ដើម្បីសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់សិស្សានុសិស្សឱ្យកាន់តែមានភាពងាយស្រួល និងស៊ីជម្រៅ។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងក្លាយជាឯកសារយោងដ៏មានតម្លៃសម្រាប់ការត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) និងជួយជំរុញទឹកចិត្តសិស្សានុសិស្សទាំងអស់ឱ្យកាន់តែមានភាពជឿជាក់លើសមត្ថភាពរបស់ខ្លួន។ ទោះបីជាខ្ញុំបាទបានខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏កំហុសឆ្គងដោយអចេតនាអាចនឹងកើតមាន អាស្រ័យហេតុនេះខ្ញុំបាទរង់ចាំទទួលនូវរាល់មតិរិះគន់ស្ថាបនាតាមរយៈលោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានដោយក្តីសោមនស្សរីករាយបំផុត។

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២៦

**លោកគ្រូ ខែម ពុទ្ធី**

# សេចក្តីដឹងគុណ

ជាបឋម ខ្ញុំបាទ **លោកគ្រូ ខែម ពុទ្ធី** សូមលំឱនកាយវាចាចិត្ត ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះលោកអ្នកមានគុណទាំងពីរ គឺមាតា និងបិតារបស់ខ្ញុំ ដែលលោកទាំងពីរបានពលិកម្មគ្រប់បែបយ៉ាង ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅ និងអប់រំទូន្មានប្រៀនប្រដៅខ្ញុំបាទតាំងពីកុមារភាព រហូតធ្វើឱ្យខ្ញុំអាចឈរយ៉ាងរឹងមាំនៅលើវិថីជីវិតមួយនេះ។ បើគ្មានការលះបង់ និងសេចក្តីស្រឡាញ់ដ៏មហាសាលពីលោកទាំងពីរទេ នោះខ្ញុំបាទក៏ប្រហែលជាគ្មានថ្ងៃនេះឡើយ។

ជាបន្តបន្ទាប់ ខ្ញុំបាទសូមសម្តែងនូវសេចក្តីគោរពដឹងគុណយ៉ាងស្មោះស្ម័គ្រ ជូនចំពោះលោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យគ្រប់លំដាប់ថ្នាក់ តាំងពីកម្រិតបឋមសិក្សា រហូតដល់ថ្នាក់សាកលវិទ្យាល័យ ដែលបានខិតខំចំណាយកម្លាំងកាយចិត្តក្នុងការផ្ទេរនូវចំណេះដឹង និងបណ្តុះបណ្តាលរូបខ្ញុំឱ្យក្លាយជាធនធានមនុស្សមួយរូបប្រកបដោយសមត្ថភាព។ រាល់ដំបូន្មានដែលទទួលបានពីលោកគ្រូ អ្នកគ្រូ គឺជាប្រទីបបំភ្លឺផ្លូវដែលតែងតែចង្អុលបង្ហាញឱ្យខ្ញុំបាទដើរលើកន្លងដ៏ត្រឹមត្រូវ។

ជាពិសេសលើសពីនេះទៅទៀត ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងផ្ញើជូននូវសេចក្តីស្រឡាញ់ដ៏ធំធេងមិនអាចកាត់ថ្លៃបាន ជូនចំពោះភរិយាជាទីស្រឡាញ់របស់ខ្ញុំ គឺលោកស្រី **ចែ៉ត សុគន្ធា** ព្រមទាំងកូនស្រីជាទីស្រឡាញ់ **ខែម សោភា** ដែលតែងតែនៅក្បែរ ផ្តល់ភាពកក់ក្តៅ មើលថែទាំ លើកទឹកចិត្ត និងលះបង់គ្រប់បែបយ៉ាង ដើម្បីឱ្យខ្ញុំបាទមានពេលវេលាពេញលេញក្នុងការស្រាវជ្រាវ និងចងក្រងសៀវភៅមួយក្បាលនេះឡើងរហូតទទួលបានជោគជ័យ។

សៀវភៅ «**ចំនួនកុំផ្លិច**» មួយក្បាលនេះ មិនអាចលេចចេញជារូបរាងឡើងបានឡើយ ប្រសិនបើគ្មានការលើកទឹកចិត្តពីមនុស្សជាច្រើនជុំវិញខ្លួនខ្ញុំ។ ខ្ញុំបាទសូមអរគុណដល់មិត្តភក្តិ បងប្អូន និងសហការីទាំងអស់ ដែលតែងតែផ្តល់មតិយោបល់ជួយកែសម្រួល និងជួយជំរុញទឹកចិត្តខ្ញុំនៅក្នុងដំណើរការនៃការចងក្រងសៀវភៅនេះជាភាសា LaTeX។ ជាចុងបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គល ជូនដល់លោកអ្នកមានគុណ លោកគ្រូ អ្នកគ្រូ ភរិយា កូនស្រី ព្រមទាំងមិត្តអ្នកសិក្សាទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ ប្រាជ្ញាភ្លឺថ្លា ជោគជ័យគ្រប់ភារកិច្ច និងសម្រេចបាននូវរាល់បំណងប្រាថ្នាក្នុងជីវិតជានិរន្តរ៍។

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២៦

**លោកគ្រូ ខែម ពុទ្ធី**

# និមិត្តសញ្ញាដែលប្រើក្នុងសៀវភៅនេះ

| និមិត្តសញ្ញា | អត្ថន័យ / ការកំណត់ | និមិត្តសញ្ញា | អត្ថន័យ / ការកំណត់ |
|---|---|---|---|
| **សំណុំចំនួន និងចំនួនកុំផ្លិច** | | **ធរណីមាត្រ និងប្លង់កុំផ្លិច** | |
| $\mathbb{C}$ | សំណុំចំនួនកុំផ្លិច | $(P)$ | ប្លង់កុំផ្លិច (ប្លង់អារហ្គង់ ) |
| $\mathbb{R}$ | សំណុំចំនួនពិត | $(O,\vec{u},\vec{v})$ | តម្រុយអរតូណរម៉ាល់នៃប្លង់កុំផ្លិច |
| $\mathbb{Q},\mathbb{Z},\mathbb{N}$ | សំណុំចំនួនសនិទាន, គត់, ធម្មជាតិ | $M(z)$ ឬ $M(a,b)$ | ចំណុចរូបភាពនៃ $z$ (អាភិចនៃ $M$) |
| $i$ | ឯកតានិម្មិត ($i^2=-1$) | $\vec{w}(z)$ | វ៉ិចទ័ររូបភាពនៃចំនួនកុំផ្លិច $z$ |
| $z=a+bi$ | ទម្រង់ពិជគណិត ($a,b\in\mathbb{R}$) | $z_{\vec{AB}}=z_B-z_A$ | អាភិចនៃវ៉ិចទ័រ $\vec{AB}$ |
| $\mathrm{Re}(z)$ | ផ្នែកពិតនៃ $z$ ($\mathrm{Re}(z)=a$) | $AB=\lvert z_B-z_A\rvert$ | ប្រវែងអង្កត់ $AB$ (ចម្ងាយពី $A$ ទៅ $B$) |
| $\mathrm{Im}(z)$ | ផ្នែកនិម្មិតនៃ $z$ ($\mathrm{Im}(z)=b$) | $(\vec{u},\vec{OM})$ | មុំតម្រង់ទិសស្មើ $\arg(z) \pmod{2\pi}$ |
| $\bar{z}$ ឬ $\bar{z}$ | ចំនួនកុំផ្លិចឆ្លាស់ ($\bar{z}=a-bi$) | $R_{(O,\theta)}$ | ចលនាបង្វិលផ្ចិត $O$ មុំ $\theta$ |
| $\lvert z\rvert$ | ម៉ូឌុលនៃ $z$ ($\lvert z\rvert=\sqrt{a^2+b^2}$) | $h_{(O,k)}$ | ចលនាដូចគ្នាផ្ចិត $O$ ផលធៀប $k$ |
| $\arg(z)$ | អាគុយម៉ង់នៃចំនួនកុំផ្លិច $z$ | **និមិត្តសញ្ញាគណិតវិទ្យាទូទៅ** | |
| $\mathrm{Arg}(z)$ | អាគុយម៉ង់ចម្បង ($\in(-\pi,\pi]$) | $\forall$ | ចំពោះគ្រប់ (For all) |
| **ទម្រង់ត្រីកោណមាត្រ និងស្វ័យគុណ** | | $\exists$ | មាន / មានយ៉ាងហោចណាស់មួយ |
| $r(\cos\theta+i\sin\theta)$ | ទម្រង់ត្រីកោណមាត្រ ($r=\lvert z\rvert$) | $\in,\notin$ | ជាធាតុនៃ, មិនមែនជាធាតុនៃ |
| $\mathrm{cis}\,\theta$ | សញ្ញាកាត់ $\cos\theta+i\sin\theta$ | $\subset,\subseteq$ | ជាសំណុំរងនៃ |
| $e^{i\theta}$ | រូបមន្តអយល័រ ($\cos\theta+i\sin\theta$) | $\cap,\cup$ | ប្រសព្វ, ប្រជុំ នៃសំណុំ |
| $re^{i\theta}$ | ទម្រង់អិចស្ប៉ូណង់ស្យែលនៃ $z$ | $\Longleftrightarrow$ | សមមូល / លុះត្រាតែ |
| $(\cos\theta+i\sin\theta)^n$ | រូបមន្តដឺម័រ ($\cos n\theta+i\sin n\theta$) | $\Longrightarrow$ | នាំឱ្យ / នាំមកនូវ |
| $w_k=\sqrt[n]{z}$ | ឫសទី $n$ នៃ $z$ ($k=0,\ldots,n-1$) | $\sum_{k=1}^{n}$ | ផលបូកពីតួទី 1 ដល់ $n$ |
| $\mathbb{U}_n$ | សំណុំឫសទី $n$ នៃឯកតា | $\prod_{k=1}^{n}$ | ផលគុណពីតួទី 1 ដល់ $n$ |

# មាតិកា


**មេរៀនទី ១ : ចំនួនកុំផ្លិចទម្រង់ពីជគណិត** . . . . . . . . **9**

១ សញ្ញាណនៃចំនួនកុំផ្លិច . . . . . . . . 10

២ ប្រមាណវិធីលើចំនួនកុំផ្លិច . . . . . . . . 16

៣ ចំនួនកុំផ្លិចឆ្លាស់ . . . . . . . . 17

៤ សមីការដឺក្រេទី២ មានមេគុណពិត . . . . . . . . 18

៥ ការតាងតាមបែបធរណីមាត្រនៃចំនួនកុំផ្លិច . . . . . . . . 21

៦ ចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច . . . . . . . . 21

៧ វ៉ិចទ័ររូបភាព នៃផលបូក និង ផលដកចំនួនកុំផ្លិច និង ផលគុណចំនួនពិតជាមួយនឹងចំនួនកុំផ្លិច . . . . 22

▸ វិញ្ញាសាពហុជ្រើសរើស (១០០ លំហាត់) . . . . . . . . 25

▸ លំហាត់អនុវត្តន៍បន្ថែម . . . . . . . . 34

**មេរៀនទី ២ : ចំនួនកុំផ្លិចទម្រង់ត្រីកោណមាត្រ** . . . . . . . . **55**

១ ម៉ូឌុលនៃចំនួនកុំផ្លិច . . . . . . . . 55

២ អាគុយម៉ង់នៃចំនួនកុំផ្លិច . . . . . . . . 58

៣ ទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច . . . . . . . . 60

៤ ផលគុណចំនួនកុំផ្លិចតាមទម្រង់ត្រីកោណមាត្រ . . . . . . . . 61

៥ ផលចែកចំនួនកុំផ្លិចតាមទម្រង់ត្រីកោណមាត្រ . . . . . . . . 63

៦ បំប្លែងវិលជុំវិញគល់តម្រុយនៃប្លង់កុំផ្លិច . . . . . . . . 64

▸ វិញ្ញាសាពហុជ្រើសរើស (១០០ លំហាត់) . . . . . . . . 65

▸ លំហាត់អនុវត្តន៍ . . . . . . . . 74

**មេរៀនទី ៣ : ស្វ័យគុណទី n និង ឬសទី n នៃចំនួនកុំផ្លិច** . . . . . . . . **95**

១ ស្វ័យគុណទី $n$ នៃចំនួនកុំផ្លិច . . . . . . . . 95

២ អនុវត្តន៍ចំនួនកុំផ្លិចក្នុងធរណីមាត្រត្រីកោណ . . . . . . . . 97

៣ ឬសទី $n$ នៃចំនួនកុំផ្លិច . . . . . . . . 98

▸ វិញ្ញាសាពហុជ្រើសរើស (១០០ លំហាត់) . . . . . . . . 102

▸ លំហាត់មេរៀន . . . . . . . . 111

▸ លំហាត់ជំពូកទី១ . . . . . . . . 119

▸ លំហាត់ដែលធ្លាប់ចេញ . . . . . . . . 131

**មេរៀនទី ៤ : លំហាត់ស្រាវជ្រាវ និង វិញ្ញាសាពង្រឹងសមត្ថភាព** . . . . . . . . **151**

១ វិញ្ញាសាពហុជ្រើសរើសត្រៀមប្រឡងប្រជែង . . . . . . . . 151

២ លំហាត់ស្រាវជ្រាវ និង កម្រិតខ្ពស់ . . . . . . . . 156

**មេរៀនទី ៥ : ផ្នែកចម្លើយ** . . . . . . . . **163**

១ តារាងចម្លើយពហុជ្រើសរើស (Answer Keys) . . . . . . . . 163

២ ដំណោះស្រាយលម្អិត លំហាត់អនុវត្តន៍មេរៀនទី១ . . . . . . . . 167

៣ ដំណោះស្រាយលម្អិត លំហាត់មេរៀនទី២ . . . . . . . . 172

៤ ដំណោះស្រាយលម្អិត លំហាត់មេរៀនទី៣ និងលំហាត់ជំពូក . . . . . . . . 175

៥ ដំណោះស្រាយលម្អិត លំហាត់ស្រាវជ្រាវ និង កម្រិតខ្ពស់ . . . . . . . . 178

**ឯកសារយោង** . . . . . . . . **183**



# មេរៀនទី ១
# ចំនួនកុំផ្លិចទម្រង់ពីជគណិត

## ប្រវត្តិនៃការកកើតចំនួនកុំផ្លិច

**ចំនួនកុំផ្លិច (Complex Numbers)** គឺជាប្រភេទចំនួនដែលត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាដែលចំនួនពិត (Real Numbers) មិនអាចដោះស្រាយបាន។ ការរកឃើញរបស់វាមានប្រវត្តិយូរលង់ណាស់មកហើយ ដោយចាប់ផ្តើមពីតម្រូវការដោះស្រាយសមីការគណិតវិទ្យា៖

- **សម័យគ្រិចបុរាណ៖** គណិតវិទូដឹងពីបញ្ហាដែលថាឫសការេនៃចំនួនអវិជ្ជមានមិនមានចម្លើយនៅក្នុងប្រព័ន្ធចំនួនដែលពួកគេស្គាល់ (ឧទាហរណ៍ គ្មានតម្លៃ $x$ ណាដែលបំពេញ $x^2 = -1$ ឡើយ)។

- **Gerolamo Cardano (១៥០១–១៥៧៦)៖** គណិតវិទូជនជាតិអ៊ីតាលីដែលបានរកឃើញរូបមន្តដោះស្រាយសមីការដឺក្រេទី៣ (Cubic Equations) ដូចជា $x^3 - 15x = 4$។ ក្នុងដំណើរការដោះស្រាយ គាត់បានជួបប្រទះឫសការេនៃចំនួនអវិជ្ជមាន ដែលកាលនោះហៅថា "ចំនួនមិនអាចទៅរួច" (Impossible Numbers)។

- **Rafael Bombelli (១៥២៦–១៥៧២)៖** គណិតវិទូដំបូងគេដែលបានសិក្សាស៊ីជម្រៅលើចំនួនទាំងនេះ។ គាត់បានបង្ហាញពីរបៀបប្រើឫសនៃចំនួនអវិជ្ជមានដើម្បីដោះស្រាយសមីការគូប និងបានបង្កើតក្បួនប្រមាណវិធីបូក ដក គុណ ចែក ដែលជាមូលដ្ឋានគ្រឹះនៃចំនួនកុំផ្លិច។

- **René Descartes (១៥៩៦–១៦៥០)៖** បានបង្កើតពាក្យ **"Imaginary Number"** (ចំនួននិម្មិត) សម្រាប់សម្គាល់ឫសការេនៃចំនួនអវិជ្ជមាន។

- **Leonhard Euler (១៧០៧–១៧៨៣)៖** បានធ្វើឱ្យចំនួនកុំផ្លិចមានសារៈសំខាន់បំផុត ដោយបង្កើតនិមិត្តសញ្ញា $i$ តំណាងឱ្យ $\sqrt{-1}$ (មកពីពាក្យ "Imaginary") និងរកឃើញរូបមន្តដ៏ល្បីល្បាញ $e^{i\theta} = \cos\theta + i\sin\theta$។

- **Carl Friedrich Gauss (១៧៧៧–១៨៥៥)៖** បានផ្តល់ឈ្មោះជាផ្លូវការថា **"Complex Number"** (ចំនួនកុំផ្លិច) និងបង្ហាញពីរបៀបតាងចំនួនទាំងនេះលើប្លង់ធរណីមាត្រ (ប្លង់កុំផ្លិច) ដែលធ្វើឱ្យងាយស្រួលយល់ និងមើលឃើញជាក់ស្តែង។

# ១ សញ្ញាណនៃចំនួនកុំផ្លិច

## ១.១ ឯកតានិម្មិត

**និយមន័យ ១ : ចំនួននិម្មិត**

បើ $c>0$ នោះឫសការេនៃ $-c$គឺ $\sqrt{-c}=\sqrt{(-1)c}=\sqrt{c}\cdot\sqrt{-1}=\sqrt{c}i$ ដែល $i^2=-1$។

**លំហាត់គំរូ ១**

គណនាចំនួនខាងក្រោម៖

ក. $\sqrt{-144}$   ខ. $\sqrt{-12}$   គ. $\sqrt{-169}$   ឃ. $\sqrt{-25}$

**ចម្លើយ:**

**គន្លឹះដោះស្រាយ៖** ជាទូទៅ បើយើងមានរ៉ាឌីកង់អវិជ្ជមាន $-c$ $(c>0)$ យើងអាចសរសេរវាជា $c(-1)$ រួចជំនួស $-1$ ដោយ $i^2$ ព្រោះ $i^2=-1$។ ដូច្នេះ $\sqrt{-c}=\sqrt{ci^2}=i\sqrt{c}$។

**ដំណោះស្រាយលម្អិត៖**

ក. $\sqrt{-144}=\sqrt{144\times(-1)}=\sqrt{144i^2}=12i$

ខ. $\sqrt{-12}=\sqrt{12\times(-1)}=\sqrt{12i^2}=\sqrt{4\times3}i=2i\sqrt{3}$

គ. $\sqrt{-169}=\sqrt{169\times(-1)}=\sqrt{169i^2}=13i$

ឃ. $\sqrt{-25}=\sqrt{25\times(-1)}=\sqrt{25i^2}=5i$

## ១.២ ស្វ័យទី$n$ នៃ$i$

**ជាទូទៅ ១**

ស្វ័យទី$n$ នៃ$i$ ចំពោះគ្រប់$k$ ជាចំនួនគត់វិជ្ជមានគេបាន៖

ក. $i^{4k}=1$   ខ. $i^{4k+1}=i$   គ. $i^{4k+2}=-1$   ឃ. $i^{4k+3}=-i$

## លំហាត់គំរូ ២

គណនាចំនួនខាងក្រោម៖

ក. $i^{1975}$ ខ. $i^{1979}$ គ. $i^{2019}$ ឃ. $i^{2021}$ ង. $i^{2025}$ ច. $i^{2026}$

**ចម្លើយ**:

**គន្លឹះដោះស្រាយ៖** ដើម្បីគណនាស្វ័យគុណ $i^n$ យើងត្រូវយកនិទស្សន្ត $n$ ចែកនឹង 4 ដើម្បីរកសំណល់ $r$។ ពេលនោះ $i^n = i^r$។ សំណល់ $r$ អាចជា $0,1,2,3$ ដែលត្រូវនឹងតម្លៃ $1, i, -1, -i$ តាមលំដាប់។

**ដំណោះស្រាយលម្អិត៖**

ក. យក $1975 \div 4$ បានផលចែក 493 សំណល់ 3។ ដូច្នេះ $i^{1975} = i^{4(493)+3} = (i^4)^{493} \cdot i^3 = 1 \cdot (-i) = -i$

ខ. យក $1979 \div 4$ បានផលចែក 494 សំណល់ 3។ ដូច្នេះ $i^{1979} = i^{4(494)+3} = (i^4)^{494} \cdot i^3 = 1 \cdot (-i) = -i$

គ. យក $2019 \div 4$ បានផលចែក 504 សំណល់ 3។ ដូច្នេះ $i^{2019} = i^{4(504)+3} = (i^4)^{504} \cdot i^3 = 1 \cdot (-i) = -i$

ឃ. យក $2021 \div 4$ បានផលចែក 505 សំណល់ 1។ ដូច្នេះ $i^{2021} = i^{4(505)+1} = (i^4)^{505} \cdot i^1 = 1 \cdot i = i$

ង. យក $2025 \div 4$ បានផលចែក 506 សំណល់ 1។ ដូច្នេះ $i^{2025} = i^{4(506)+1} = (i^4)^{506} \cdot i^1 = 1 \cdot i = i$

ច. យក $2026 \div 4$ បានផលចែក 506 សំណល់ 2។ ដូច្នេះ $i^{2026} = i^{4(506)+2} = (i^4)^{506} \cdot i^2 = 1 \cdot (-1) = -1$

# ១.៣ សញ្ញាណនៃចំនួនកុំផ្លិច

**និយមន័យ ២ : ចំនួននិម្មិត**

ចំនួនកុំផ្លិចជាចំនួនដែលមានរាង $a+bi$ ដែល$a$ និង $b$ជាចំនួនពិត។ គេតាងសំណុំចំនួនកុំផ្លិចដោយ $\mathbb{C}$។

## លំហាត់គំរូ ៣

ចូរសរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ពីជគណិត

ក. $3+\sqrt{-144}$ ខ. $5+\sqrt{-12}$ គ. $6+\sqrt{-169}$ ឃ. $18-\sqrt{-169}$

**ចម្លើយ**:

**គន្លឹះដោះស្រាយ៖** បើយើងមានចំនួនកុំផ្លិចដែលមានរាង $a+\sqrt{-c}$ នោះយើងត្រូវបំប្លែងរ៉ាឌីកង់អវិជ្ជមានទៅជាចំនួននិម្មិត ដោយប្រើលក្ខណៈ $\sqrt{-c} = i\sqrt{c}$។

**ដំណោះស្រាយលម្អិត៖**

ក. $3+\sqrt{-144}=3+\sqrt{144\cdot(-1)}=3+12i$

ខ. $5+\sqrt{-12}=5+\sqrt{12\cdot(-1)}=5+i\sqrt{4\cdot 3}=5+2i\sqrt{3}$

គ. $6+\sqrt{-169}=6+\sqrt{169\cdot(-1)}=6+13i$

ឃ. $18-\sqrt{-169}=18-\sqrt{169\cdot(-1)}=18-13i$

**ជាទូទៅ ២**

បើគេមានចំនួនកុំផ្លិច $z=a+bi$ នោះចំនួនកុំផ្លិចឆ្លាស់នៃ $z$ តាងដោយ $\bar{z}=a-bi$។

## លំហាត់គំរូ ៤

កំណត់ចំនួនកុំផ្លិចឆ្លាស់នៃចំនួនកុំផ្លិចខាងក្រោម៖

ក. $7+\sqrt{-49}$ ខ. $15+\sqrt{-121}$ គ. $11+\sqrt{-216}$ ឃ. $12-\sqrt{-288}$

**ចម្លើយ:**

**គន្លឹះដោះស្រាយ៖** ចំនួនកុំផ្លិចឆ្លាស់នៃ $z=a+bi$ គឺ $\bar{z}=a-bi$។ ដូច្នេះយើងត្រូវសរសេរចំនួនដែលគេឲ្យជាទម្រង់ពីជគណិត $a+bi$ សិន ទើបទាញរកចំនួនឆ្លាស់របស់វា។

**ដំណោះស្រាយលម្អិត៖**

ក. តាង $z=7+\sqrt{-49}=7+7i$ នោះចំនួនកុំផ្លិចឆ្លាស់គឺ $\bar{z}=7-7i$

ខ. តាង $z=15+\sqrt{-121}=15+11i$ នោះចំនួនកុំផ្លិចឆ្លាស់គឺ $\bar{z}=15-11i$

គ. តាង $z=11+\sqrt{-216}=11+i\sqrt{36\cdot 6}=11+6i\sqrt{6}$ នោះចំនួនកុំផ្លិចឆ្លាស់គឺ $\bar{z}=11-6i\sqrt{6}$

ឃ. តាង $z=12-\sqrt{-288}=12-i\sqrt{144\cdot 2}=12-12i\sqrt{2}$ នោះចំនួនកុំផ្លិចឆ្លាស់គឺ $\bar{z}=12+12i\sqrt{2}$

**ជាទូទៅ ៣**

ចំនួនកុំផ្លិចផ្ទុយនៃចំនួនកុំផ្លិច $z=a+bi$ តាងដោយ $-z=-a-bi$។

## លំហាត់គំរូ ៥

កំណត់ចំនួនកុំផ្លិចផ្ទុយនៃចំនួនកុំផ្លិចខាងក្រោម៖

ក. $7+\sqrt{-49}$ ខ. $15+\sqrt{-121}$ គ. $11+\sqrt{-216}$ ឃ. $12-\sqrt{-288}$

**ចម្លើយ:**

**គន្លឹះដោះស្រាយ៖** ចំនួនកុំផ្លិចផ្ទុយនៃ $z=a+bi$ គឺ $-z=-a-bi$ (ប្តូរសញ្ញាទាំងផ្នែកពិត និងផ្នែកនិម្មិត)។

**ដំណោះស្រាយលម្អិត៖**

ក. តាង $z=7+\sqrt{-49}=7+7i$ នោះចំនួនកុំផ្លិចផ្ទុយគឺ $-z=-7-7i$

ខ. តាង $z=15+\sqrt{-121}=15+11i$ នោះចំនួនកុំផ្លិចផ្ទុយគឺ $-z=-15-11i$

គ. តាង $z=11+\sqrt{-216}=11+6i\sqrt{6}$ នោះចំនួនកុំផ្លិចផ្ទុយគឺ $-z=-11-6i\sqrt{6}$

ឃ. តាង $z=12-\sqrt{-288}=12-12i\sqrt{2}$ នោះចំនួនកុំផ្លិចផ្ទុយគឺ $-z=-12+12i\sqrt{2}$

## ១.៤ ចំនួនកុំផ្លិចពីរស្មើគ្នា

**ជាទូទៅ ៤**

ចំនួនកុំផ្លិចពីរស្មើគ្នា គេមានពីរចំនួនកុំផ្លិច $z_1=a+bi$ និង $z_2=c+di$ បើ $z_1=z_2 \Rightarrow a=c$ និង $b=d$។

**លំហាត់គំរូ ៦**

ចូរកំណត់តម្លៃនៃចំនួនពិត $a$ និង $b$ ដើម្បីឲ្យចំនួនកុំផ្លិចទាំងពីរខាងក្រោមស្មើគ្នា៖

ក. $(a+bi)+(2-3i)=5+i$

ខ. $(a+bi)(1+i)=2+4i$

គ. $(a+bi)(2-i)=7+i$

ឃ. $(a+bi)^2=3+4i$

ង. $(a+bi)(a-bi)=13$

ច. $\dfrac{a+bi}{1+i}=2-i$

ឆ. $(a+bi)+(b-ai)=3+i$

ជ. $(a+bi)i=-2+5i$

**ចម្លើយ:**

**គន្លឹះដោះស្រាយ៖** ពីរចំនួនកុំផ្លិចស្មើគ្នា លុះត្រាតែផ្នែកពិតស្មើផ្នែកពិត និងផ្នែកនិម្មិតស្មើផ្នែកនិម្មិត។

**ដំណោះស្រាយលម្អិត៖**

ក. $(a+bi)+(2-3i)=5+i \implies (a+2)+(b-3)i=5+i$

ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិត យើងបាន៖

$$\begin{cases} a+2=5 \\ b-3=1 \end{cases} \implies \begin{cases} a=3 \\ b=4 \end{cases}$$

ខ. $(a+bi)(1+i)=2+4i \implies a+ai+bi+bi^2=2+4i$

$\implies (a-b)+(a+b)i=2+4i$

ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិត យើងបានប្រព័ន្ធសមីការ៖

$$\begin{cases} a-b=2 \\ a+b=4 \end{cases}$$

បូកសមីការទាំងពីរបញ្ចូលគ្នាបាន $2a=6 \implies a=3$ ។ ជំនួសក្នុងសមីការទីពីរ $3+b=4 \implies b=1$។

ដូចនេះ $a=3, b=1$។

គ. $(a+bi)(2-i)=7+i \implies 2a-ai+2bi-bi^2=7+i$

$\implies (2a+b)+(-a+2b)i=7+i$

ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិត យើងបានប្រព័ន្ធសមីការ៖

$$\begin{cases} 2a+b=7 \\ -a+2b=1 \end{cases}$$

គុណសមីការទីពីរនឹង ២ រួចបូកនឹងសមីការទីមួយ យើងបាន $5b=9 \implies b=\frac{9}{5}$។ ជំនួសក្នុងសមីការទីមួយ $2a+\frac{9}{5}=7 \implies 2a=\frac{26}{5} \implies a=\frac{13}{5}$។

ដូចនេះ $a=\frac{13}{5}, b=\frac{9}{5}$។

ឃ. $(a+bi)^2=3+4i \implies a^2+2abi+b^2i^2=3+4i$

$\implies (a^2-b^2)+2abi=3+4i$

ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិត យើងបានប្រព័ន្ធសមីការ៖

$$\begin{cases} a^2-b^2=3 \quad (1) \\ 2ab=4 \implies ab=2 \quad (2) \end{cases}$$

តាមលក្ខណៈម៉ូឌុល $|(a+bi)^2|=|3+4i| \implies a^2+b^2=\sqrt{3^2+4^2}=5 \quad (3)$។

បូកសមីការ (1) និង (3) គេបាន $2a^2=8 \implies a^2=4 \implies a=\pm 2$។

- បើ $a=2$ នោះពី (2) គេបាន $b=1$។
- បើ $a=-2$ នោះពី (2) គេបាន $b=-1$។

ដូចនេះ $(a=2, b=1)$ ឬ $(a=-2, b=-1)$។

ង. $(a+bi)(a-bi)=13 \implies a^2-b^2i^2=13 \implies a^2+b^2=13$

សមីការនេះមានចម្លើយច្រើនរាប់មិនអស់ (រាល់គូ $(a,b)$ នៃចំនួនពិតដែលផ្ទៀងផ្ទាត់ $a^2+b^2=13$)។ ឧទាហរណ៍ $a=\pm 3, b=\pm 2$ ឬ $a=\pm 2, b=\pm 3$ ជាដើម។

ឋ. $\dfrac{a+bi}{1+i}=2-i \implies a+bi=(2-i)(1+i)$

$\implies a+bi=2+2i-i-i^2=2+i+1=3+i$

ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិត គេបាន $a=3, b=1$។

ឆ. $(a+bi)+(b-ai)=3+i \implies (a+b)+(b-a)i=3+i$

ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិត យើងបានប្រព័ន្ធសមីការ៖

$$\begin{cases} a+b=3 \\ -a+b=1 \end{cases}$$

បូកបញ្ចូលគ្នាបាន $2b=4 \implies b=2$។ ជំនួសបាន $a+2=3 \implies a=1$។

ដូចនេះ $a=1, b=2$។

ជ. $(a+bi)i=-2+5i \implies ai+bi^2=-2+5i$

$\implies -b+ai=-2+5i$

ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិត គេបាន $-b=-2 \implies b=2$ និង $a=5$។

ដូចនេះ $a=5, b=2$។

## លំហាត់គំរូ ៧

កំណត់តម្លៃនៃចំនួនពិត $x$ និង $y$ ដែលផ្ទៀងផ្ទាត់សមភាពខាងក្រោម៖

១. $-6+3yi=3x-\sqrt{-25}$

២. $x-iy=3+4i$

៣. $(2+i)x+y=2-3i$

៤. $(1+i)x+(3-5i)y=1-3i$

**ចម្លើយ:**

### ដំណោះស្រាយលម្អិត៖

១. $-6+3yi=3x-\sqrt{-25}$

ដោយ $\sqrt{-25}=5i$ គេបាន $-6+3yi=3x-5i$។ ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិត៖ $\begin{cases} 3x=-6 \\ 3y=-5 \end{cases} \Rightarrow \begin{cases} x=-2 \\ y=-\frac{5}{3} \end{cases}$

២. $x-iy=3+4i$

ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិត គេបាន៖ $\begin{cases} x=3 \\ -y=4 \end{cases} \Rightarrow \begin{cases} x=3 \\ y=-4 \end{cases}$

៣. $(2+i)x+y=2-3i$

ពន្លាតអង្គទី១៖ $2x+xi+y=(2x+y)+xi$។ ផ្ទឹមអង្គទាំងពីរ៖ $\begin{cases} 2x+y=2 \\ x=-3 \end{cases} \Rightarrow \begin{cases} x=-3 \\ 2(-3)+y=2 \Rightarrow y=8 \end{cases}$

៤. $(1+i)x+(3-5i)y=1-3i$

ពន្លាតអង្គទី១៖ $x+xi+3y-5yi=(x+3y)+(x-5y)i$។ ផ្ទឹមអង្គទាំងពីរ៖ $\begin{cases} x+3y=1 \\ x-5y=-3 \end{cases} \Rightarrow 8y=4 \Rightarrow y=\frac{1}{2}$ និង $x=-\frac{1}{2}$

## ២ ប្រមាណវិធីលើចំនួនកុំផ្លិច

ក. ប្រមាណវិធីបូក
បើ $z_1=a+bi$ និង $z_2=c+di$ នោះគេបាន $z_1+z_2=(a+c)+(b+d)i$។

ខ. ប្រមាណវិធីដក
បើ $z_1=a+bi$ និង $z_2=c+di$ នោះគេបាន $z_1-z_2=(a-c)+(b-d)i$។

គ. ប្រមាណវិធីគុណ
បើ $z_1=a+bi$ និង $z_2=c+di$ នោះគេបាន $z_1\cdot z_2=(ac-bd)+(ad+bci$។

ឃ. ប្រមាណវិធីចែក
បើ $z_1=a+bi$ និង $z_2=c+di$ នោះគេបាន $\frac{z_1}{z_2}=\frac{a+bi}{c+di}=\frac{(ac+bd)+(bc-ad)i}{c^2+d^2}$។

### លំហាត់គំរូ ៨

ចូរធ្វើប្រមាណវិធីនៃចំនួនកុំផ្លិចខាងក្រោម៖

ក. $(3+2i)+(5-4i)$

ខ. $(7-3i)-(2+5i)$

គ. $(2+i)(4-3i)$

ឃ. $(5-2i)(1+3i)$

ង. $\frac{6+4i}{2-i}$

ច. $\frac{3-5i}{1+2i}$

**ចម្លើយ**:

**គន្លឹះដោះស្រាយ៖** - វិធីបូកនិងដក៖ គណនាផ្នែកពិតជាមួយផ្នែកពិត និងផ្នែកនិម្មិតជាមួយផ្នែកនិម្មិត។ - វិធីគុណ៖ គុណពង្រាយធម្មតា រួចជំនួស $i^2=-1$។ - វិធីចែក៖ គុណយកភាគយកនិងភាគបែងនឹងចំនួនកុំផ្លិចឆ្លាស់នៃភាគបែង រួចប្រើរូបមន្ត $(a+bi)(a-bi)=a^2+b^2$។

**ដំណោះស្រាយលម្អិត៖**

ក. $(3+2i)+(5-4i)=(3+5)+(2-4)i=8-2i$

ខ. $(7-3i)-(2+5i)=(7-2)+(-3-5)i=5-8i$

គ. $(2+i)(4-3i)=8-6i+4i-3i^2=8-2i-3(-1)=11-2i$

ឃ. $(5-2i)(1+3i)=5+15i-2i-6i^2=5+13i-6(-1)=11+13i$

ង. $\frac{2+3i}{1-2i}=\frac{(2+3i)(1+2i)}{(1-2i)(1+2i)}=\frac{2+4i+3i+6i^2}{1^2+2^2}=\frac{2+7i-6}{5}=\frac{-4+7i}{5}=-\frac{4}{5}+\frac{7}{5}i$

ច. $\frac{4-i}{3+2i}=\frac{(4-i)(3-2i)}{(3+2i)(3-2i)}=\frac{12-8i-3i+2i^2}{3^2+2^2}=\frac{12-11i-2}{13}=\frac{10-11i}{13}=\frac{10}{13}-\frac{11}{13}i$

## ៣ ចំនួនកុំផ្លិចឆ្លាស់

បើ$z=a+bi$ជាចំនួនកុំផ្លិចនោះចំនួនកុំផ្លិចឆ្លាស់របស់វាកំណត់ដោយ$\bar{z}=a-bi$។ ហើយបើគេមានពីរចំនួនកុំផ្លិច$z,w$នោះគេបាន៖

ក. $\overline{z+w}=\bar{z}+\bar{w}$ ខ. $\overline{z-w}=\bar{z}-\bar{w}$ គ. $\overline{z\cdot w}=\bar{z}\cdot\bar{w}$ ឃ. $\overline{\left(\frac{z}{w}\right)}=\frac{\bar{z}}{\bar{w}}$

### លំហាត់គំរូ ៩

គេមាន $z=2-3i$ និង $w=3-i$ ចូរផ្ទៀងផ្ទាត់ថាលក្ខណៈខាងក្រោមពិតជានិច្ច៖

ក. $\overline{z+w}=\bar{z}+\bar{w}$ ខ. $\overline{z-w}=\bar{z}-\bar{w}$ គ. $\overline{z\cdot w}=\bar{z}\cdot\bar{w}$ ឃ. $\overline{\left(\frac{z}{w}\right)}=\frac{\bar{z}}{\bar{w}}$

**ចម្លើយ:**

**គន្លឹះដោះស្រាយ៖** ដើម្បីផ្ទៀងផ្ទាត់ យើងត្រូវគណនាអង្គខាងឆ្វេង និងអង្គខាងស្តាំដោយឡែកពីគ្នា រួចប្រៀបធៀបលទ្ធផល។

**ដំណោះស្រាយលម្អិត៖** គេមាន $z=2-3i$ និង $w=3-i$

ក. $\overline{z+w}=\bar{z}+\bar{w}$

អង្គខាងឆ្វេង៖ $z+w=(2-3i)+(3-i)=5-4i \implies \overline{z+w}=5+4i$

អង្គខាងស្តាំ៖ $\bar{z}+\bar{w}=(2+3i)+(3+i)=5+4i$

ដូចនេះ $\overline{z+w}=\bar{z}+\bar{w}$ ពិត។

ខ. $\overline{z-w}=\bar{z}-\bar{w}$

អង្គខាងឆ្វេង៖ $z-w=(2-3i)-(3-i)=-1-2i \implies \overline{z-w}=-1+2i$

អង្គខាងស្តាំ៖ $\bar{z}-\bar{w}=(2+3i)-(3+i)=-1+2i$

ដូចនេះ $\overline{z-w}=\bar{z}-\bar{w}$ ពិត។

គ. $\overline{z\cdot w}=\bar{z}\cdot\bar{w}$

អង្គខាងឆ្វេង៖ $z\cdot w=(2-3i)(3-i)=6-2i-9i+3i^2=3-11i \implies \overline{z\cdot w}=3+11i$

អង្គខាងស្តាំ៖ $\bar{z}\cdot\bar{w}=(2+3i)(3+i)=6+2i+9i+3i^2=3+11i$

ដូចនេះ $\overline{z\cdot w}=\bar{z}\cdot\bar{w}$ ពិត។

ឃ. $\overline{\left(\frac{z}{w}\right)} = \frac{\bar{z}}{\bar{w}}$

អង្គខាងឆ្វេង៖ $\frac{z}{w} = \frac{2-3i}{3-i} = \frac{(2-3i)(3+i)}{3^2+1^2} = \frac{6+2i-9i-3i^2}{10} = \frac{9-7i}{10} \implies \overline{\left(\frac{z}{w}\right)} = \frac{9+7i}{10}$

អង្គខាងស្តាំ៖ $\frac{\bar{z}}{\bar{w}} = \frac{2+3i}{3+i} = \frac{(2+3i)(3-i)}{3^2+1^2} = \frac{6-2i+9i-3i^2}{10} = \frac{9+7i}{10}$

ដូចនេះ $\overline{\left(\frac{z}{w}\right)} = \frac{\bar{z}}{\bar{w}}$ ពិត។

## ៤ សមីការដឺក្រេទី២ មានមេគុណពិត

**ជាទូទៅ ៥**

គេមានសមីការដឺក្រេទី២ ដែលមានរាង $ax^2+bx+c=0,\quad a\neq 0, a,b,c\in\mathbb{R}$ និង $\Delta = b^2-4ac$ នោះឫសរបស់សមីការមានបីករណីដូចខាងក្រោម៖

ក. បើ $\Delta > 0$ សមីការមានឫសពីរគឺ $x_1 = \frac{-b+\sqrt{\Delta}}{2a}; x_2 = \frac{-b-\sqrt{\Delta}}{2a}$។

ខ. បើ $\Delta = 0$ សមីការមានឫសឌុបគឺ $x_1 = x_2 = \frac{-b}{2a}$

គ. បើ $\Delta < 0$ សមីការមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់គឺ $x_1 = \frac{-b+i\sqrt{-\Delta}}{2a}; x_2 = \frac{-b-i\sqrt{-\Delta}}{2a}$។

**សម្រាយបញ្ជាក់៖**

ចំពោះសមីការ $ax^2+bx+c=0$ ដែល $a\neq 0$ ។ យើងអាចសរសេរសមីការជាទម្រង់កាណូនិច៖

$$a\left(x^2+\frac{b}{a}x+\frac{c}{a}\right)=0$$

$$\left(x+\frac{b}{2a}\right)^2-\frac{b^2}{4a^2}+\frac{c}{a}=0$$

$$\left(x+\frac{b}{2a}\right)^2=\frac{b^2-4ac}{4a^2}$$

តាង $\Delta = b^2-4ac$ ហៅថា ឌីសគ្រីមីណង់។ សមីការក្លាយជា $\left(x+\frac{b}{2a}\right)^2 = \frac{\Delta}{4a^2}$។

- បើ $\Delta > 0$ នោះ $x+\frac{b}{2a} = \pm\frac{\sqrt{\Delta}}{2a} \implies x = \frac{-b\pm\sqrt{\Delta}}{2a}$។
- បើ $\Delta = 0$ នោះ $x+\frac{b}{2a} = 0 \implies x = \frac{-b}{2a}$។
- បើ $\Delta < 0$ នោះ $-\Delta > 0$។ ដោយ $i^2=-1$ គេអាចសរសេរ $\Delta = i^2(-\Delta) = (i\sqrt{-\Delta})^2$។
  សមីការក្លាយជា $\left(x+\frac{b}{2a}\right)^2 = \frac{(i\sqrt{-\Delta})^2}{(2a)^2} = \left(\frac{i\sqrt{-\Delta}}{2a}\right)^2$។
  ទាញបាន $x+\frac{b}{2a} = \pm\frac{i\sqrt{-\Delta}}{2a} \implies x = \frac{-b\pm i\sqrt{-\Delta}}{2a}$។

## លំហាត់គំរូ ១០

ចូរដោះស្រាយសមីការដឺក្រេទី២ខាងក្រោម៖

ក. $x^2-5x+6=0$

ខ. $x^2+3x-10=0$

គ. $2x^2-7x+3=0$

ឃ. $3x^2+5x-2=0$

ង. $x^2+2x+5=0$

ច. $2x^2-x+4=0$

ឆ. $x^2+4x+8=0$

ជ. $x^2+2x+5=0$

ឈ. $2x^2+3x+7=0$

**ចម្លើយ**:

**គន្លឹះដោះស្រាយ៖** សមីការដឺក្រេទី២ មានរាង $ax^2+bx+c=0$ យើងអាចគណនាឌីសគ្រីមីណង់ $\Delta=b^2-4ac$ ដើម្បីរកឫស។ (ចំពោះលំហាត់នេះ $\Delta>0$ នាំឱ្យសមីការមានឫសជាចំនួនពិត)។

**ដំណោះស្រាយលម្អិត៖**

ក. $x^2-5x+6=0$

$\Delta=(-5)^2-4(1)(6)=25-24=1 \implies \sqrt{\Delta}=1$

$x_1=\dfrac{5-1}{2}=2,\quad x_2=\dfrac{5+1}{2}=3$

ខ. $x^2+3x-10=0$

$\Delta=(3)^2-4(1)(-10)=9+40=49 \implies \sqrt{\Delta}=7$

$x_1=\dfrac{-3-7}{2}=-5,\quad x_2=\dfrac{-3+7}{2}=2$

គ. $2x^2-7x+3=0$

$\Delta=(-7)^2-4(2)(3)=49-24=25 \implies \sqrt{\Delta}=5$

$x_1=\dfrac{7-5}{4}=\dfrac{1}{2},\quad x_2=\dfrac{7+5}{4}=3$

ឃ. $3x^2+5x-2=0$

$\Delta=5^2-4(3)(-2)=25+24=49 \implies \sqrt{\Delta}=7$

$x_1=\dfrac{-5-7}{6}=-2,\quad x_2=\dfrac{-5+7}{6}=\dfrac{1}{3}$

ង. $x^2+2x+5=0$

$\Delta=2^2-4(1)(5)=4-20=-16 \implies \sqrt{\Delta}=4i$

$x_1=\dfrac{-2-4i}{2}=-1-2i,\quad x_2=\dfrac{-2+4i}{2}=-1+2i$

ច. $2x^2-x+4=0$

$\Delta=(-1)^2-4(2)(4)=1-32=-31 \implies \sqrt{\Delta}=i\sqrt{31}$

$x_1=\dfrac{1-i\sqrt{31}}{4},\quad x_2=\dfrac{1+i\sqrt{31}}{4}$

ឆ. $x^2+4x+8=0$

$\Delta=4^2-4(1)(8)=16-32=-16 \implies \sqrt{\Delta}=4i$

$x_1=\dfrac{-4-4i}{2}=-2-2i,\quad x_2=\dfrac{-4+4i}{2}=-2+2i$

ជ. $x^2+2x+5=0$

$\Delta=2^2-4(1)(5)=4-20=-16 \implies \sqrt{\Delta}=4i$

$x_1=\dfrac{-2-4i}{2}=-1-2i,\quad x_2=\dfrac{-2+4i}{2}=-1+2i$

ឈ. $2x^2+3x+7=0$

$\Delta=3^2-4(2)(7)=9-56=-47 \implies \sqrt{\Delta}=i\sqrt{47}$

$x_1=\dfrac{-3-i\sqrt{47}}{4},\quad x_2=\dfrac{-3+i\sqrt{47}}{4}$

## ករណីពិសេស (Special Cases)

ចំពោះសមីការដឺក្រេទី២ $ax^2+bx+c=0$ $(a\neq 0)$ យើងមានករណីពិសេសមួយចំនួនដែលអាចរកឫសបានយ៉ាងរហ័ស៖

- **ករណីទី១** $(b=0)$៖ សមីការក្លាយជា $ax^2+c=0 \iff x^2=-\dfrac{c}{a}$។
  បើ $\dfrac{c}{a}>0$ នោះសមីការមានឫសពីរជាចំនួននិម្មិតឆ្លាស់គ្នាគឺ $x=\pm i\sqrt{\dfrac{c}{a}}$។
- **ករណីទី២** $(c=0)$៖ សមីការក្លាយជា $ax^2+bx=0 \iff x(ax+b)=0$
  ទាញបានឫស៖ $x_1=0$ និង $x_2=-\dfrac{b}{a}$។
- **ករណីទី៣** $(a+b+c=0)$៖ សមីការមានឫសពីរគឺ $x_1=1$ និង $x_2=\dfrac{c}{a}$។
- **ករណីទី៤** $(a-b+c=0)$៖ សមីការមានឫសពីរគឺ $x_1=-1$ និង $x_2=-\dfrac{c}{a}$។

## ជាទូទៅ ៦

ទ្រឹស្តីបទផលបូក និងផលគុណឫស (Vieta's Formulas) បើ $x_1$ និង $x_2$ ជាឫសទាំងពីរនៃសមីការដឺក្រេទី២ $ax^2+bx+c=0$ $(a\neq 0)$ នោះយើងបានទំនាក់ទំនង៖

- **ផលបូកឫស** (Sum of Roots)៖ $S=x_1+x_2=-\dfrac{b}{a}$
- **ផលគុណឫស** (Product of Roots)៖ $P=x_1\cdot x_2=\dfrac{c}{a}$

បើដឹងផលបូក $S$ និងផលគុណ $P$ នោះ $x_1,x_2$ ជាឫសនៃសមីការ $X^2-SX+P=0$។

# ៥ ការតាងតាមបែបធរណីមាត្រនៃចំនួនកុំផ្លិច

**និយមន័យ ៣ : ប្លង់កុំផ្លិច**

បើ $z=a+bi$ ជាចំនួនកុំផ្លិចគេអាចតាងចំនួនកុំផ្លិច $z$ នេះនៅក្នុងប្លង់កុំផ្លិចដោយចំនុច $P(a,b)$ ចំនុច $P$ ហៅថាអាភិចនៃចំនួនកុំផ្លិច $z$។

# ៦ ចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

## ៦.១ ការតាងចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

គេមានតម្រុយអរតូណរម៉ាល់ $xOy$។ គេអាចតាងចំនួនកុំផ្លិច $z=a+bi$ ដោយចំនុច $M$ ដែលមានកូអរដោនេ $(a,b)$ ក្នុងតម្រុយនេះ។ គេថាចំណុច $M$ ជាចំណុចរូបភាពនៃចំនួនកុំផ្លិច $z=a+bi$ គេកំណត់សរសេរដោយ $M(z)$។ ម្យ៉ាងទៀតចំនួនកុំផ្លិច $z=a+bi$ អាចតាងដោយវ៉ិចទ័រ $\overrightarrow{OM}=(a,b)$ គេថាវ៉ិចទ័រ $\overrightarrow{OM}$ ជាវ៉ិចទ័ររូបភាពនៃចំនួននៃចំនួនកុំផ្លិច $z=a+bi$ ហើយកំណត់សរសេរដោយ $\overrightarrow{OM}=(z)$។ នៅពេលដែលគេដៅចំណុចក្នុងតម្រុយតាងចំនួនកុំផ្លិចប្លង់ដែលប្រដាប់ដោយតម្រុយនេះហៅថា ប្លង់កុំផ្លិច។ អ័ក្ស $(x'Ox)$ ហៅថាអ័ក្សពិត ហើយអ័ក្ស $(y'Oy)$ ហៅថាអ័ក្សនិម្មិត។




**លំហាត់គំរូ ១១**

តាងរូបភាពនៃចំនួនកុំផ្លិច $1+i, -1+2i$ និង $-2-i$ ដោយចំណុចក្នុងប្លង់ចំនួនកុំផ្លិច។ យើងតាងចំណុច $A,B$ និង $C$ ជារូបភាពរៀងគ្នានៃ $1+i, -1+2i$ និង $-2-i$ ដូចរូបខាងក្រោម៖




# ៧ វិចទ័ររូបភាព នៃផលបូក និង ផលដកចំនួនកុំផ្លិច និង ផលគុណចំនួនពិតជាមួយនឹងចំនួនកុំផ្លិច

## ៧.១ វិចទ័ររូបភាពនៃផលបូកចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

**លំហាត់គំរូ ១២**

កំណត់រូបភាពនៃ $z_1+z_2$ ដែល $z_1=2+i$ និង $z_2=1+2i$ ក្នុងប្លង់កុំផ្លិច។ តាងវិចទ័រ $\overrightarrow{OM_1}$ ជារូបភាពនៃចំនួនកុំផ្លិច $z_1$ និង វិចទ័រ $\overrightarrow{OM_2}$ ជារូបភាពនៃចំនួនកុំផ្លិច $z_2$។
គេបាន $z_1+z_2=\overrightarrow{OM_1}+\overrightarrow{OM_2}=\overrightarrow{OM}$ ($OM$ ជាអង្កត់ទ្រូងប្រលេឡូក្រាម)




ដូចនេះ $\overrightarrow{OM}$ ជារូបភាពនៃ $z_1+z_2$ ផលបូក $z_1+z_2=(2+i)+(1+2i)=3+3i$។

## ៧.២ វ៉ិចទ័ររូបភាពនៃផលដកចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

### លំហាត់គំរូ ១៣

កំណត់រូបភាពនៃផលដក $z_1 - z_2$ ដែល $z_1 = 2+i$ និង $z_2 = 1+2i$។ យើងចាត់ទុកថា $z_1 - z_2 = z_1 + (-z_2)$ តាងវ៉ិចទ័រ $\overrightarrow{OM_1}$ ជារូបភាពនៃចំនួនកុំផ្លិច $z_1$ និង វ៉ិចទ័រ $\overrightarrow{OM_2}$ ជារូបភាពនៃចំនួនកុំផ្លិច $z_2$ និង វ៉ិចទ័រ $\overrightarrow{OM_2'}$ ជារូបភាពនៃ $-z_2 = -1-2i$ ។

គេបាន $z_1 - z_2 = z_1 + (-z_2) = \overrightarrow{OM_1} + \overrightarrow{OM_2'} = \overrightarrow{OM}$ ជារូបភាពនៃផលដក។

ចំនួនកុំផ្លិច $z_1 - z_2 = 2+i-(1+2i) = 1-i$។




## ៧.៣ វ៉ិចទ័ររូបភាពនៃផលគុណចំនួនពិត នឹង ចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

### លំហាត់គំរូ ១៤

កំណត់រូបភាពនៃចំនួនកុំផ្លិច $2z$ បើ $z = 2+i$។ តាងវ៉ិចទ័រ $\overrightarrow{OM_1}$ ជារូពភាពនៃចំនួនកុំផ្លិច $z$ ហើយ $\overrightarrow{OM}$ ជារូបភាពនៃចំនួនកុំផ្លិច $2z$ ។ គេបាន $\overrightarrow{OM} = 2\overrightarrow{OM_1}$ ជារូបភាពនៃ $2z$ ដែល $2z = 2(2+i) = 4+2i$។


Im
Re
3
2
1
O
1
2
3
4
5
M
$M_1$
2z
z

## វិញ្ញាសាពហុជ្រើសរើស៖ ចំនួនកុំផ្លិច (១០០ លំហាត់)

រៀបតាមកម្រិត *Bloom's Taxonomy Level 1 - 6*

១. តើឯកតានិម្មិត $i^2$ ស្មើនឹងប៉ុន្មាន ?

ក. $1$ ខ. $-1$ គ. $i$ ឃ. $-i$

២. បើ $z = a + bi$ តើ $a$ ហៅថាផ្នែកអ្វី ?

ក. ផ្នែកនិម្មិត ខ. ផ្នែកពិត គ. ផ្នែកឆ្លាស់ ឃ. ផ្នែកផ្ទុយ

៣. ចំនួនកុំផ្លិចឆ្លាស់នៃ $z = a + bi$ តាងដោយ៖

ក. $-z$ ខ. $|z|$ គ. $\bar{z}$ ឃ. $z'$

៤. តើ $i^{4k}$ ស្មើនឹងប៉ុន្មាន ចំពោះ $k$ ជាចំនួនគត់វិជ្ជមាន ?

ក. $1$ ខ. $-1$ គ. $i$ ឃ. $0$

៥. តើផ្នែកនិម្មិតនៃ $z = 7i$ គឺ៖

ក. $0$ ខ. $7$ គ. $7i$ ឃ. $-7$

៦. រូបមន្តផលបូក $z_1 + z_2$ បើ $z_1 = a + bi, z_2 = c + di$ គឺ៖

ក. $(a+c)+(b+d)i$ គ. $ac+bdi$

ខ. $(a-c)+(b-d)i$ ឃ. $(a+d)+(b+c)i$

៧. បើ $z = a + bi$ នោះចំនួនផ្ទុយ $-z$ គឺ៖

ក. $a - bi$ ខ. $-a + bi$ គ. $-a - bi$ ឃ. $b + ai$

៨. តើ $i^3$ ស្មើនឹងប៉ុន្មាន ?

ក. $1$ ខ. $-1$ គ. $i$ ឃ. $-i$

៩. សំណុំចំនួនកុំផ្លិចតាងដោយអក្សរអ្វី ?

ក. $\mathbb{R}$ ខ. $\mathbb{Q}$ គ. $\mathbb{C}$ ឃ. $\mathbb{Z}$

១០. តើ $i^1$ ស្មើនឹងអ្វី ?

ក. $1$ ខ. $-1$ គ. $i$ ឃ. $-i$

១១. ក្នុង $z = a + bi$ បើ $b = 0$ នោះ $z$ ជា៖

ក. ចំនួនពិត ខ. ចំនួននិម្មិតសុទ្ធ គ. ចំនួនកុំផ្លិចឆ្លាស់ ឃ. សូន្យ

១២. តើ $i^{4k+1}$ ស្មើនឹងប៉ុន្មាន ?

ក. 1 ខ. $-1$ គ. $i$ ឃ. $-i$

១៣. តើ $i^{4k+2}$ ស្មើនឹងប៉ុន្មាន ?

ក. 1 ខ. $-1$ គ. $i$ ឃ. $-i$

១៤. តើ $i^{4k+3}$ ស្មើនឹងប៉ុន្មាន ?

ក. 1 ខ. $-1$ គ. $i$ ឃ. $-i$

១៥. អ័ក្សដេកក្នុងប្លង់កុំផ្លិចហៅថា៖

ក. អ័ក្សនិម្មិត ខ. អ័ក្សពិត គ. អ័ក្សអរដោនេ ឃ. គ្មានចម្លើយ

១៦. បើ $z=bi$ នោះ $z$ ហៅថា៖

ក. ចំនួនពិត ខ. ចំនួននិម្មិតសុទ្ធ គ. ចំនួនផ្ទុយ ឃ. ចំនួនឆ្លាស់

១៧. រូបមន្តផលដក $z_1-z_2$ គឺ៖

ក. $(a+c)+(b+d)i$ គ. $ac-bd$
ខ. $(a-c)+(b-d)i$ ឃ. $(a-d)+(b-c)i$

១៨. តើ $i^0$ ស្មើនឹងប៉ុន្មាន ?

ក. 0 ខ. 1 គ. $i$ ឃ. $-1$

១៩. ចំណុច $M(a,b)$ ហៅថាអ្វីនៃចំនួនកុំផ្លិច $z=a+bi$?

ក. ម៉ូឌុល ខ. អាភិច គ. អាគុយម៉ង់ ឃ. រូបភាព

២០. តើ $\sqrt{-1}$ កំណត់ដោយសញ្ញាអ្វី ?

ក. 1 ខ. $i$ គ. $-1$ ឃ. $\pi$

២១. តើលទ្ធផលនៃ $\sqrt{-144}$ ស្មើនឹងប៉ុន្មាន ?

ក. 12 ខ. $-12$ គ. $12i$ ឃ. $-12i$

២២. បើ $z=3-2i$ តើផ្នែកនិម្មិត $Im(z)$ គឺ៖

ក. 3 ខ. 2 គ. $-2$ ឃ. $-2i$

២៣. បើ $z$ ជាចំនួននិម្មិតសុទ្ធ នោះគេបាន៖

ក. $Re(z)=0$ ខ. $Im(z)=0$ គ. $z=0$ ឃ. $Re(z)=Im(z)$

២៤. ក្នុងប្លង់កុំផ្លិច ចំណុច $M(a,b)$ ជាអាភិចនៃ៖

ក. $z = b + ai$ ខ. $z = a + bi$ គ. $z = a - bi$ ឃ. $z = -a - bi$

២៥. ស្វ័យគុណ $i^{2026}$ មានតម្លៃស្មើនឹង៖

ក. $i$ ខ. $-i$ គ. $1$ ឃ. $-1$

២៦. តើ $\sqrt{-25}$ ស្មើនឹងប៉ុន្មាន ?

ក. $5$ ខ. $-5$ គ. $5i$ ឃ. $-5i$

២៧. តើផ្នែកពិតនៃ $z = -4 + 9i$ គឺ៖

ក. $4$ ខ. $-4$ គ. $9$ ឃ. $9i$

២៨. បើ $z = \sqrt{-16} + 3$ នោះទម្រង់ពីជគណិតគឺ៖

ក. $4i + 3$ ខ. $3 + 4i$ គ. $3 - 4i$ ឃ. $-3 + 4i$

២៩. ចំនួនកុំផ្លិចឆ្លាស់នៃ $z = -2 - 5i$ គឺ៖

ក. $2 + 5i$ ខ. $-2 + 5i$ គ. $2 - 5i$ ឃ. $-2 - 5i$

៣០. ចំនួនផ្ទុយនៃ $z = 6 - i$ គឺ៖

ក. $-6 - i$ ខ. $6 + i$ គ. $-6 + i$ ឃ. $i - 6$

៣១. តើ $i^{100}$ ស្មើនឹងប៉ុន្មាន ?

ក. $1$ ខ. $-1$ គ. $i$ ឃ. $-i$

៣២. តើ $i^{50}$ ស្មើនឹងប៉ុន្មាន ?

ក. $1$ ខ. $-1$ គ. $i$ ឃ. $-i$

៣៣. បើ $z_1 = z_2$ នោះ៖

ក. ផ្នែកពិតស្មើគ្នា គ. ទាំង a និង b ត្រឹមត្រូវ

ខ. ផ្នែកនិម្មិតស្មើគ្នា ឃ. ផ្នែកពិតស្មើផ្នែកនិម្មិត

៣៤. តើ $\sqrt{-c}$ (បើ $c > 0$) ស្មើនឹង៖

ក. $ci$ ខ. $\sqrt{ci}$ គ. $-\sqrt{c}$ ឃ. $\sqrt{c}i$

៣៥. អាភិចនៃចំណុច $P(0,3)$ គឺ៖

ក. $3$ ខ. $3i$ គ. $-3i$ ឃ. $0$

៣៦. អាភិចនៃចំណុច $Q(-2,0)$ គឺ៖

ក. $-2$ ខ. $-2i$ គ. $2$ ឃ. $2i$

៣៧. តើ $i^{11}$ ស្មើនឹងប៉ុន្មាន?

ក. $1$ ខ. $-1$ គ. $i$ ឃ. $-i$

៣៨. ចំនួនកុំផ្លិច $z=a+bi$ ជាចំនួនពិត លុះត្រាតែ៖

ក. $a=0$ ខ. $b=0$ គ. $a=b$ ឃ. $a=1$

៣៩. តើ $\sqrt{-12}$ ស្មើនឹង៖

ក. $2\sqrt{3}$ ខ. $2\sqrt{3}i$ គ. $3\sqrt{2}i$ ឃ. $12i$

៤០. បើ $z=a-bi$ នោះ $\bar{z}$ គឺ៖

ក. $a-bi$ ខ. $a+bi$ គ. $-a+bi$ ឃ. $-a-bi$

៤១. គណនា $(3+2i)+(5-4i)$៖

ក. $8+6i$ ខ. $8-2i$ គ. $2-2i$ ឃ. $8+2i$

៤២. គណនាផលគុណ $(2+i)(3-i)$៖

ក. $6-i$ ខ. $5+i$ គ. $7+i$ ឃ. $7-i$

៤៣. រក $x,y$ បើ $x+yi=(2-i)^2$៖

ក. $x=3,y=-4$ ខ. $x=5,y=-4$ គ. $x=3,y=4$ ឃ. $x=5,y=4$

៤៤. គណនា $\frac{1+i}{1-i}$៖

ក. $1$ ខ. $-1$ គ. $i$ ឃ. $-i$

៤៥. ឫសនៃសមីការ $x^2+9=0$ គឺ៖

ក. $x=\pm 3$ ខ. $x=\pm 3i$ គ. $x=3i$ ឃ. $x=-9$

៤៦. គណនា $(1+i)+(2-3i)$៖

ក. $3-2i$ ខ. $3+2i$ គ. $3-4i$ ឃ. $1-2i$

៤៧. គណនា $(5+4i)-(2+i)$៖

ក. $3+3i$ ខ. $7+5i$ គ. $3+5i$ ឃ. $7+3i$

៤៨. គណនា $i^{10}+i^{20}$៖

ក. 0 ខ. 2 គ. $1-i$ ឃ. $i+1$

៤៩. គណនា $(2i)^3$៖

ក. $8i$ ខ. $-8i$ គ. $6i$ ឃ. $-6i$

៥០. គណនា $\frac{2}{i}$៖

ក. 2 ខ. $-2$ គ. $2i$ ឃ. $-2i$

៥១. បើ $z=1+i$ នោះ $z^2$ គឺ៖

ក. 2 ខ. $2i$ គ. $-2i$ ឃ. 1

៥២. គណនា $(3+i)(3-i)$៖

ក. 8 ខ. 9 គ. 10 ឃ. $10i$

៥៣. ឫសនៃសមីការ $x^2+16=0$ គឺ៖

ក. $\pm 4$ ខ. $\pm 4i$ គ. 4 ឃ. $4i$

៥៤. គណនា $i(2-3i)$៖

ក. $3+2i$ ខ. $2i-3$ គ. $-3+2i$ ឃ. $3-2i$

៥៥. បើ $z=4-3i$ នោះ $z\cdot\bar{z}$ គឺ៖

ក. 7 ខ. 25 គ. 5 ឃ. 1

៥៦. គណនា $(1-i)^2$៖

ក. $2i$ ខ. $-2i$ គ. 2 ឃ. $-2$

៥៧. ឫសនៃសមីការ $x^2+1=0$ គឺ៖

ក. 1 ខ. $-1$ គ. $\pm i$ ឃ. 0

៥៨. គណនា $i^4+i^2$៖

ក. 0 ខ. 1 គ. 2 ឃ. $-1$

៥៩. បើ $x+yi=3-4i$ នោះ $x+y$ គឺ៖

ក. 7 ខ. $-1$ គ. 1 ឃ. $-7$

៦០. គណនា $(1+i)(1+i)$៖

ក. $2$ ខ. $2i$ គ. $0$ ឃ. $1+2i$

៦១. បើ $z=\frac{3-i}{1+2i}$ តើផ្នែកពិតរបស់ $z$ គឺ៖

ក. $1/5$ ខ. $1$ គ. $-7/5$ ឃ. $3$

៦២. កំណត់តម្លៃ $x$ ដើម្បីឲ្យ $z=\frac{x-i}{1+i}$ ជាចំនួនពិត៖

ក. $x=1$ ខ. $x=-1$ គ. $x=0$ ឃ. $x=2$

៦៣. បើ $z_1=2+i$ និង $z_2=-2+i$ តើ $z_1+z_2$ ជាអ្វី?

ក. ចំនួនពិត ខ. ចំនួននិម្មិតសុទ្ធ គ. សូន្យ ឃ. គ្មានចម្លើយ

៦៤. បើ $z=(a+bi)^2$ ជាចំនួននិម្មិតសុទ្ធ នោះគេបាន៖

ក. $a=0$ ខ. $b=0$ គ. $a^2=b^2$ ឃ. $a=b=0$

៦៥. តម្លៃនៃ $i+i^2+i^3$ គឺ៖

ក. $i$ ខ. $-1$ គ. $-1+i$ ឃ. $-1-i$

៦៦. បើ $(x+yi)i=1$ នោះ $x,y$ គឺ៖

ក. $x=0,y=1$ ខ. $x=0,y=-1$ គ. $x=1,y=0$ ឃ. $x=-1,y=0$

៦៧. បើ $z=\frac{1}{1+i}$ នោះ $z$ ស្មើនឹង៖

ក. $1-i$ ខ. $\frac{1-i}{2}$ គ. $\frac{1+i}{2}$ ឃ. $i$

៦៨. ឫសនៃសមីការ $x^2-2x+2=0$ គឺ៖

ក. $1\pm i$ ខ. $2\pm 2i$ គ. $-1\pm i$ ឃ. $\pm 1$

៦៩. បើ $z=i^{1975}$ តើ $z$ ស្មើនឹងអ្វី?

ក. $1$ ខ. $-1$ គ. $i$ ឃ. $-i$

៧០. បើ $z$ ជាចំនួនកុំផ្លិច នោះ $z+\bar{z}$ ជានិច្ចកាលជា៖

ក. ចំនួនពិត ខ. ចំនួននិម្មិតសុទ្ធ គ. សូន្យ ឃ. មិនអាចកំណត់

៧១. បើ $z$ ជាចំនួនកុំផ្លិច នោះ $z-\bar{z}$ ជានិច្ចកាលជា៖

ក. ចំនួនពិត ខ. ចំនួននិម្មិតសុទ្ធ គ. សូន្យ ឃ. មិនអាចកំណត់

៧២. កំណត់តម្លៃ $a$ បើ $a+2i=3+bi$៖

ក. 2 ខ. 3 គ. $b$ ឃ. 0

៧៣. បើ $z=(1+i)^4$ នោះ $z$ ស្មើនឹង៖

ក. $4i$ ខ. $-4$ គ. 4 ឃ. $-4i$

៧៤. តើផ្នែកនិម្មិតនៃ $z=\frac{1}{i}$ គឺ៖

ក. 1 ខ. $-1$ គ. 0 ឃ. $i$

៧៥. បើ $z=1-i$ នោះ $\bar{z}^2$ គឺ៖

ក. $2i$ ខ. $-2i$ គ. 2 ឃ. $-2$

៧៦. រក $x$ បើ $x+i=\bar{i}$៖

ក. 0 ខ. 1 គ. $-1$ ឃ. គ្មានចម្លើយ

៧៧. បើ $z=\sqrt{-4}\cdot\sqrt{-9}$ នោះ $z$ ស្មើនឹង៖

ក. 6 ខ. $-6$ គ. $6i$ ឃ. $-6i$

៧៨. បើ $z=a+bi$ និង $\bar{z}=a-bi$ នោះ $z\cdot\bar{z}$ គឺ៖

ក. $a^2-b^2$ ខ. $a^2+b^2$ គ. $2a$ ឃ. $2bi$

៧៩. បើ $z=i+i^2+i^3+i^4$ នោះ $z$ គឺ៖

ក. 0 ខ. 1 គ. $i$ ឃ. $-1$

៨០. ឫសនៃសមីការ $x^2+x+1=0$ មានឌីស្ក្រីមីណង់ $\Delta$ ស្មើ៖

ក. 1 ខ. $-3$ គ. 3 ឃ. $-4$

៨១. តើតម្លៃនៃ $i^1+i^2+i^3+i^4$ ស្មើនឹងប៉ុន្មាន?

ក. 0 ខ. 1 គ. $i$ ឃ. $-1$

៨២. បើ $\bar{z}=-z$ នោះ $z$ ជាចំនួនប្រភេទអ្វី?

ក. ចំនួនពិត ខ. ចំនួននិម្មិតសុទ្ធ គ. ចំនួនសូន្យ ឃ. មិនអាចកំណត់

៨៣. តើតម្លៃនៃ $(1+i)^{10}$ ស្មើនឹង៖

ក. $32i$ ខ. $-32i$ គ. 32 ឃ. $-32$

៨៤. បើ $z=\frac{1+i}{2+i}$ នោះផ្នែកនិម្មិតគឺ៖

ក. $1/5$ ខ. $3/5$ គ. $-1/5$ ឃ. $2/5$

៨៥. តើមួយណាជាចំនួននិម្មិតសុទ្ធ?

ក. $(1+i)^2$ ខ. $(1+i)^4$ គ. $(1-i)^2$ ឃ. ទាំង a និង c

៨៦. បើ $z=\cos\theta+i\sin\theta$ នោះ $|z|$ ស្មើនឹង៖

ក. $0$ ខ. $1$ គ. $\sin\theta$ ឃ. $\cos\theta$

៨៧. បើ $z=1+i\sqrt{3}$ នោះ $z^2-2z+4$ ស្មើ៖

ក. $0$ ខ. $1$ គ. $i$ ឃ. $4$

៨៨. តម្លៃ $i^n+i^{n+1}+i^{n+2}+i^{n+3}$ គឺ៖

ក. $1$ ខ. $0$ គ. $i$ ឃ. $-1$

៨៩. បើ $z=\frac{1+2i}{1-i}$ នោះ $\bar{z}$ គឺ៖

ក. $-1/2-3i/2$ ខ. $-1/2+3i/2$ គ. $1/2-3i/2$ ឃ. $1/2+3i/2$

៩០. បើ $z_1=1+i, z_2=1-i$ នោះ $z_1/z_2+z_2/z_1$ គឺ៖

ក. $0$ ខ. $2$ គ. $2i$ ឃ. $-2$

៩១. សមីការដឺក្រេទី២ ដែលមានឫស $x=1\pm 2i$ គឺ៖

ក. $x^2-2x+5=0$ គ. $x^2-2x-5=0$

ខ. $x^2+2x+5=0$ ឃ. $x^2+x+1=0$

៩២. រក $z$ បើ $z^2=3+4i$៖

ក. $2+i$ និង $-2-i$ ខ. $2-i$ គ. $1+2i$ ឃ. $3+i$

៩៣. កំណត់តម្លៃ $n$ តូចបំផុតដែលវិជ្ជមាន ដើម្បីឲ្យ $i^n=1$៖

ក. $2$ ខ. $4$ គ. $8$ ឃ. $1$

៩៤. បើ $z=x+yi$ និង $|z-i|=|z+i|$ នោះសំណុំចំណុច $M(x,y)$ ជា៖

ក. រង្វង់ ខ. អ័ក្សពិត គ. អ័ក្សនិម្មិត ឃ. បន្ទាត់ $y=x$

៩៥. រកតម្លៃ $k$ ដើម្បីឲ្យ $x^2-2x+k=0$ មានឫសជាចំនួនកុំផ្លិច៖

ក. $k>1$ ខ. $k<1$ គ. $k=1$ ឃ. $k=0$

៩៦. បើ $z=(1+i)^n$ ជាចំនួនពិត នោះ $n$ អាចជា៖

ក. 2 ខ. 4 គ. 1 ឃ. 3

៩៧. បង្កើតសមីការដឺក្រេទី២ ដែលមានឫស $i$ និង $-i$៖

ក. $x^2+1=0$ ខ. $x^2-1=0$ គ. $x^2+x+1=0$ ឃ. $x^2=0$

៩៨. រកចំនួនកុំផ្លិច $z$ ដែល $\bar{z}=z^2$៖

ក. 1 គ. 0

ខ. $-1/2+i\sqrt{3}/2$ ឃ. គ្រប់ចម្លើយខាងលើ

៩៩. បើ $z+1/z=2$ នោះ $z^{100}+1/z^{100}$ គឺ៖

ក. 2 ខ. 1 គ. 0 ឃ. $2i$

១០០. កំណត់ចំនួនកុំផ្លិច $z$ ដែលផ្ទៀងផ្ទាត់ $z+2\bar{z}=6-i$៖

ក. $2+i$ ខ. $2-i$ គ. $1+i$ ឃ. $3-i$

# លំហាត់អនុវត្តន៍បន្ថែម

១. ចូរបំប្លែងចំនួនខាងក្រោមជាចំនួននិមិត្ត៖

ក. $\sqrt{-4}$ គ. $\sqrt{-6}$ ង. $\sqrt{-144}$ ឆ. $\sqrt{-64}$

ខ. $-\sqrt{-121}$ ឃ. $\sqrt{-12}$ ច. $-\sqrt{-17}$ ជ. $\sqrt{-169}$

២. កំណត់តម្លៃនៃចំនួនពិត $x$ និង $y$ ដែលផ្ទៀងផ្ទាត់សមភាពខាងក្រោម៖

ក. $(1+i)x+(3-5i)y=1-3i$

ខ. $-4-\sqrt{-8}=-x-iy$

គ. $(x-1)+(y+3)i=1-3i$

ឃ. $(x+iy)^2=8-6i$

ង. $(x+iy)^2=-5+12i$

ច. $(x+iy)^2=24-10i$

៣. ដោះស្រាយសមីការខាងក្រោមក្នុងសំណុំចំនួនកុំផ្លិច៖

ក. $x^2=-18$ គ. $x^2=-81$ ង. $x^2=-625$ ឆ. $x^2=-\frac{48}{121}$

ខ. $x^2=-24$ ឃ. $x^2=-75$ ច. $x^2=-10^{-4}$ ជ. $x^2=-\frac{3}{100}$

៤. គណនា $z_1+z_2, z_1-z_2, z_1z_2$ និង $\frac{z_1}{z_2}$ សម្រាប់៖

ក. $z_1=2+5i, z_2=1-7i$

គ. $z_1=3+4i, z_2=-1+2i$

ខ. $z_1=\sqrt{2}-i\sqrt{3}, z_2=\sqrt{2}+i\sqrt{3}$

ឃ. $z_1=5-2i, z_2=2+3i$

**ចម្លើយ:**

៥. ចូរសរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ $a+bi$៖

ក. $\dfrac{13+12i}{6i-8}+\dfrac{(2i+1)^2}{2+i}$

គ. $\dfrac{1+i}{\sqrt{2}-i}+\dfrac{1-i}{\sqrt{2}+i}$

ង. $\dfrac{4-3i}{2+3i}+\dfrac{2+i}{1-i}$

ខ. $\dfrac{(i\sqrt{2}-\sqrt{3})(i\sqrt{3}-\sqrt{2})}{1-i}$

ឃ. $\dfrac{3+i}{2-i}+\dfrac{1-2i}{1+i}$

ច. $\dfrac{5-2i}{1+i}-\dfrac{3+4i}{2-i}$

**ចម្លើយ**:

៦. គណនា $i^n$ សម្រាប់ចមនួនកុំផ្លិចខាងក្រោម៖

ក. $i^5$ គ. $i^{23}$ ង. $i^{47}$ ឆ. $i^{63}$ ឈ. $i^{91}$

ខ. $i^{12}$ ឃ. $i^{34}$ ច. $i^{56}$ ជ. $i^{78}$ ញ. $i^{104}$

**ចម្លើយ:**

៧. សរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ $a+bi$។

ក. $(2+i)^3$ គ. $(3+2i)^3$ ង. $(1+3i)^3$ ឆ. $(2-i)^3$

ខ. $(1-i)^4$ ឃ. $(2-3i)^4$ ច. $(4-i)^4$ ជ. $(3-2i)^4$

**ចម្លើយ:**

៨. គេឲ្យ $x$ ជាចំនួនពិត។ កំណត់តម្លៃ $x$ ដើម្បីឲ្យ $\frac{3+i}{1+i}+\frac{x-i}{1-i}$ ជាចំនួនពិត។

ក. $\frac{2+i}{1-i}+\frac{x+3i}{1+2i}$

គ. $\frac{3+4i}{2-i}+\frac{x+2i}{1+i}$

ខ. $\frac{1-2i}{1+i}+\frac{x-i}{2-i}$

ឃ. $\frac{5-3i}{3+2i}+\frac{x-i}{2-i}$

**ចម្លើយ:**

៩. តាងសំណុំចំណុចនៃចំនួនកុំផ្លិច $-1-3i, -1+3i, 2, 4i, 2-3i$ និង $1+i$ ក្នុងប្លង់កុំផ្លិច។

**ចម្លើយ:**

១០. គេឲ្យ $z_1 = 3+2i$ និង $z_2 = 2+4i$ ក្នុងប្លង់កុំផ្លិច។ កំណត់រូបភាពនៃ៖

ក. $z_1+z_2$ គ. $2z_2$ ង. $-z_1$ ឆ. $z_1+3z_2$

ខ. $z_1-z_2$ ឃ. $z_2+2z_1$ ច. $-2z_1+z_2$ ជ. $2z_1-3z_2$

**ចម្លើយ:**

១១. កំណត់រូបភាពនៃ ចំនួនកុំផ្លិចខាងក្រោម បើ $z_1 = 2+i$ និង $z_2 = -2+i$។

ក. $z_1+z_2$ ខ. $z_1-z_2$ គ. $-2z_2$ ឃ. $3z_1+z_2$

**ចម្លើយ:**

១២. ផ្ទៀងផ្ទាត់លក្ខណៈនៃចំនួនកុំផ្លិចឆ្លាស់៖

ក. $\overline{z+w}=\overline{z}+\overline{w},\ z=2-i, w=1+3i$

ខ. $\overline{z-w}=\overline{z}-\overline{w},\ z=3+i, w=2-2i$

គ. $\overline{zw}=\overline{z}\,\overline{w},\ z=1+i, w=2-i$

ឃ. $\overline{\dfrac{z}{w}}=\dfrac{\overline{z}}{\overline{w}},\ z=3-2i, w=1+2i$

**ចម្លើយ**:

១៣. គណនា $z\cdot\bar{z}$ និង $|z|$ សម្រាប់ចំនួនកុំផ្លិចខាងក្រោម៖

ក. $z = 3 - 4i$ | គ. $z = -2 + 3i$ | ង. $z = 4 + i$

ខ. $z = 1 + 2i$ | ឃ. $z = 2 - 5i$ | ច. $z = -3 - 4i$

**ចម្លើយ:**

១៤. ដោះស្រាយសមីការដឺក្រេដែលមានមេគុណពិត៖

ក. $x^2+2x+5=0$

ខ. $x^2-4x+13=0$

គ. $2x^2+3x+4=0$

ឃ. $x^2+x+1=0$

ង. $x^2-2x+2=0$

ច. $x^2+6x+13=0$

**ចម្លើយ**:

១៥. ចូរកំណត់ $a,b$ ដើម្បីឲ្យ $(a+bi)(1+i)=2+4i$ និង $(a+bi)^2=3+4i$។

**ចម្លើយ:**

១៦. កំណត់តម្លៃ $a,b$ ដើម្បីឲ្យ $(a+bi)(2-i)=7+i$ និង $\frac{a+bi}{1+i}=2-i$។

**ចម្លើយ:**



១៧. គណនាប្រមាណវិធីចំនួនកុំផ្លិចៈ

ក. $(3+2i)+(5-4i)$

ខ. $(7-3i)-(2+5i)$

គ. $(2+i)(4-3i)$

ឃ. $(5-2i)(1+3i)$

ង. $\frac{6+4i}{2-i}$

ច. $\frac{3-5i}{1+2i}$

**ចម្លើយ:**

១៨. ចូរគោងរូបភាពវ៉ិចទ័រ $z_1+z_2$ និង $z_1-z_2$ សម្រាប់ $z_1=2+i$ និង $z_2=1+2i$។

**ចម្លើយ**:

១៩. គណនារូបភាពវិចទ័រ $2z$ សម្រាប់ $z=2+i$ និង $z=-1+3i$។

**ចម្លើយ**:

២០. តាងចំនួនកុំផ្លិច $z=1+i, -1+2i, -2-i$ ក្នុងប្លង់កុំផ្លិច។

**ចម្លើយ**:

២១. សរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ $a+bi$៖

ក. $(3+i)(2-4i)$ ខ. $\dfrac{5+2i}{2-i}$ គ. $\dfrac{3-4i}{1+3i}$

**ចម្លើយ**:

២២. ចូរសរសេរលក្ខណៈចំនួនកុំផ្លិចឆ្លាស់ $\overline{z_1+z_2}, \overline{z_1-z_2}, \overline{z_1 \cdot z_2}$ និង $\overline{\frac{z_1}{z_2}}$ សម្រាប់ $z_1 = 2-i, z_2 = 3+4i$។

**ចម្លើយ**:

២៣. ចូរកំណត់តម្លៃ $x$ សម្រាប់ $\frac{1+i}{2-i}+\frac{x-i}{1+i}$ ជាចំនួនពិត។

**ចម្លើយ:**

២៤. គណនា $z_1+z_2, z_1-z_2, z_1z_2$ និង $\frac{z_1}{z_2}$ បើ

ក. $z_1=2+5i, z_2=1-7i$

ខ. $z_1=\sqrt{2}-i\sqrt{3}, z_2=\sqrt{2}+i\sqrt{3}$

**ចម្លើយ:**

២៥. ចូរសរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ពីជគណិត $a+bi$

ក. $\dfrac{13+12i}{6i-8}+\dfrac{(2i+1)^2}{2+i}$

ខ. $\dfrac{(i\sqrt{2}-\sqrt{3})(i\sqrt{3}-\sqrt{2})}{1-i}$

គ. $\dfrac{1+i}{\sqrt{2}-i}+\dfrac{1-i}{\sqrt{2}+i}$

**ចម្លើយ**:

២៦. គណនា $(1+2i)^3$ និង $(3i-4)^4$។

**ចម្លើយ:**

២៧. គេឲ្យ $x$ ជាចំនួនពិត។ កំណត់តម្លៃ $x$ ដើម្បីឲ្យ $\frac{3+i}{1+i}+\frac{x-i}{1-i}$ ជាចំនួនពិត។

**ចម្លើយ:**

២៨. កំណត់រូបភាព តាងសំណុំចំណុចនៃចំនួនកុំផ្លិច $-1-3i, -1+3i, 2, 4i$ និង $2-3i$ ក្នុងប្លង់កុំផ្លិច។

**ចម្លើយ:**

២៩. គេឲ្យចំនួនកុំផ្លិច $z_1 = 3+2i$ និង $z_2 = 2+4i$ ក្នុងប្លង់កុំផ្លិច។ កំណត់រូបភាពនៃ

ក. $z_1+z_2$ ខ. $z_1-z_2$ គ. $2z_2$ ឃ. $z_2+2z_1$

**ចម្លើយ:**

៣០. កំណត់រូភាពនៃ $z_1+z_2, z_1-z_2, -2z_2$ បើ $z_1 = 2+i$ និង $z_2 = -2+i$។

**ចម្លើយ:**

៣១. គេមានចំនួនកុំផ្លិច $z_1 = 3+2i$, $z_2 = -1+3i$, $z_3 = 1-i$។ ចូរគណនាកន្សោមខាងក្រោមជាទម្រង់ពីជគណិត $a+bi$៖

ក. $z_4 = z_1 - 3z_2$ គ. $z_6 = -iz_3$ ង. $z_8 = z_2^4$

ខ. $z_5 = iz_1^2$ ឃ. $z_7 = z_1 \times z_2$ ច. $z_9 = \dfrac{z_1}{z_3}$

**ចម្លើយ:**

៣២. គេមានចំនួនកុំផ្លិច $Z_1 = 1+2i$, $Z_2 = 1$ និង $Z_3 = 2i$។ ចូរគណនាកន្សោមខាងក្រោម៖

ក. $A = 2Z_1 - 3Z_2 + Z_3$ ខ. $B = Z_1^2 - Z_2Z_3$ គ. $C = \dfrac{Z_1+Z_3}{Z_2-Z_3}$

**ចម្លើយ:**

៣៣. ដោះស្រាយសមីការ និងប្រព័ន្ធសមីការក្នុងសំណុំចំនួនកុំផ្លិច $\mathbb{C}$៖

ក. $z+(2-i)\bar{z}=3+4i$

គ. $z^2+(1-i)z+4-2i=0$

ខ. $\dfrac{z-1}{z+1}=i$

ឃ. $\begin{cases} z_1+z_2=4-2i \\ z_1\cdot z_2=5-i \end{cases}$

**ចម្លើយ**:



# មេរៀនទី ២ ចំនួនកុំផ្លិចទម្រង់ត្រីកោណមាត្រ

## ១ ម៉ូឌុលនៃចំនួនកុំផ្លិច

គេឲ្យចំនួនកុំផ្លិច $z=a+bi$ និង ចំណុច $M$ ជារូបភាពនៃ $z$ ក្នុងប្លង់ $(xoy)$។ $OM$ ហៅថាម៉ូឌុលនៃចំនួនកុំផ្លិច យើងនឹងគណនាម៉ូឌុលនេះ។ រូបភាពខាងក្រោមយើងមានត្រីកោណ $OMN$ ជាត្រីកោណកែងត្រង់ $N$។ តាមទ្រឹស្តីបទពីតាគ័រយើងបាន $OM^2=ON^2+NM^2 \Rightarrow OM^2=a^2+b^2 \iff OM=\sqrt{a^2+b^2}$។ ដូចនេះ $OM=\sqrt{a^2+b^2}$ ជាម៉ូឌុលនៃចំនួនកុំផ្លិច $z=a+bi$។




**និយមន័យ ១ : ម៉ូឌុលនៃចំនួនកុំផ្លិច**

បើ $z=a+bi; \quad a,b\in\mathbb{R}$ ជាម៉ូឌុលនៃចំនួនកុំផ្លិច $z$ កំណត់ដោយ $r=|z|=\sqrt{a^2+b^2}$។

**លំហាត់គំរូ ១**

គណនាម៉ូឌុលនៃចំនួនកុំផ្លិចខាងក្រោម៖

ក. $4-3i$ ខ. $-4-3i$ គ. $4+3i$ ឃ. $-4+3i$

**ចម្លើយ**:

**គន្លឹះដោះស្រាយ៖** ម៉ូឌុលនៃចំនួនកុំផ្លិច $z=a+bi$ តាងដោយ $|z|$ និងកំណត់ដោយរូបមន្ត $|z|=\sqrt{a^2+b^2}$។ ម៉ូឌុលជានិច្ចកាលជាចំនួនពិតវិជ្ជមាន ឬសូន្យ។

**ដំណោះស្រាយលម្អិត៖**

ក. តាង $z=4-3i$ នោះ $|z|=\sqrt{4^2+(-3)^2}=\sqrt{16+9}=\sqrt{25}=5$

ខ. តាង $z=-4-3i$ នោះ $|z|=\sqrt{(-4)^2+(-3)^2}=\sqrt{16+9}=\sqrt{25}=5$

គ. តាង $z=4+3i$ នោះ $|z|=\sqrt{4^2+3^2}=\sqrt{16+9}=\sqrt{25}=5$

ឃ. តាង $z=-4+3i$ នោះ $|z|=\sqrt{(-4)^2+3^2}=\sqrt{16+9}=\sqrt{25}=5$

**ជាទូទៅ ១**

បើគេមាន $z,z_1,z_2$ ជាបីចំនួនកុំផ្លិចនោះ យើងបានលក្ខណៈមួយចំនួនដូចខាងក្រោមផ្ទៀងផ្ទាត់ ៖

ក. $|z|=|-z|=|\bar{z}|$

ខ. $|z|^2=z\cdot\bar{z}$

គ. $|z_1\cdot z_2|=|z_1||z_2|$

ឃ. $\left|\dfrac{z_1}{z_2}\right|=\dfrac{|z_1|}{|z_2|};\quad z_2\neq 0$

ង. $|z_1+z_2|\leq|z_1|+|z_2|$

**សម្រាយបញ្ជាក់៖**

តាង $z=a+bi,\ z_1=a_1+b_1i,$ និង $z_2=a_2+b_2i$ ដែល $a,b,a_1,b_1,a_2,b_2\in\mathbb{R}$ ។

ក. $|z|=|-z|=|\bar{z}|$

តាមរូបមន្តម៉ូឌុល $|z|=\sqrt{a^2+b^2}$ នោះយើងបាន៖

ម៉ូឌុលនៃ $z$ គឺ $|z|=\sqrt{a^2+b^2}$

ចំនួនផ្ទុយ $-z=-a-bi\Rightarrow|-z|=\sqrt{(-a)^2+(-b)^2}=\sqrt{a^2+b^2}$

ចំនួនឆ្លាស់ $\bar{z}=a-bi\Rightarrow|\bar{z}|=\sqrt{a^2+(-b)^2}=\sqrt{a^2+b^2}$

ដូចនេះ $|z|=|-z|=|\bar{z}|$ ។

ខ. $|z|^2=z\cdot\bar{z}$

ផលគុណ $z\cdot\bar{z}=(a+bi)(a-bi)=a^2-(bi)^2=a^2-b^2i^2=a^2+b^2$

ម្យ៉ាងទៀត $|z|^2=(\sqrt{a^2+b^2})^2=a^2+b^2$

ដូចនេះ $|z|^2=z\cdot\bar{z}$ ។

គ. $|z_1\cdot z_2|=|z_1||z_2|$

តាមលក្ខណៈ (b) ៖ $|z_1\cdot z_2|^2=(z_1\cdot z_2)(\overline{z_1\cdot z_2})=(z_1\cdot z_2)(\bar{z}_1\cdot\bar{z}_2)=(z_1\bar{z}_1)(z_2\bar{z}_2)=|z_1|^2|z_2|^2=(|z_1||z_2|)^2$

ទាញឫសការេ (ដោយសារម៉ូឌុលវិជ្ជមាន) នោះ $|z_1\cdot z_2|=|z_1||z_2|$ ។

ឃ. $\left|\dfrac{z_1}{z_2}\right|=\dfrac{|z_1|}{|z_2|}$

ស្រដៀងនឹងចំណុច (c) ដែរ៖ $\left|\dfrac{z_1}{z_2}\right|^2=\left(\dfrac{z_1}{z_2}\right)\overline{\left(\dfrac{z_1}{z_2}\right)}=\dfrac{z_1\cdot\bar{z}_1}{z_2\cdot\bar{z}_2}=\dfrac{|z_1|^2}{|z_2|^2}=\left(\dfrac{|z_1|}{|z_2|}\right)^2$

ទាញឫសការេ នោះ $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}$ ។

ង. $|z_1+z_2| \le |z_1|+|z_2|$
តាមលក្ខណៈ (b) ៖ $|z_1+z_2|^2 = (z_1+z_2)(\overline{z_1+z_2}) = (z_1+z_2)(\bar{z}_1+\bar{z}_2) = z_1\bar{z}_1+z_1\bar{z}_2+z_2\bar{z}_1+z_2\bar{z}_2$
$= |z_1|^2+|z_2|^2+(z_1\bar{z}_2+\overline{z_1\bar{z}_2}) = |z_1|^2+|z_2|^2+2\Re(z_1\bar{z}_2)$
ដោយ $\Re(w) \le |w|$ នាំឱ្យ $2\Re(z_1\bar{z}_2) \le 2|z_1\bar{z}_2| = 2|z_1||\bar{z}_2| = 2|z_1||z_2|$
ដូចនេះ $|z_1+z_2|^2 \le |z_1|^2+|z_2|^2+2|z_1||z_2| = (|z_1|+|z_2|)^2$
ទាញឫសការេ នោះ $|z_1+z_2| \le |z_1|+|z_2|$ ។

## លំហាត់គំរូ ២

គេមាន $z=4-3i, z_1=2-i, z_2=3+2i$ ចូរផ្ទៀងផ្ទាត់ថា៖

ក. $|z| = |-z| = |\bar{z}|$

ខ. $|z|^2 = z\cdot\bar{z}$

គ. $|z_1\cdot z_2| = |z_1||z_2|$

ឃ. $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}; \quad z_2 \neq 0$

ង. $|z_1+z_2| \le |z_1|+|z_2|$

**ចម្លើយ:**

**គន្លឹះដោះស្រាយ៖** ប្រើរូបមន្តម៉ូឌុល $|a+bi| = \sqrt{a^2+b^2}$ ដើម្បីគណនាអង្គនីមួយៗ រួចប្រៀបធៀបគ្នាដើម្បីផ្ទៀងផ្ទាត់។

**ដំណោះស្រាយលម្អិត៖** គេមាន $z=4-3i, z_1=2-i, z_2=3+2i$

ក. $|z| = |-z| = |\bar{z}|$
$|z| = |4-3i| = \sqrt{16+9} = 5$
$|-z| = |-4+3i| = \sqrt{(-4)^2+3^2} = 5$
$|\bar{z}| = |4+3i| = \sqrt{4^2+3^2} = 5$
ដូចនេះ $|z| = |-z| = |\bar{z}|$ ពិត។

ខ. $|z|^2 = z\cdot\bar{z}$
$|z|^2 = 5^2 = 25$
$z\cdot\bar{z} = (4-3i)(4+3i) = 4^2+3^2 = 16+9 = 25$
ដូចនេះ $|z|^2 = z\cdot\bar{z}$ ពិត។

គ. $|z_1\cdot z_2| = |z_1|\cdot|z_2|$
$z_1\cdot z_2 = (2-i)(3+2i) = 6+4i-3i-2i^2 = 8+i \implies |z_1\cdot z_2| = \sqrt{8^2+1^2} = \sqrt{65}$
$|z_1| = \sqrt{2^2+(-1)^2} = \sqrt{5}$ និង $|z_2| = \sqrt{3^2+2^2} = \sqrt{13} \implies |z_1|\cdot|z_2| = \sqrt{5}\cdot\sqrt{13} = \sqrt{65}$
ដូចនេះ $|z_1\cdot z_2| = |z_1|\cdot|z_2|$ ពិត។

ឃ. $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}$

$$\left|\frac{z_1}{z_2}\right| = \left|\frac{2-i}{3+2i}\right| = \left|\frac{(2-i)(3-2i)}{3^2+2^2}\right| = \left|\frac{6-4i-3i+2i^2}{13}\right| = \left|\frac{4-7i}{13}\right| = \sqrt{\left(\frac{4}{13}\right)^2+\left(\frac{-7}{13}\right)^2} = \sqrt{\frac{16+49}{169}} = \frac{\sqrt{65}}{13}$$

$$\frac{|z_1|}{|z_2|} = \frac{\sqrt{5}}{\sqrt{13}} = \frac{\sqrt{5}\cdot\sqrt{13}}{13} = \frac{\sqrt{65}}{13}$$

ដូចនេះ $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}$ ពិត។

## ២ អាគុយម៉ង់នៃចំនួនកុំផ្លិច

គេមានចំនួនកុំផ្លិច $z=a+bi$ ស្ថិតនៅក្នុងប្លង់កុំផ្លិច។ តាងវ៉ិចទ័រ $\overrightarrow{OM}$ ជារូបភាពនៃ $z$ ។ មុំដែលកំណត់ដោយ $(\overrightarrow{Ox},\overrightarrow{OM})$ ហៅថាអាគុយម៉ងនៃចំនួនកុំផ្លិច $z$ តាងដោយ $arg(z)$។ បើ $\varphi$ ជាអាគុយម៉ង់មួយនៃ $z$ នោះគេបាន $arg(z)=\varphi+2k\pi,\quad k\in\mathbb{Z}$។ $N$ ជាចំណោលកែងនៃចំណុច $M$ លើអ័ក្ស $(Ox)$ ក្នុងត្រីកោណកែង $OMN$ កែងត្រង់ $N$ គេបាន $\cos\varphi=\frac{a}{r}$ និង $\sin\varphi=\frac{b}{r}$ ដែល $r=\sqrt{a^2+b^2}$ ជាម៉ូឌុលនៃ $z$។




**និយមន័យ ២ : អាគុយម៉ង់នៃចំនួនកុំផ្លិច**

បើ $z=a+bi$ ជាទម្រង់ពីជគណិតដែលមានម៉ូឌុល $r=|z|$ និង អាគុយម៉ង់ $arg(z)=\varphi+2k\pi,\quad k\in\mathbb{Z}$ នោះទម្រង់កុំផ្លិចនៃ $z$។

**របៀបកំណត់អាគុយម៉ង់ $\theta$ តាមការ៉ាដង់ (ASTC)**

ដើម្បីកំណត់អាគុយម៉ង់ $\theta$ នៃចំនួនកុំផ្លិច $z=a+bi$ $(z\neq 0)$៖

1. គណនាម៉ូឌុល $r=|z|=\sqrt{a^2+b^2}$។
2. ប្រើរូបមន្ត $\cos\theta=\frac{a}{r}$ និង $\sin\theta=\frac{b}{r}$ ដោយផ្ទៀងផ្ទាត់សញ្ញាតាមការ៉ាដង់៖
   - **ការ៉ាដង់ទី១** $(a>0,b>0)$៖ $\theta=\alpha$ ស្ថិតក្នុង $\left(0,\frac{\pi}{2}\right)$ (អនុគមន៍ទាំងអស់វិជ្ជមាន All $>0$)

- **ការ្រដង់ទី២** $(a<0,b>0)$៖ $\theta=\pi-\alpha$ ស្ថិតក្នុង $\left(\frac{\pi}{2},\pi\right)$ $(\sin>0)$
- **ការ្រដង់ទី៣** $(a<0,b<0)$៖ $\theta=-(\pi-\alpha)$ ឬ $\theta=\pi+\alpha$ $(\tan>0)$
- **ការ្រដង់ទី៤** $(a>0,b<0)$៖ $\theta=-\alpha$ ឬ $\theta=2\pi-\alpha$ $(\cos>0)$




**លំហាត់គំរូ ៣**

ចូរសរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ត្រីកោណមាត្រ៖

ក. $z_1=1+i\sqrt{3}$ ខ. $z_1=-1+i$ គ. $z_1=\sqrt{3}-i$

**ចម្លើយ**:

**គន្លឹះដោះស្រាយ៖** ដើម្បីសរសេរជាទម្រង់ត្រីកោណមាត្រ $z=r(\cos\theta+i\sin\theta)$៖ ១. រកម៉ូឌុល $r=\sqrt{a^2+b^2}$ ២. ទាញ $r$ ជាកត្តា ធ្វើឱ្យ $z=r\left(\frac{a}{r}+i\frac{b}{r}\right)$ ៣. រកមុំ $\theta$ (អាគុយម៉ង់) ដែល $\cos\theta=\frac{a}{r}$ និង $\sin\theta=\frac{b}{r}$។

**ដំណោះស្រាយលម្អិត៖**

ក. $z_1=1+i\sqrt{3}$

$$r=\sqrt{1^2+(\sqrt{3})^2}=\sqrt{1+3}=2$$

$$z_1=2\left(\frac{1}{2}+i\frac{\sqrt{3}}{2}\right)=2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)$$

ខ. $z_2=-1+i$

$$r=\sqrt{(-1)^2+1^2}=\sqrt{2}$$

$$z_2=\sqrt{2}\left(-\frac{1}{\sqrt{2}}+i\frac{1}{\sqrt{2}}\right)=\sqrt{2}\left(-\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2}\right)=\sqrt{2}\left(\cos\frac{3\pi}{4}+i\sin\frac{3\pi}{4}\right)$$

គ. $z_3=\sqrt{3}-i$

$$r=\sqrt{(\sqrt{3})^2+(-1)^2}=\sqrt{3+1}=2$$

$$z_3 = 2\left(\frac{\sqrt{3}}{2} - i\frac{1}{2}\right) = 2\left[\cos\left(-\frac{\pi}{6}\right) + i\sin\left(-\frac{\pi}{6}\right)\right]$$

**ជាទូទៅ ២**

លក្ខណៈនៃអាគុយម៉ង់ (Properties of Argument) ចំពោះចំនួនកុំផ្លិចមិនសូន្យ $z_1, z_2$ និង $n \in \mathbb{Z}$ យើងមានលក្ខណៈសំខាន់ៗដូចខាងក្រោម៖

ក. **អាគុយម៉ង់នៃផលគុណ៖** $\arg(z_1 z_2) \equiv \arg(z_1) + \arg(z_2) \pmod{2\pi}$

ខ. **អាគុយម៉ង់នៃផលចែក៖** $\arg\left(\frac{z_1}{z_2}\right) \equiv \arg(z_1) - \arg(z_2) \pmod{2\pi}$

គ. **អាគុយម៉ង់នៃស្វ័យគុណ៖** $\arg(z^n) \equiv n \cdot \arg(z) \pmod{2\pi}$

ឃ. **អាគុយម៉ង់នៃចំនួនកុំផ្លិចឆ្លាស់៖** $\arg(\bar{z}) \equiv -\arg(z) \pmod{2\pi}$

## ៣ ទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច

ចំនួនកុំផ្លិច $z = a + bi$ ជាទម្រង់ពីជគណិត យើងអាចសរសេរ $z$ ទៅជាទម្រង់មួយផ្សេងទៀត។ ដោយ $\cos\varphi = \frac{a}{r} \Rightarrow a = r\cos\varphi$ និង $\sin\varphi = \frac{b}{r} \Rightarrow b = r\sin\varphi$ បើយើងជំនួសតម្លៃ $a = r\cos\varphi$ និង $b = r\sin\varphi$ ក្នុងចំនួនកុំផ្លិច $z = a + bi$ គេបាន $z = a + bi = r\cos\varphi + ir\sin\varphi = r(\cos\varphi + i\sin\varphi)$។

**និយមន័យ ៣ : ទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច**

ចំនួនកុំផ្លិច $z = a + bi$ អាចសរសេរជាទម្រង់ត្រីកោណមាត្រ $z = r(\cos\varphi + i\sin\varphi)$។

**លំហាត់គំរូ ៤**

ចូរសរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ត្រីកោណមាត្រ៖

ក. $z_1 = 2 + 2i$  ខ. $z_2 = -\sqrt{3} + i$  គ. $z_3 = -8 - 8i$  ឃ. $z_4 = 1 - i\sqrt{3}$

**ចម្លើយ:**

១៦. គេឲ្យចំនួនកុំផ្លិច $z=(\sqrt{3}+1)+i(\sqrt{3}-1)$។

ក. រកម៉ូឌុល និងអាគុយម៉ង់នៃ $z^2$ រួចទាញរកម៉ូឌុល និងអាគុយម៉ង់នៃ $z$។

ខ. ទាញឲ្យបានតម្លៃពិតនៃ $\cos\frac{\pi}{12}$ និង $\sin\frac{\pi}{12}$។

គ. ដោះស្រាយសមីការ $(\sqrt{3}+1)\cos x+(\sqrt{3}-1)\sin x=\sqrt{2}$ ក្នុង $\mathbb{R}$។ រួចដៅចម្លើយលើរង្វង់ត្រីកោណមាត្រ។

**ចម្លើយ:**

# លំហាត់ដែលធ្លាប់ចេញ

①. (១០ពិន្ទុ) [2002]

ក. គេឲ្យ $z = 1 - i\sqrt{3}$។ ចូរសរសេរ $z$ និង $z^{2002}$ ជាទម្រង់ត្រីកោណមាត្រ។

ខ. គេឲ្យ $u = x + iy$ និង $z_1 = a + ib$ ។ ចូរគណនា $x, y$ ជាអនុគមន៍នៃ $a$ និង $b$ បើដឹងថា $u = z_1^2 + iz_1 - \frac{1}{2}$ ។

**ចម្លើយ**:

②. (១៥ពិន្ទុ) [2003] គេឲ្យចំនួនកុំផ្លិច $Z = \frac{2(-1+i\sqrt{3})}{1+i\sqrt{3}}$ ។

ក. សរសេរ $Z$ ជាទម្រង់ពីជគណិត រួចជាទម្រង់ត្រីកោណមាត្រ។

ខ. សរសេរ $Z' = 1 + i$ ជាទម្រង់ត្រីកោណមាត្រ រួចទាញរកម៉ូឌុលនិងអាគុយម៉ង់នៃចំនួនកុំផ្លិច $\frac{Z'}{Z}$ ។

**ចម្លើយ:**

៣. (១៥ពិន្ទុ) [2004]

ក. កំណត់ចំនួនពិត $x$ និង $y$ ដើម្បីឲ្យ $2xi-y=\frac{(3-2i)(1+i)}{i(1+2i)}$ ។

ខ. គេឲ្យ $Z=\cos\frac{2\pi}{9}+i\sin\frac{2\pi}{9}$ ។ សរសេរ $(1+Z)^4$ ជាទម្រង់ត្រីកោណមាត្រ។

**ចម្លើយ:**

៤. (១០ពិន្ទុ) [2005] គេមានចំនួនកុំផ្លិច $Z_1 = \frac{2\left(\cos\frac{\pi}{12}+i\sin\frac{\pi}{12}\right)^2}{1+i\sqrt{3}}$ និង $Z_2 = (1-i)x+(1-y)(1+i)$។

ក. សរសេរ $Z_1$ ជាទម្រង់ត្រីកោណមាត្រ ហើយសរសេរជាទម្រង់ពីជគណិត។

ខ. កំណត់ចំនួនពិត $x$ និង $y$ ដើម្បីឲ្យបាន $2\overline{Z}_1-(Z_2+y-1)=0$, ($\overline{Z}_1$ ជាចំនួនកុំផ្លិចឆ្លាស់នៃ $Z_1$) ។

**ចម្លើយ:**

៥. (១០ពិន្ទុ) [2006]

១. កំណត់ចំនួនពិត $a; b$ ដើម្បីឲ្យ $x_1 = 1 + i\sqrt{3}$ ជាឫសមួយនៃសមីការ $x^2 + ax + b = 0$។

២. រកឫស $x_2$ មួយទៀតនៃសមីការ។ សរសេរ $Z = \left(\frac{x_1}{x_2}\right)^2$ ជាទម្រង់ត្រីកោណមាត្រ។

**ចម្លើយ**:

៦. (១០ពិន្ទុ) [2007] គេឲ្យចំនួនកុំផ្លិច $A=\left(\sqrt{3}-1\right)+i\left(\sqrt{3}+1\right)$ និង $B=\frac{x+iy}{1+i}$ ដែល $x,y$ ជាចំនួនពិត។

ក. សរសេរ $A^2$ ជាទម្រង់ពិជគណិត ហើយជាទម្រង់ត្រីកោណមាត្រ។

ខ. សរសេរ $B$ ជាទម្រង់ពីជគណិត។ រក $x$ និង $y$ ដោយដឹងថា $2\overline{B}-A^2=0$ ( $\overline{B}$ ជាចំនួនកុំផ្លិចឆ្លាស់នៃ $B$ )។

**ចម្លើយ**:

៧. (១៥ពិន្ទុ) [2008]គេឲ្យចំនួនកុំផ្លិច $Z=x+iy$ និង $W=\cos\alpha+i\sin\alpha$ ដែល $x$ និង $y$ ជាចំនួនពិតខុសពី 0 ហើយ $\alpha$ ជាចំនួនពិត។

ក. កំណត់ទំនាក់ទំនងរវាង $x$ និង $y$ ដើម្បីឲ្យ $|Z| = |W|$ ។

ខ. ក្នុងលក្ខខណ្ឌ $|Z| = |W|$ ចូរបង្ហាញថា $\frac{1}{Z} = \overline{Z}$ ។

គ. រក $x$ និង $y$ រួចរក $\alpha$ ដើម្បីឲ្យ $Z = 1,\ W = 1$ ។

**ចម្លើយ**:

៤. (១០ពិន្ទុ) [2009] សរសេរ $A = \frac{2(1+i)^2}{1-i\sqrt{3}}$ ជាទម្រង់ត្រីកោណមាត្រ ហើយជាទម្រង់ពីជគណិត។

**ចម្លើយ**:

៩. (១៥ពិន្ទុ) [2010]

ក. ដោះស្រាយសមីការ $z^2-2\sqrt{2}z+4=0 \quad (1)$ ក្នុងសំណុំចំនួនកុំផ្លិច។
រកម៉ូឌុល និងអាគុយម៉ង់នៃឫសនីមួយៗរបស់សមីការ $(1)$ ។

ខ. សរសេរ $w=\left(\frac{\sqrt{2}+i\sqrt{2}}{\sqrt{2}-i\sqrt{2}}\right)^2$ ជាទម្រង់ត្រីកោណមាត្រ។

**ចម្លើយ**:

១០. (១០ពិន្ទុ) [2011]

ក. រកឫស $t_1$, $t_2$ នៃសមីការ $-t^2+2t-4=0$ ដោយយក $t_1$ ជាឫសដែលមាន ផ្នែកនិមិត្តអវិជ្ជមាន។

ខ. សរសេរ $Z=\frac{4t_2}{t_1^3}$ ជាទម្រង់ត្រីកោណមាត្រ។

**ចម្លើយ**:

១១. (១០ពិន្ទុ)[2012] គេឲ្យចំនួនកុំផ្លិច $x=-\frac{1}{2}-i\frac{\sqrt{3}}{2}$ និង $y=-\frac{1}{2}+i\frac{\sqrt{3}}{2}$ ។

ក. គណនា $A=x-y^2$ និង $B=x^2+x+1$ ។

ខ. សរសេរ $x$ និង $y$ ជាទម្រង់ត្រីកោណមាត្រ ហើយបង្ហាញថា $C=x^{2013}+y^{2013}$ ជាចំនួនពិត ។

**ចម្លើយ**:

១២. (១០ពិន្ទុ) [2013]គេឲ្យចំនួនកុំផ្លិច $a = 2\sqrt{3} - 2i$ និង $b = -\sqrt{2} + i\sqrt{2}$ ។

ក. សរសេរ $Z = a^2 + b^2 + 4ai + \sqrt{2}b$ ជាទម្រង់ពីជគណិត។

ខ. សរសេរ $a, b$ និង $ab$ ជាទម្រង់ត្រីកោណមាត្រ។

**ចម្លើយ**:

១៣. (១៥ពិន្ទុ) [2014][លើកទី១] គេឲ្យចំនួនកុំផ្លិច $z_1 = -1 + i\sqrt{3}$, $z_2 = -1 - i\sqrt{3}$ ។

ក. គណនា $z_1 + z_2$, $z_1 - z_2$, $z_1 z_2$ ។

ខ. សរសេរចំនួនកុំផ្លិច $z_1$ និង $z_2$ ជាទម្រង់ត្រីកោណមាត្រ។

គ. បង្ហាញថា $z_1$ និង $z_2$ ជាឫសរបស់សមីការ $z^3 - 8 = 0$ ។

**ចម្លើយ**:

១៤. (២០ពិន្ទុ) [2014][លើកទី២]

ក. គេមានចំនួនកុំផ្លិច $z_1 = \sqrt{2},\ z_2 = -i\sqrt{2},\ z_3 = +i\sqrt{2}$ ។

i. គណនា $z_1 + z_2,\ \ z_1 + z_3,\ \ (z_1 + z_2)(z_1 + z_3)$ ។

ii. កំណត់ម៉ូឌុល និងអាគុយម៉ង់នៃ $z_1 + z_2,\ \ z_1 + z_3,\ \ \left(\frac{z_1+z_3}{z_1+z_2}\right)^2$ ។

ខ. កំណត់ $i^n$ ចំពោះតម្លៃនៃចំនួនគត់រ៉ឺឡាទីប $n \geq 1$ ។ ទាញរកតម្លៃ $i^{2015} - i^{2014}$ ។

**ចម្លើយ**:

១៥. (១៥ពិន្ទុ) [2015] គេមានចំនួនកុំផ្លិច $z_1 = -1 + i\sqrt{3}$ និង $z_2 = 1 - i\sqrt{3}$ ។

ក. គណនា $z_1 + z_2,\ \ z_1 - z_2,\ \ z_1 \times z_2$ ។

ខ. សរសេរជាទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $z_1 - z_2,\ \ z_1 \times z_2$ ។

**ចម្លើយ**:

១៦. (១៥ពិន្ទុ) [2016] គេមានចំនួនកុំផ្លិច $z_1 = \sqrt{3} - i$ ; $z_2 = \left(1 - \sqrt{3}\right) + \left(1 - \sqrt{3}\right) i$ និង $z_3 = -\frac{1}{2}$ ។
គណនា $z_1 + z_2$ ,$(z_1 + z_2) \times z_3$ ។
សរសេរជាទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $Z = (z_1 + z_2) \times z_3$ ។ ទាញរកតម្លៃនៃ $Z^3$ ។
**ចម្លើយ**:

១៧. (១៥ពិន្ទុ) [2017] គេមានចំនួនកុំផ្លិច $z_1 = 1 + i\sqrt{3}$ និង $z_2 = 6\left(\cos\frac{\pi}{4} - i\sin\frac{\pi}{4}\right)$ ។

ក. សរសេរ $z_1$ ជាទម្រង់ត្រីកោណមាត្រ។

ខ. រកម៉ូឌុល និង អាគុយម៉ង់នៃ $z_1^3$ ។

គ. សរសេរផលគុណ $z_1 \times z_2$ ជាទម្រង់ពីជគណិត។

**ចម្លើយ**:

១៨. (១៥ពិន្ទុ) [2018] គេមានចំនួនកុំផ្លិច $z_1 = 3+3i\sqrt{3}$ និង $z_2 = \sqrt{3}+i$។

ក. គណនា $z_1 \times z_2$ និង $\frac{z_1}{z_2}$ ។

ខ. សរសេរ $z_1 \times z_2$ និង $\left(\frac{z_1}{z_2}\right)^2$ ជាទម្រង់ត្រីកោណមាត្រ

គ. សរសេរ $\left(\frac{z_1}{z_2}\right)^3$ ជាទម្រង់ពិជគណិត

**ចម្លើយ:**

១៩. (១៥ពិន្ទុ) [2019]

ក. ដោះស្រាយនៅក្នុងសំណុំចំនួនកុំផ្លិច $\mathbb{C}$ សមីការ $z^2-8z+64=0$។

ខ. គេមានចំនួនកុំផ្លិច $z_1=4+4i\sqrt{3}$ និង $z_2=4-4i\sqrt{3}$។ សរសេរ $(2z_1+\overline{z_2})$ ជាទម្រង់ត្រីកោណមាត្រ និង គណនា $(2z_1+\overline{z_2})^3$។ ( យើងតាង $\overline{z_2}$ ជាចំនួនកុំផ្លិចឆ្លាស់នៃ $z_2$ )។

**ចម្លើយ**:

២០. (១៥ពិន្ទុ) [2021]

ក. គេមានចំនួនកុំផ្លិច $z_1=\sqrt{2}+i\sqrt{2}$។ រក $\overline{z_1}$ ,($\overline{z_1}$ ជាចំនួនកុំផ្លិចឆ្លាស់នៃ $z_1$)

ខ. រកម៉ូឌុល និង អាគុយម៉ង់នៃចំនួនកុំផ្លិច$z_1$ ។ សរសេរ $z_1$ ជាទម្រង់ត្រីកោណមាត្រ ។

គ. បង្ហាញថា $\overline{z_1}$ ជាឫសរបស់សមីការ $z^2=2\left(z\sqrt{2}-2\right)$ ។

**ចម្លើយ**:

២១. (១៥ពិន្ទុ) [2022] គេមានចំនួនកុំផ្លិច $z_1 = i(3+2i)(2+i)^2$ ។

ក. សរសេរ $z_1$ ជាទម្រង់ពីជគណិតរួចរក $\overline{z_1}$ ចំនួនកុំផ្លិចឆ្លាស់នៃ $z_1$ ។

ខ. សរសេរ $z_2 = z_1 + 19$ ជាទម្រង់ត្រីកោណមាត្រ។ គណនា៖ $z_2^4$ និង $z_2^6$ ។

**ចម្លើយ**:

២២. (១៥ពិន្ទុ) [2023] ដោះស្រាយក្នុងសំណុំចំនួនកុំផ្លិចសមីការ $z^2+4z+16=0$។ សរសេរចម្លើយទាំងពីរតាងដោយ $z_1$ និង $z_2$ ជាទម្រង់ត្រីកោណមាត្រ។

**ចម្លើយ**:

២៣. (១៥ពិន្ទុ) [2024] នៅក្នុងសំណុំនៃចំនួនកុំផ្លិច $\mathbb{C}$។

ក. ដោះស្រាយសមីការ $2z-(1+i)\bar{z}=-1+5i$ ។ គណនា $i^{2025}$ ។

ខ. គេមាន $z_1=-4$ ; $z_2=3+i$ ។ គណនា $z_1+z_2$ រួចសរសេរ $z_1+z_2$ ជាទម្រង់ត្រីកោណមាត្រ ។

**ចម្លើយ**:

២៤. (១៥ពិន្ទុ) [2025] គេមានចំនួនកុំផ្លិច $z_1 = \sqrt{3} - i; z_2 = 2(1-i)$ និង $Z = \frac{z_1^7}{z_2^6}$។ រកម៉ូឌុល និង អាគុយម៉ង់នៃ $z_1, z_2$ និង $Z$ រួចសរសេរ $z_1, z_2$ និង $Z$ ជាទម្រង់ត្រីកោណមាត្រ។ សរសេរ $Z$ ជាទម្រង់ពីជគណិត។

**ចម្លើយ**:

២៥. (១៥ពិន្ទុ) [2026]

ក. ចូរសរសេរចំនួនកុំផ្លិច $1+i$ និង $1-i$ ជាទម្រង់ត្រីកោណមាត្រ ។

ខ. ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ យើងតាង $S_n=(1+i)^n+(1-i)^n$ ។ គណនា $S_2$ , $S_4$ , $S_6$ ។ បង្ហាញថា $\forall n\in\mathbb{N}$ គេសរសេរ $S_n$ ជាទម្រង់ត្រីកោណមាត្រ ។ តើសំណើដែលថា "$\forall n\in\mathbb{N}, S_n$ ជាចំនួនគត់" ជាសំណើពិតឬទេ? តើមាន $n\in\mathbb{N}$ ដែល $S_n=0$ ឬទេ?

**ចម្លើយ**:




## ១ វិញ្ញាសាពហុជ្រើសរើសត្រៀមប្រឡងប្រជែង

**១**. សរសេរឫសការេនៃចំនួនខាងស្ដាំនេះជាចំនួននិមិត្ត $\sqrt{-4-2\sqrt{3}}$ ។ តើមួយណាជាជម្រើសត្រឹមត្រូវ?

ក. $(\sqrt{3}+1)i$ ខ. $(\sqrt{3}-1)i$ គ. $(\sqrt{2}+1)i$ ឃ. $(2\sqrt{3}+1)i$

**២**. ក្នុងសមីការ $Z^2+6Z+13=0$ មាន៖

ក. ឫសពីរជាចំនួនពិត ខ. ឫសពីរជាចំនួនកុំផ្លិចដែលមិនមែនជាចំនួនពិត

គ. ឫសមួយជាចំនួនកុំផ្លិចនិងមួយទៀតជាចំនួនពិត ឃ. ឫសពីរចំនួនពិត

**៣**. ដោះស្រាយសមីការ $\frac{2z-1}{z+1}=z$ ក្នុងសំណុំ $\mathbb{C}$។ តើជម្រើសមួយណាត្រឹមត្រូវ?

ក. $z=\{\frac{1}{2}+i\frac{\sqrt{3}}{2},\frac{1}{2}-i\frac{\sqrt{3}}{2}\}$

ខ. $z=\{-1,\frac{1}{2}\}$

គ. $z=\{i\sqrt{3},-i\sqrt{3}\}$

ឃ. គ្មានឫស

**៤**. បើ $z=5+i$ តើ $z$ ជាឫសនៃសមីការមួយណាខាងក្រោម?

ក. $z^2-10z+26=0$ ខ. $z^2+10z+26=0$

គ. $z^2-10z-26=0$ ឃ. $-z^2+10z+26=0$

**៥**. បើ $z_1=-2+i\sqrt{5}$, $z_2=-2-i\sqrt{5}$ តើ $z_1,z_2$ ជាឫសនៃសមីការមួយណាខាងក្រោម?

ក. $-z^2+4z+9=0$ ខ. $z^2-4z+9=0$

គ. $z^2+4z-9=0$ ឃ. $z^2+4z+9=0$

**៦**. បើ $z=x+yi$ និង $3x+(3x-y)i=12+6i$ ។ កំណត់ចំនួនកុំផ្លិច $z$ ជាទម្រង់ពីជគណិត៖

ក. $4+6i$ ខ. $4-6i$ គ. $-4+6i$ ឃ. $-4-6i$

៧. គេមាន $a=\sqrt{3}-i$ និង $b=2-2\sqrt{3}i$ ។ កំណត់ចំនួនកុំផ្លិច $z=\frac{a}{b}$ ជាទម្រង់ពីជគណិត $x+yi$ ។

ក. $x=-\frac{\sqrt{3}}{4}, y=\frac{1}{4}$ ខ. $x=\frac{\sqrt{3}}{4}, y=\frac{1}{4}$
គ. $x=\frac{\sqrt{3}}{4}, y=-\frac{1}{4}$ ឃ. $x=\frac{\sqrt{3}}{2}, y=\frac{1}{2}$

៨. គេមានស្វ័យគុណ $i^n$ ( $i$ ជាឯកតានិមិត្ត ) ។ បើ $n=4k+2$ ចូរកំណត់ចម្លើយត្រឹមត្រូវដែលផ្ទៀងផ្ទាត់៖

ក. $i^n=1$ ខ. $i^n=i$ គ. $i^n=-1$ ឃ. $i^n=-i$

៩. គណនា $A=\left(\frac{7-15i}{15+7i}\right)^{2025}$ ។

ក. $A=-i^{2025}$ ខ. $A=-i$ គ. $A=1$ ឃ. $A=-1$

១០. គណនា $z=\left(\frac{-1+i\sqrt{3}}{\sqrt{3}+i}\right)^{100}$ ។

ក. $z=-i$ ខ. $z=i$ គ. $z=-1$ ឃ. $z=1$

១១. សរសេរ $z=\frac{1+i}{1-i}$ ជារាង $a+bi$ ។

ក. $z=1$ ខ. $z=i$ គ. $z=-i$ ឃ. $z=-1$

១២. គណនា $i+i^2+i^3+\ldots+i^{1000}$ ។

ក. $-i$ ខ. $-1$ គ. $0$ ឃ. $1$

១៣. បើ $x=1+i\sqrt{3}, y=-1-i\sqrt{3}$ ។ គណនា $x+\bar{y}$ ។

ក. $-2i\sqrt{3}$ ខ. $0$ គ. $2$ ឃ. $2i\sqrt{3}$

១៤. បើ $2-i$ ជាឫសនៃសមីការ $z^2-az-b=0$ ។ គណនាតម្លៃនៃ $a,b$ ។

ក. $a=-4, b=-5$ ខ. $a=4, b=5$
គ. $a=4, b=-5$ ឃ. $a=-4, b=5$

១៥. គេឲ្យចំនួនកុំផ្លិច $z=-1+i\sqrt{3}$ នោះផលគុណ $z\cdot\bar{z}$ កំណត់ដោយ៖

ក. $-1^2+\sqrt{3}^2$ ខ. $-2$ គ. $1^2+\sqrt{3}^2$ ឃ. $(-1)^2+\sqrt{3}^2 i$

១៦. គេមានចំនួនកុំផ្លិច $z$ ដែលផ្ទៀងផ្ទាត់ $|z|\bar{z}=15-20i$ ។ ចូរគណនា $|z|$ ។

ក. $5\sqrt{2}$ ខ. $2\sqrt{5}$ គ. $3\sqrt{5}$ ឃ. គ្មានចម្លើយ

១៧. ផលចែកចំនួនកុំផ្លិច $z=\frac{2}{-\sqrt{3}+i}$ កំណត់ដោយ៖

ក. $\frac{2}{-\sqrt{3}}+\frac{2}{i}$ ខ. $\frac{-\sqrt{3}}{2}+\frac{2}{i}$
គ. $-\frac{\sqrt{3}}{2}-\frac{1}{2}i$ ឃ. $-\sqrt{3}+i$

១៨. ផលចែកចំនួនកុំផ្លិច $z=\frac{(1-i)^2}{2-i}$ កំណត់ដោយៈ

ក. $\frac{2}{5}-\frac{4}{5}i$

ខ. $\frac{2}{5}+\frac{4}{5}i$

គ. $-\frac{2}{5}-\frac{4}{5}i$

ឃ. $\frac{2}{5}-\frac{2}{5}i$

១៩. បើ $z=x+iy$ នោះ $\left|\frac{z-1}{1-\bar{z}}\right|$ ស្មើនឹងៈ

ក. $\sqrt{x^2+y^2}$

ខ. $\frac{x+y}{x-y}$

គ. $2$

ឃ. $1$

២០. ចូររកម៉ូឌុលនិងអាគុយម៉ង់នៃ $z=\frac{1}{(1+i)^2}$ ។

ក. $r=\frac{1}{2}, \arg(z)=\frac{\pi}{2}+2k\pi$

ខ. $r=1, \arg(z)=\frac{\pi}{2}+2k\pi$

គ. $r=\frac{1}{2}, \arg(z)=\frac{\pi}{4}+2k\pi$

ឃ. $r=\frac{1}{2}, \arg(z)=-\frac{\pi}{2}+2k\pi$

២១. តើមួយណាមិនមែនជាលក្ខណៈត្រឹមត្រូវនៃម៉ូឌុលនៃចំនួនកុំផ្លិច ?

ក. $|Z|^2=Z\times\overline{Z}$

ខ. $|Z_1+Z_2|=|Z_1|+|Z_2|$

គ. $\left|\frac{Z_1}{Z_2}\right|=\frac{|Z_1|}{|Z_2|}$

ឃ. $|Z_1\times Z_2|=|Z_1|\times|Z_2|$

២២. រកតម្លៃ $x$ ដែលធ្វើឲ្យចំនួនកុំផ្លិច $z=\frac{x+i}{\sqrt{3}-i}$ ជាចំនួននិម្មិតសុទ្ធ។

ក. $x=-3$

ខ. $x=-\sqrt{3}$

គ. $x=-\frac{\sqrt{3}}{3}$

ឃ. $x=\frac{\sqrt{3}}{3}$

២៣. តម្លៃ $x$ ដែលធ្វើឲ្យចំនួនកុំផ្លិច $z=\frac{x+i}{\sqrt{3}-i}$ ជាចំនួនពិតសុទ្ធគឺៈ

ក. $x=-3$

ខ. $x=-\sqrt{3}$

គ. $x=-\frac{\sqrt{3}}{3}$

ឃ. $x=\frac{\sqrt{3}}{3}$

២៤. ម៉ូឌុលនៃចំនួនកុំផ្លិច $z=\frac{-3i-\sqrt{3}}{3}$ គឺៈ

ក. $|z|=\frac{2\sqrt{3}}{2}$

ខ. $|z|=\frac{2\sqrt{3}}{3}$

គ. $|z|=\frac{3\sqrt{3}}{2}$

ឃ. $|z|=\frac{2\sqrt{3}}{3}$

២៥. គេឱ្យ $z=(1-i)^2(1+i\sqrt{3})$ និង $\bar{z}$ តាងឱ្យចំនួនកុំផ្លិចឆ្លាស់នៃ $z$ ។ គណនា $z$ ។

ក. $z=2\sqrt{3}+2i$

ខ. $z=2\sqrt{3}-2i$

គ. $z=3\sqrt{3}+3i$

ឃ. $z=4\sqrt{3}+4i$

២៦. ចំនួនកុំផ្លិច $z$ មាន $|z|=4$ និង $\arg(z)=\frac{7\pi}{6}$ ។ នោះទម្រង់ពីជគណិតនៃ $z$ កំណត់ដោយៈ

ក. $-2-2\sqrt{3}i$

ខ. $-2\sqrt{3}-2i$

គ. $2-2\sqrt{3}i$

ឃ. $2\sqrt{3}-2i$

២៧. សរសេរ $z=-5(1+i\sqrt{3})$ ជាទម្រង់ត្រីកោណមាត្រ។ តើមួយណាជាជម្រើសត្រឹមត្រូវ?

ក. $z=10(\cos\frac{4\pi}{3}+i\sin\frac{4\pi}{3})$
ខ. $z=10(\cos\frac{3\pi}{4}+i\sin\frac{4\pi}{3})$
គ. $z=5(\cos\frac{4\pi}{3}+i\sin\frac{4\pi}{3})$
ឃ. $z=5(\cos\frac{3\pi}{4}+i\sin\frac{3\pi}{4})$

២៨. សរសេរ $z=\frac{1+\sqrt{2}+i}{1+\sqrt{2}-i}$ ជាទម្រង់ត្រីកោណមាត្រ។ តើមួយណាជម្រើសត្រឹមត្រូវ?

ក. $z=\cos\frac{\pi}{4}-i\sin\frac{\pi}{4}$
ខ. $z=\cos\frac{\pi}{4}+i\sin\frac{\pi}{4}$
គ. $z=\cos\frac{\pi}{6}+i\sin\frac{\pi}{6}$
ឃ. $z=\cos\frac{\pi}{3}+i\sin\frac{\pi}{3}$

២៩. គេមាន $z=3+3\cos\frac{4\pi}{9}-3i\sin\frac{4\pi}{9}$ ។ ម៉ូឌុលនៃចំនួនកុំផ្លិច $|z|$ កំណត់ដោយៈ

ក. $|z|=6\cos\frac{2\pi}{9}$
ខ. $|z|=2\cos\frac{\pi}{9}$
គ. $|z|=2\cos\frac{3\pi}{9}$
ឃ. $|z|=\cos\frac{2\pi}{9}$

៣០. គេមាន $z=[(1-\sqrt{3})-i(1+\sqrt{3})]^2$ ។ តើជម្រើសមួយណាជាអាគុយម៉ង់នៃចំនួនកុំផ្លិច $z$?

ក. $\frac{5\pi}{6}+2k\pi$
ខ. $-\frac{5\pi}{6}+2k\pi$
គ. $\frac{7\pi}{6}+2k\pi$
ឃ. $\frac{\pi}{6}+2k\pi$

៣១. ទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $z=-\cos\frac{\pi}{4}+i\sin\frac{\pi}{4}$ កំណត់ដោយៈ

ក. $z=\cos(-\frac{\pi}{4})+i\sin(-\frac{\pi}{4})$
ខ. $z=\cos\frac{3\pi}{4}+i\sin\frac{3\pi}{4}$
គ. $z=\cos\frac{5\pi}{4}+i\sin\frac{5\pi}{4}$
ឃ. $z=\cos\frac{7\pi}{4}+i\sin\frac{7\pi}{4}$

៣២. ទម្រង់ត្រីកោណមាត្រនៃ $z=-3(\cos\frac{\pi}{7}+i\sin\frac{\pi}{7})$ កំណត់ដោយៈ

ក. $z=3[\cos(-\frac{\pi}{7})+i\sin(-\frac{\pi}{7})]$
ខ. $z=3(\cos\frac{6\pi}{7}+i\sin\frac{6\pi}{7})$
គ. $z=3(\cos\frac{8\pi}{7}+i\sin\frac{8\pi}{7})$
ឃ. $z=3(\cos\frac{\pi}{7}+i\sin\frac{\pi}{7})$

៣៣. សរសេរជាទម្រង់ត្រីកោណមាត្រនៃ $1+\cos\frac{\pi}{7}+i\sin\frac{\pi}{7}$

ក. $2\cos\frac{\pi}{14}(\cos\frac{\pi}{14}+i\sin\frac{\pi}{14})$
ខ. $2\cos\frac{\pi}{7}(\cos\frac{\pi}{7}+i\sin\frac{\pi}{7})$
គ. $2\cos\frac{\pi}{14}(\sin\frac{\pi}{14}+i\cos\frac{\pi}{14})$
ឃ. $2(\cos\frac{\pi}{7}+i\sin\frac{\pi}{7})$

៣៤. សរសេរជាទម្រង់ត្រីកោណមាត្រនៃ $1-\cos\frac{\pi}{5}+i\sin\frac{\pi}{5}$

ក. $2\sin\frac{\pi}{10}(\cos\frac{2\pi}{5}+i\sin\frac{2\pi}{5})$
ខ. $\sin\frac{\pi}{10}(\cos\frac{\pi}{10}+i\sin\frac{\pi}{10})$
គ. $2\cos\frac{\pi}{10}(\cos\frac{\pi}{10}+i\sin\frac{\pi}{10})$
ឃ. $2\sin\frac{\pi}{10}(\sin\frac{\pi}{5}+i\cos\frac{\pi}{5})$

៣៥. បើ $Z=\sqrt{2}+\sqrt{2}i$ គណនា $\arg(Z^2)$ ។

ក. $0$
ខ. $\frac{\pi}{6}+2k\pi$
គ. $\frac{\pi}{2}+2k\pi$
ឃ. $\frac{\pi}{4}+2k\pi$

៣៦. សរសេរ $A=\frac{2(1+i)^2}{1-\sqrt{3}i}$ ជាទម្រង់ត្រីកោណមាត្រ។

ក. $2(\cos\frac{\pi}{6}+i\sin\frac{\pi}{6})$
ខ. $2(\cos(-\frac{\pi}{6})+i\sin(-\frac{\pi}{6}))$
គ. $2(\cos\frac{5\pi}{6}+i\sin\frac{5\pi}{6})$
ឃ. $4(\cos\frac{\pi}{6}+i\sin\frac{\pi}{6})$

៣៧. សរសេរកន្សោម $(\sin\frac{\pi}{6}+i\cos\frac{\pi}{6})^7$ ជាទម្រង់ពីជគណិត។

ក. $\frac{1}{2}+\frac{\sqrt{3}}{2}i$ ខ. $\frac{1}{2}-\frac{\sqrt{3}}{2}i$ គ. $-\frac{1}{2}+\frac{\sqrt{3}}{2}i$ ឃ. $-\frac{1}{2}-\frac{\sqrt{3}}{2}i$

៣៨. តើចំនួនកុំផ្លិចណាមួយខាងក្រោមដែលជាឫសទី៣នៃ 8 ។

ក. $\cos\frac{\pi}{2}+i\sin\frac{\pi}{2}$ ខ. $\cos\frac{3\pi}{2}+i\sin\frac{3\pi}{2}$ គ. $\cos\frac{2\pi}{3}+i\sin\frac{2\pi}{3}$ ឃ. $\cos\frac{3\pi}{2}+i\sin\frac{3\pi}{2}$

៣៩. គេមាន $a=\cos\alpha+i\sin\alpha$, $b=\cos\beta+i\sin\beta$, $c=\cos\gamma+i\sin\gamma$ និង $\frac{a}{b}+\frac{b}{c}+\frac{c}{a}=1$ ។ គណនា $\cos(\alpha-\beta)+\cos(\beta-\gamma)+\cos(\gamma-\alpha)$ ។

ក. $\frac{3}{2}$ ខ. $-\frac{3}{2}$ គ. $0$ ឃ. $1$

៤០. បើ $z=x-yi$ និង $z^{\frac{1}{3}}=p+qi$ ។ គណនា $\frac{\frac{x}{p}+\frac{y}{q}}{p^2+q^2}$ ។

ក. $2$ ខ. $-1$ គ. $1$ ឃ. $-2$

៤១. គេមានចំនួនកុំផ្លិច $z$ ដែលផ្ទៀងផ្ទាត់ $\arg(z+1)=\frac{\pi}{6}$ និង $\arg(z-1)=\frac{2\pi}{3}$ ។ កំណត់ចំនួនកុំផ្លិច $z$ ជាទម្រង់ $a+ib$

ក. $z=\frac{1}{2}+i\frac{\sqrt{3}}{2}$ ខ. $z=\frac{1}{2}-i\frac{\sqrt{3}}{2}$ គ. $z=1+i\sqrt{3}$ ឃ. $z=-2$

៤២. គេមានចំនួនកុំផ្លិច $z$ ដែល $|z-3+4i|=2$ ។ កំណត់សំណុំចំណុចនៃ $z$ ?

ក. រង្វង់ផ្ចិតនៅចំនុច $(-3,4)$ កាំ $r=2$ ខ. រង្វង់ផ្ចិតនៅចំនុច $(3,-4)$ កាំ $r=2$

គ. រង្វង់ផ្ចិតនៅចំនុច $(-3,4)$ កាំ $r=4$ ឃ. រង្វង់ផ្ចិតនៅចំនុច $(3,-4)$ កាំ $r=4$

៤៣. គណនាផលបូក $S=1+i^2+i^4+i^6+\ldots+i^{2n}$ ដែល $n$ ជាចំនួនគត់វិជ្ជមាន។

ក. $S=1$ ខ. $S=0$ គ. $S=n+1$ ឃ. $S=n$

៤៤. គេឱ្យចំនួនកុំផ្លិច $Z$ ដែល $|Z|=1$ ។ គណនាតម្លៃនៃកន្សោម $P=\frac{Z+1}{Z-1}$ ។

ក. $P$ ជាចំនួនពិតសុទ្ធ ខ. $P$ ជាចំនួននិមិត្តសុទ្ធ

គ. $P$ ជាចំនួនកុំផ្លិចមានផ្នែកពិតនិងផ្នែកនិមិត្តមិនសូន្យ ឃ. $P=0$

## ២ លំហាត់ស្រាវជ្រាវ និង កម្រិតខ្ពស់

១. ចូរសរសេរកន្សោមនីមួយៗខាងក្រោមជាទម្រង់ពីជគណិត $x+iy$ ៖

ក. $(9-3i)+(-4+5i)$ ខ. $(5-i)-(6-2i)$ គ. $(4-i)(3+2i)$ ឃ. $(3+2i)^3$

ង. $\frac{1+i}{\sqrt{2}-\sqrt{2}i}$ ច. $\frac{1+i}{1+3i}$ ឆ. $\frac{(1+i)(1-2i)}{2-4i}$

២. ចូរដោះស្រាយសមីការលីនេអ៊ែរខាងក្រោមក្នុងសំណុំ $\mathbb{C}$ ៖

ក. $(1+i)z=3+i$ ខ. $(3-4i)(z-1)=10-5i$

គ. $(2+i)(z-7+3i)=15-10i$ ឃ. $(3+5i)(z+2-5i)=6+3i$

៣. ចូរកំណត់តម្លៃនៃចំនួនពិត $a$ និង $b$ ដែលបំពេញសមភាពនីមួយៗខាងក្រោម៖

ក. $\frac{a}{3+i}+\frac{b}{1+2i}=1-i$ ខ. $\frac{2-3i}{2a+bi}=3+2i$ គ. $(a+bi)^2=8+6i$

៤. ចូរដោះស្រាយសមីការដឺក្រេទីពីរក្នុងសំណុំចំនួនកុំផ្លិច $\mathbb{C}$ ៖

ក. $z^2+2z+2=0$ ខ. $4z^2-4z+17=0$ គ. $z^2+6z+34=0$ ឃ. $z^2-2\sqrt{3}z+4=0$

៥. ចូរដោះស្រាយសមីការដឺក្រេទីពីរខាងក្រោមក្នុងសំណុំ $\mathbb{C}$ ៖

ក. $z^2-4iz-4=0$ ខ. $z^2+iz+6=0$

គ. $z^2+8iz-17=0$ ឃ. $z^2-(3+2i)z+5+i=0$

៦. ចូរកំណត់ឫសការេនៃចំនួនកុំផ្លិចខាងក្រោមជាទម្រង់ពីជគណិត $x+iy$ ៖

ក. $Z_1=3+4i$ ខ. $Z_2=-8-6i$ គ. $Z_3=-15+8i$ ឃ. $Z_4=5-12i$

៧. ចូរដោះស្រាយប្រព័ន្ធសមីការខាងក្រោមក្នុង $\mathbb{C}\times\mathbb{C}$ ៖

ក. $\begin{cases} z_1+z_2=3+i \\ 2z_1-iz_2=5 \end{cases}$ ខ. $\begin{cases} (1+i)z_1+z_2=2 \\ z_1-iz_2=1+i \end{cases}$

៨. ចំពោះគ្រប់ចំនួនកុំផ្លិច $z\in\mathbb{C}$ ចូរបង្ហាញថា៖

ក. $A=z^2-\bar{z}^2$ គឺជាចំនួននិម្មិតសុទ្ធ។

ខ. $B=z^n+\bar{z}^n$ គឺជាចំនួនពិតសុទ្ធ ចំពោះគ្រប់ $n\in\mathbb{N}$។

គ. $C=\frac{z-\bar{z}}{1+|z|^2}$ គឺជាចំនួននិម្មិតសុទ្ធ។

៩. គេមាន $X=(2-\sqrt{5}i)^n+(2+\sqrt{5}i)^n$ និង $Y=(2-\sqrt{5}i)^n-(2+\sqrt{5}i)^n$ ដែល $n\in\mathbb{N}$។

ក. បង្ហាញថា $X$ គឺជាចំនួនពិតសុទ្ធ។ ខ. បង្ហាញថា $Y$ គឺជាចំនួននិម្មិតសុទ្ធ។

១០. ចូរគណនាម៉ូឌុលនៃចំនួនកុំផ្លិចនីមួយៗខាងក្រោម៖

ក. $z_1=\frac{(2+i)(1-3i)}{3+4i}$ ខ. $z_2=\frac{(1+i\sqrt{3})^4}{(1-i)^6}$ គ. $z_3=1+\cos\alpha+i\sin\alpha$

១១. ចូរសរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ត្រីកោណមាត្រ $r(\cos\theta+i\sin\theta)$ ៖

ក. $4$ និង $-6$ ខ. $2i$ និង $-3i$ គ. $1+i$ និង $2-2i$ ឃ. $-\sqrt{3}+i$ និង $2\sqrt{3}+2i$

១២. សរសេរជាទម្រង់ពីជគណិតនៃចំនួនកុំផ្លិចខាងក្រោម (សម្គាល់៖ $\operatorname{cis}\alpha=\cos\alpha+i\sin\alpha$) ៖

ក. $2\operatorname{cis}\left(\frac{\pi}{2}\right)$ ខ. $8\operatorname{cis}\left(\frac{\pi}{4}\right)$ គ. $4\operatorname{cis}\left(\frac{\pi}{6}\right)$
ឃ. $\sqrt{2}\operatorname{cis}\left(-\frac{\pi}{4}\right)$ ង. $\sqrt{3}\operatorname{cis}\left(\frac{2\pi}{3}\right)$ ច. $5\operatorname{cis}\pi$

១៣. គេឱ្យ $z_1=2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)$ និង $z_2=\sqrt{2}\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)$។

ក. គណនាផលគុណ $z_1z_2$ និងផលចែក $\frac{z_1}{z_2}$ ជាទម្រង់ត្រីកោណមាត្រ។

ខ. សរសេរ $z_1,z_2$ ជាទម្រង់ពីជគណិត រួចទាញរកទម្រង់ពីជគណិតនៃ $\frac{z_1}{z_2}$។

គ. ទាញរកតម្លៃប្រាកដនៃ $\cos\frac{\pi}{12}$ និង $\sin\frac{\pi}{12}$។

១៤. ដោយប្រើទ្រឹស្តីបទដឺម័រ (De Moivre's Theorem) ចូររកចម្លើយសាមញ្ញនេះ៖

ក. $\left(\sqrt{2}\operatorname{cis}\frac{\pi}{5}\right)^{10}$ ខ. $\left(\operatorname{cis}\frac{\pi}{12}\right)^{36}$ គ. $\left(\sqrt{2}\operatorname{cis}\frac{\pi}{8}\right)^{12}$ ឃ. $\left(2\operatorname{cis}\frac{5\pi}{6}\right)^{6}$

១៥. ដោយប្រើទ្រឹស្តីបទដឺម័រ ចូរគណនាកន្សោមខាងក្រោមជាទម្រង់ពីជគណិត $x+iy$ ៖

ក. $(1+i)^{16}$ ខ. $(1-i\sqrt{3})^{11}$ គ. $(\sqrt{3}+i)^{10}$ ឃ. $\left(\frac{1+i}{\sqrt{3}-i}\right)^{12}$

១៦. ចូរសរសេរ $z=2-2\sqrt{3}i$ ជាទម្រង់ត្រីកោណមាត្រ។

ក. រកតម្លៃទាំងអស់នៃ $n\in\mathbb{N}$ ដែលធ្វើឱ្យ $z^n$ ជាចំនួនពិត។ ខ. រកតម្លៃទាំងអស់នៃ $n\in\mathbb{N}$ ដែលធ្វើឱ្យ $z^n$ ជានិម្មិតសុទ្ធ។

១៧. គេមានចំនួនកុំផ្លិច $Z=\frac{-1+i}{1+i\sqrt{3}}$។

ក. ចូរកំណត់ផ្នែកពិត និងផ្នែកនិម្មិតនៃ $Z$ ជាទម្រង់ពីជគណិត។

ខ. សរសេរ $-1+i$ និង $1+i\sqrt{3}$ ជាទម្រង់ប៉ូលែរ រួចទាញរកទម្រង់ត្រីកោណមាត្រនៃ $Z$។

គ. ទាញបង្ហាញថា $\cos\frac{5\pi}{12}=\frac{\sqrt{3}-1}{2\sqrt{2}}$ ហើយកំណត់តម្លៃប្រាកដនៃ $\sin\frac{5\pi}{12}$។

១៨. គេឱ្យចំនួនកុំផ្លិច $Z=(\sqrt{3}+1)+i(\sqrt{3}-1)$។

ក. គណនា $Z^2$ ជាទម្រង់ពីជគណិត និងជាទម្រង់ត្រីកោណមាត្រ។

ខ. ទាញរកម៉ូឌុល និងអាគុយម៉ង់ចម្បងនៃ $Z$។

គ. ទាញរកតម្លៃប្រាកដនៃ $\cos\frac{\pi}{12}$ និង $\sin\frac{\pi}{12}$។

ឃ. ដោះស្រាយសមីការលើ $\mathbb{R}$ ដែល $(\sqrt{3}+1)\cos x+(\sqrt{3}-1)\sin x=\sqrt{2}$។

១៩. គេមានចំនួនកុំផ្លិច $z=\sqrt{1+\sqrt{2}}+i\sqrt{\sqrt{2}-1}$ និង $Z=z^4$។

ក. គណនា $z^2$ រួចទាញរក $Z$ ជាទម្រង់ពីជគណិត។

ខ. សរសេរ $Z$ ជាទម្រង់ត្រីកោណមាត្រ។

គ. ទាញរកតម្លៃប្រាកដនៃ $\cos\frac{\pi}{8}$ និង $\sin\frac{\pi}{8}$។

២០. គេឱ្យចំនួនកុំផ្លិច $z_1=-1+i$, $z_2=\sqrt{6}-i\sqrt{2}$ និង $z_3=-\sqrt{6}-\sqrt{2}+i(\sqrt{6}-\sqrt{2})$។

ក. សរសេរ $z_1$ និង $z_2$ ជាទម្រង់ត្រីកោណមាត្រ។

ខ. បង្ហាញថា $z_3=z_1\overline{z_2}$ រួចទាញរកម៉ូឌុល និងអាគុយម៉ង់នៃ $z_3$។

គ. ទាញរកតម្លៃប្រាកដនៃ $\cos\left(\frac{11\pi}{12}\right)$ និង $\sin\left(\frac{11\pi}{12}\right)$។

ឃ. គណនា $z_3^{18}$។

២១. គេឱ្យចំនួនកុំផ្លិច $u=4\sqrt{3}+4i$។

ក. គណនាម៉ូឌុល និងអាគុយម៉ង់នៃ $u$។

ខ. រកឬសការេនៃ $u$ ជាទម្រង់ត្រីកោណមាត្រ។

គ. រកឬសការេនៃ $u$ ជាទម្រង់ពីជគណិត។

ឃ. ទាញរកតម្លៃប្រាកដនៃ $\cos\frac{\pi}{12}$ និង $\sin\frac{\pi}{12}$។

២២. ចូរកំណត់ឬសគូបទាំងអស់ក្នុងសំណុំ $\mathbb{C}$ នៃចំនួនកុំផ្លិចនីមួយៗខាងក្រោម៖

ក. $Z_1=-27$ ខ. $Z_2=8i$ គ. $Z_3=-1+i$

២៣. គេឱ្យសមីការ $z^5-1=0$ លើសំណុំ $\mathbb{C}$។

ក. រកឬសទាំង ៥ នៃសមីការជាទម្រង់ត្រីកោណមាត្រ។

ខ. តាង $\omega=\cos\frac{2\pi}{5}+i\sin\frac{2\pi}{5}$។ បង្ហាញថា $1+\omega+\omega^2+\omega^3+\omega^4=0$។

គ. ទាញបង្ហាញថា $\cos\frac{2\pi}{5}+\cos\frac{4\pi}{5}=-\frac{1}{2}$។

ឃ. គណនាតម្លៃប្រាកដនៃ $\cos\frac{2\pi}{5}$ និង $\sin\frac{2\pi}{5}$។

២៤. តាង $j=-\frac{1}{2}+i\frac{\sqrt{3}}{2}=e^{i\frac{2\pi}{3}}$ ជាឬសគូបមិនពិតនៃ 1។

ក. បង្ហាញថា $j^2=\overline{j}$ និង $1+j+j^2=0$។

ខ. គណនាតម្លៃនៃកន្សោម $A=(1-j+j^2)(1+j-j^2)$។

គ. ចំពោះគ្រប់ចំនួនពិត $a,b,c$ ចូរបង្ហាញថា៖ $(a+b+c)(a+bj+cj^2)(a+bj^2+cj)=a^3+b^3+c^3-3abc$។

២៥. ដោយប្រើកន្សោម $(\cos\theta+i\sin\theta)^3=\cos3\theta+i\sin3\theta$ ៖

ក. ពន្លាតកន្សោមខាងឆ្វេងតាមរូបមន្តទ្វេធាញូតុន។

ខ. ផ្ទឹមផ្នែកពិត និងផ្នែកនិម្មិតដើម្បីទាញយករូបមន្ត៖ $\sin3\theta=3\sin\theta-4\sin^3\theta$ និង $\cos3\theta=4\cos^3\theta-3\cos\theta$។

២៦. ដោយប្រើទ្រឹស្តីបទដឺម័រចំពោះ $(\cos\theta+i\sin\theta)^4$ ៖

ក. បង្ហាញថា $\cos4\theta=8\cos^4\theta-8\cos^2\theta+1$។

ខ. បង្ហាញថា $\sin4\theta=4\cos^3\theta\sin\theta-4\cos\theta\sin^3\theta$។

គ. ទាញបង្ហាញថា $\tan4\theta=\frac{4\tan\theta-4\tan^3\theta}{1-6\tan^2\theta+\tan^4\theta}$។

២៧. គេឱ្យ $z=\operatorname{cis}\theta=\cos\theta+i\sin\theta$។

ក. ចូរបង្ហាញថា $z^n+\frac{1}{z^n}=2\cos n\theta$ និង $z^n-\frac{1}{z^n}=2i\sin n\theta$។

ខ. ពន្លាតកន្សោម $\left(z+\frac{1}{z}\right)^3$ រួចទាញបង្ហាញថា៖ $\cos^3\theta=\frac{1}{4}\cos 3\theta+\frac{3}{4}\cos\theta$។

គ. ទាញរកតម្លៃប្រាកដនៃ $\cos^3\left(\frac{13\pi}{12}\right)=-\frac{5\sqrt{2}-3\sqrt{6}}{16}$។

២៨. ដោយប្រើរូបមន្តអយល័រ (Euler formulas) នៃ $\cos\theta$ និង $\sin\theta$ ៖

ក. ចូរបំប្លែង $\cos^4\theta$ ជាផលបូកកូស៊ីនុសនៃមុំគុណ។

ខ. ចូរបំប្លែង $\sin^4\theta$ ជាផលបូកកូស៊ីនុសនៃមុំគុណ។

គ. ទាញគណនាតម្លៃនៃអាំងតេក្រាល $I=\int_0^{\frac{\pi}{2}}\sin^4\theta\,d\theta$។

២៩. គេឱ្យសមីការដឺក្រេទីពីរ $z^2-6z+13=0$។

ក. ដោះស្រាយសមីការនេះក្នុងសំណុំ $\mathbb{C}$។

ខ. ទាញរក $u$ ដែល $\left(\frac{u-3i}{u+2}\right)^2-6\left(\frac{u-3i}{u+2}\right)+13=0$។

៣០. គេឱ្យសមីការ $(z+1)^4=(z-1)^4$ លើ $\mathbb{C}$។

ក. បង្ហាញថា បើ $z$ ជាឫសនៃសមីការ នោះ $\left|\frac{z+1}{z-1}\right|=1$។

ខ. ទាញបញ្ជាក់ថា ឫសទាំងអស់នៃសមីការសុទ្ធតែជានិម្មិតសុទ្ធ។

គ. រកឫសទាំងអស់នៃសមីការនេះ។

៣១. ចូរដោះស្រាយសមីការខាងក្រោមក្នុងសំណុំ $\mathbb{C}$ ៖ $\left(\frac{z+i}{z-i}\right)^3+\left(\frac{z+i}{z-i}\right)^2+\frac{z+i}{z-i}+1=0$។

៣២. គេឱ្យផលបូកត្រីកោណមាត្រពីរ៖ $S_n=1+\cos x+\cos 2x+\cdots+\cos nx$ និង $T_n=\sin x+\sin 2x+\cdots+\sin nx$ $(x\neq 2k\pi)$។

ក. គណនាផលបូក $C_n=S_n+iT_n=\sum_{k=0}^{n}e^{ikx}$ តាមរូបមន្តផលបូកស្វ៊ីតធរណីមាត្រ។

ខ. ទាញបង្ហាញថា $S_n=\dfrac{\sin\left(\frac{(n+1)x}{2}\right)\cos\left(\frac{nx}{2}\right)}{\sin\left(\frac{x}{2}\right)}$ និង $T_n=\dfrac{\sin\left(\frac{(n+1)x}{2}\right)\sin\left(\frac{nx}{2}\right)}{\sin\left(\frac{x}{2}\right)}$។

៣៣. គេឱ្យចំនួនកុំផ្លិច $A=(\sqrt{3}-1)+i(\sqrt{3}+1)$ និង $B=\frac{x+iy}{1+i}$ ដែល $x,y\in\mathbb{R}$។

ក. សរសេរ $A^2$ ជាទម្រង់ពីជគណិត ហើយជាទម្រង់ត្រីកោណមាត្រ។

ខ. សរសេរ $B$ ជាទម្រង់ពីជគណិត។ រក $x$ និង $y$ ដោយដឹងថា $2\overline{B}-A^2=0$។

៣៤. គេឱ្យចំនួនកុំផ្លិច $z=x+iy$ និង $w=\cos\alpha+i\sin\alpha$ ដែល $x,y\neq 0$ និង $\alpha\in\mathbb{R}$។

ក. កំណត់ទំនាក់ទំនងរវាង $x$ និង $y$ ដើម្បីឱ្យ $|z|=|w|$។

ខ. ក្នុងលក្ខខណ្ឌ $|z|=|w|$ ចូរបង្ហាញថា $\frac{1}{z}=\overline{z}$។

គ. រក $x$ និង $y$ រួចរក $\alpha$ ដើម្បីឱ្យ $z=1$ និង $w=1$។

៣៥. នៅក្នុងប្លង់កុំផ្លិច $(O,\vec{u},\vec{v})$ ចូរកំណត់ និងសង់សំណុំចំណុចរូបភាព $M(z)$ ក្នុងករណីនីមួយៗខាងក្រោម៖

ក. $|z-2+3i|=4$

ខ. $|z-3i|=|z+2-i|$

គ. $|z-1+2i|\leq 3$

៣៦. បើ $z = x + iy$ ហើយ $P(x,y)$ ធ្វើចលនានៅលើប្លង់កុំផ្លិច ចូរកំណត់សមីការដេកាត Cartesian នៃខ្សែកោងដែលបានមកពីសំណុំចំណុច $P$ បើ៖

ក. $\arg(z-i) = \frac{\pi}{2}$ ខ. $\left|\frac{z+2}{z-2}\right| = 2$

៣៧. គេឱ្យចំនួនកុំផ្លិច $z$ ដែលមិនសូន្យ។

ក. រកចំនួនកុំផ្លិច $z$ ដែល $z$, $1-z$ និង $\frac{1}{z}$ មានម៉ូឌុលស្មើគ្នា។

ខ. តាង $A,B,C$ ជាចំណុចរូបភាពនៃ $z, 1-z, \frac{1}{z}$ រៀងគ្នាលើប្លង់កុំផ្លិច។ ចូរបង្ហាញថា ត្រីកោណ $ABC$ គឺជាត្រីកោណសម័ង្ស។

៣៨. ចំនួនកុំផ្លិចអថេរ $z$ ត្រូវបានកំណត់ដោយ $z = 1 + \cos 2\theta + i\sin 2\theta$ ដែល $-\frac{\pi}{2} < \theta < \frac{\pi}{2}$។

ក. ចូរបង្ហាញថា ម៉ូឌុលនៃ $z$ គឺ $2\cos\theta$។ ខ. ចូរបង្ហាញថា ផ្នែកពិតនៃ $\frac{1}{z}$ គឺជាចំនួនថេរ។

៣៩. ចំនួនកុំផ្លិចអថេរ $z$ ត្រូវបានកំណត់ដោយ $z = 2\cos\theta + i(1-2\sin\theta)$ ដែល $-\pi < \theta \leq \pi$។

ក. ចូរបង្ហាញថា $|z-i| = 2$ សម្រាប់គ្រប់តម្លៃនៃ $\theta$។ ខ. ចូរបង្ហាញថា ផ្នែកពិតនៃ $\frac{1}{z+2-i}$ គឺជាចំនួនថេរ។

៤០. ក្នុងប្លង់កុំផ្លិច គេឱ្យចំណុចបី $A(z_A), B(z_B), C(z_C)$ ខុសៗគ្នា។

ក. បង្ហាញថា $A,B,C$ រត់ត្រង់ជួរគ្នា លុះត្រាតែ $\frac{z_C - z_A}{z_B - z_A}$ ជាចំនួនពិត។

ខ. បង្ហាញថា $AB \perp AC$ លុះត្រាតែ $\frac{z_C - z_A}{z_B - z_A}$ ជានិម្មិតសុទ្ធ។

គ. អនុវត្ត៖ គេឱ្យ $z_A = 1+2i$, $z_B = -2-i$, $z_C = 4+5i$។ តើចំណុច $A,B,C$ រត់ត្រង់ជួរគ្នាដែរឬទេ ?

៤១. គេឱ្យចំណុច $A(z_1), B(z_2), C(z_3)$ ជាកំពូលនៃត្រីកោណមួយក្នុងប្លង់កុំផ្លិច។

ក. បង្ហាញថាត្រីកោណ $ABC$ ជាត្រីកោណសម័ង្ស លុះត្រាតែ $\frac{z_3 - z_1}{z_2 - z_1} = e^{\pm i\frac{\pi}{3}}$។

ខ. ទាញបង្ហាញថា លក្ខខណ្ឌសមមូលគឺ៖ $z_1^2 + z_2^2 + z_3^2 = z_1z_2 + z_2z_3 + z_3z_1$។

៤២. ចំពោះចំនួនកុំផ្លិច $z \neq -1$ គេកំណត់ចំនួនកុំផ្លិច $Z = \frac{z-2i}{z+1}$។

ក. សរសេរ $Z$ ជាទម្រង់ $X + iY$ ដោយតាង $z = x + iy$ $(x, y \in \mathbb{R})$។

ខ. រកសំណុំចំណុច $M(x,y)$ នៃប្លង់កុំផ្លិចដើម្បីឱ្យ $Z$ ជាចំនួនពិតសុទ្ធ។

គ. រកសំណុំចំណុច $M(x,y)$ នៃប្លង់កុំផ្លិចដើម្បីឱ្យ $Z$ ជានិម្មិតសុទ្ធ។

៤៣. គេឱ្យពហុធា $P(z) = z^4 - 2z^3 + 3z^2 - 2z + 2$ ក្នុង $\mathbb{C}$។

ក. ផ្ទៀងផ្ទាត់ថា $z = i$ ជាឫសមួយនៃពហុធា $P(z)$។

ខ. ទាញរកឫសមួយទៀតដែលជាកុំផ្លិចឆ្លាស់នៃ $i$ រួចបំបែក $P(z)$ ជាផលគុណកត្តាដឺក្រេទីពីរពីរលើ $\mathbb{R}$។

គ. រកឫសទាំងអស់ទាំង ៤ នៃសមីការ $P(z) = 0$ ក្នុង $\mathbb{C}$។

៤៤. គេឱ្យសមីការ $(z+i)^n - (z-i)^n = 0$ លើ $\mathbb{C}$ ដែល $n \geq 2$ $(n \in \mathbb{N})$។

ក. បង្ហាញថា បើ $z$ ជាឫសនៃសមីការ នោះ $|z+i| = |z-i|$ រួចទាញបញ្ជាក់ថា $z$ ត្រូវតែជាចំនួនពិត។

ខ. ដោះស្រាយសមីការ និងបង្ហាញថាឫសទាំង $n-1$ នៃសមីការគឺ៖ $z_k = \cot\left(\frac{k\pi}{n}\right) = \frac{1}{\tan\left(\frac{k\pi}{n}\right)}$ ដែល $k = 1, 2, \ldots, n-1$។

គ. អនុវត្តចំពោះករណី $n = 5$ ៖ ទាញរកឫសទាំង ៤ ជាទម្រង់ត្រីកោណមាត្រ។

៤៥. គេឱ្យសមីការ $z^{2n+1}-1=0$ $(n\in\mathbb{N}^*)$។

ក. បង្ហាញថា ឫសនៃសមីការគឺ $z_k=e^{i\frac{2k\pi}{2n+1}}$ ដែល $k\in\{-n,\dots,-1,0,1,\dots,n\}$។

ខ. ដោយបំបែកពហុធា $z^{2n}+z^{2n-1}+\cdots+z+1$ ជាផលគុណកត្តាដឺក្រេទីពីរ ចូរបង្ហាញថា៖ $\prod_{k=1}^{n}\left|1-e^{i\frac{2k\pi}{2n+1}}\right|^2=2n+1$

គ. ទាញបញ្ជាក់រូបមន្តផលគុណត្រីកោណមាត្រដ៏ល្បី៖ $\prod_{k=1}^{n}\sin\left(\frac{k\pi}{2n+1}\right)=\frac{\sqrt{2n+1}}{2^n}$។

៤៦. ក. ស្រាយបញ្ជាក់វិសមភាពត្រីកោណ $|z_1+z_2|\le|z_1|+|z_2|$ ចំពោះគ្រប់ $z_1,z_2\in\mathbb{C}$។ តើសមភាពកើតឡើងនៅពេលណា?

ខ. ទាញបង្ហាញថា $||z_1|-|z_2||\le|z_1-z_2|$។

គ. អនុវត្ត៖ គេឱ្យចំនួនកុំផ្លិច $z$ ផ្ទៀងផ្ទាត់ $\left|z-\frac{3}{z}\right|=2$។ ចូរបង្ហាញថា $1\le|z|\le3$ រួចទាញរកតម្លៃអប្បបរមា និង អតិបរមានៃ $|z|$។

៤៧. គេឱ្យចំនួនកុំផ្លិច $u,v,w$ ដែលមានម៉ូឌុលស្មើគ្នា $|u|=|v|=|w|=1$ និងផ្ទៀងផ្ទាត់ $u+v+w=0$។

ក. បង្ហាញថា $\frac{1}{u}+\frac{1}{v}+\frac{1}{w}=0$

ខ. បង្ហាញថា $uv+vw+wu=0$

គ. ទាញបង្ហាញថា $u^2+v^2+w^2=0$ និង $u^3=v^3=w^3$

ឃ. បង្ហាញថា ចំណុចរូបភាព $u,v,w$ ជាកំពូលត្រីកោណសម័ង្ស

៤៨. ចូរដោះស្រាយប្រព័ន្ធសមីការខាងក្រោមក្នុង $\mathbb{C}^3$ ៖

$$\begin{cases}|z_1|=|z_2|=|z_3|=1\\ z_1+z_2+z_3=1\\ z_1z_2z_3=1\end{cases}$$

៤៩. គេឱ្យត្រីកោណ $ABC$ មួយក្នុងប្លង់កុំផ្លិច ដែលមានកំពូលតំណាងដោយ $z_A,z_B,z_C$ តាមទិសដៅវិជ្ជមាន។ នៅលើជ្រុង $BC,CA,AB$ គេសង់ត្រីកោណសម័ង្សក្រៅ $BCD,CAE,ABF$ ដែលមានផ្ចិតរៀងគ្នា $P,Q,R$។

ក. បង្ហាញថាកំពូល $D$ មានកូអរដោនេកុំផ្លិចផ្ទៀងផ្ទាត់ $z_D-z_B=e^{i\frac{\pi}{3}}(z_C-z_B)$។

ខ. កំណត់កូអរដោនេកុំផ្លិចនៃផ្ចិត $P,Q,R$ ជាអនុគមន៍នៃ $z_A,z_B,z_C$។

គ. បង្ហាញថា ត្រីកោណ $PQR$ គឺជាត្រីកោណសម័ង្ស (ទ្រឹស្តីបទណាប៉ូឡេអុង)។

៥០. ចំពោះគ្រប់ $n\in\mathbb{N}^*$ និង $x\in\mathbb{R}$ គេកំណត់ផលបូក៖ $C_n=\sum_{k=0}^{n}\binom{n}{k}\cos(kx)$ និង $S_n=\sum_{k=0}^{n}\binom{n}{k}\sin(kx)$។

ក. គណនា $Z_n=C_n+iS_n=\sum_{k=0}^{n}\binom{n}{k}e^{ikx}$ ដោយប្រើរូបមន្តទ្វេធាញូតុនចំពោះ $(1+e^{ix})^n$។

ខ. បង្ហាញថា $1+e^{ix}=2\cos\left(\frac{x}{2}\right)e^{i\frac{x}{2}}$។

គ. ទាញបង្ហាញរូបមន្ត៖ $C_n=2^n\cos^n\left(\frac{x}{2}\right)\cos\left(\frac{nx}{2}\right)$ និង $S_n=2^n\cos^n\left(\frac{x}{2}\right)\sin\left(\frac{nx}{2}\right)$។

ឃ. អនុវត្ត៖ គណនាតម្លៃនៃ $\sum_{k=0}^{n}\binom{n}{k}\cos\left(\frac{k\pi}{3}\right)$។




## ១ តារាងចម្លើយពហុជ្រើសរើស (Answer Keys)

### តារាងចម្លើយមេរៀនទី១ (ចំនួនកុំផ្លិច ១០០ សំណួរ)

| ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ |
|---|---|---|---|---|---|---|---|---|---|
| 1 | ខ | 21 | គ | 41 | ខ | 61 | ក | 81 | ក |
| 2 | ខ | 22 | គ | 42 | គ | 62 | ខ | 82 | ខ |
| 3 | គ | 23 | ក | 43 | ក | 63 | ខ | 83 | ក |
| 4 | ក | 24 | ខ | 44 | គ | 64 | គ | 84 | ក |
| 5 | ខ | 25 | ឃ | 45 | ខ | 65 | ខ | 85 | ឃ |
| 6 | ក | 26 | គ | 46 | ក | 66 | ខ | 86 | ខ |
| 7 | គ | 27 | ខ | 47 | ក | 67 | ខ | 87 | ក |
| 8 | ឃ | 28 | ខ | 48 | ក | 68 | ក | 88 | ខ |
| 9 | គ | 29 | ខ | 49 | ខ | 69 | ឃ | 89 | ក |
| 10 | គ | 30 | គ | 50 | ឃ | 70 | ក | 90 | ក |
| 11 | ក | 31 | ក | 51 | ខ | 71 | ខ | 91 | ក |
| 12 | គ | 32 | ខ | 52 | គ | 72 | ខ | 92 | ក |
| 13 | ខ | 33 | គ | 53 | ខ | 73 | ខ | 93 | ខ |
| 14 | ឃ | 34 | ខ | 54 | ក | 74 | ខ | 94 | ខ |
| 15 | ខ | 35 | ខ | 55 | ខ | 75 | ក | 95 | ក |
| 16 | ខ | 36 | ក | 56 | ខ | 76 | ឃ | 96 | ខ |
| 17 | ខ | 37 | ឃ | 57 | គ | 77 | ខ | 97 | ក |
| 18 | ខ | 38 | ខ | 58 | ក | 78 | ខ | 98 | ឃ |
| 19 | ខ | 39 | ខ | 59 | ខ | 79 | ក | 99 | ក |
| 20 | ខ | 40 | ខ | 60 | ខ | 80 | ខ | 100 | ក |

# តារាងចម្លើយមេរៀនទី២ (ម៉ូឌុល និង អាគុយម៉ង់)

| ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ |
|---|---|---|---|---|---|---|---|---|---|
| 1 | ខ | 21 | ខ | 41 | ខ | 61 | ខ | 81 | ក |
| 2 | គ | 22 | ខ | 42 | ក | 62 | ក | 82 | ខ |
| 3 | ខ | 23 | ខ | 43 | ក | 63 | ក | 83 | ក |
| 4 | គ | 24 | ក | 44 | ខ | 64 | ខ | 84 | ខ |
| 5 | ឃ | 25 | ខ | 45 | ខ | 65 | ក | 85 | ក |
| 6 | ខ | 26 | ខ | 46 | ខ | 66 | ខ | 86 | ខ |
| 7 | ក | 27 | គ | 47 | ខ | 67 | ក | 87 | ក |
| 8 | ខ | 28 | ខ | 48 | ក | 68 | គ | 88 | ខ |
| 9 | ខ | 29 | ខ | 49 | ក | 69 | ខ | 89 | ខ |
| 10 | ខ | 30 | គ | 50 | ខ | 70 | ខ | 90 | ខ |
| 11 | ខ | 31 | ខ | 51 | ក | 71 | ខ | 91 | ក |
| 12 | ក | 32 | ខ | 52 | គ | 72 | ក | 92 | ក |
| 13 | គ | 33 | គ | 53 | ក | 73 | ក | 93 | ខ |
| 14 | ខ | 34 | ខ | 54 | ខ | 74 | ក | 94 | ក |
| 15 | ខ | 35 | ខ | 55 | ខ | 75 | ក | 95 | ក |
| 16 | គ | 36 | ខ | 56 | ខ | 76 | ក | 96 | គ |
| 17 | ខ | 37 | ខ | 57 | ខ | 77 | គ | 97 | ក |
| 18 | គ | 38 | ខ | 58 | ក | 78 | ក | 98 | ក |
| 19 | ខ | 39 | ខ | 59 | ខ | 79 | ខ | 99 | ក |
| 20 | ខ | 40 | ខ | 60 | ក | 80 | ខ | 100 | ក |

# តារាងចម្លើយមេរៀនទី៣ (ស្វ័យគុណ និង ឫសទី $n$)

| ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ |
|---|---|---|---|---|---|---|---|---|---|
| 1 | ក | 21 | ខ | 41 | ខ | 61 | ក | 81 | ក |
| 2 | ខ | 22 | ក | 42 | ក | 62 | ក | 82 | ក |
| 3 | ខ | 23 | ខ | 43 | ក | 63 | ខ | 83 | ខ |
| 4 | ខ | 24 | គ | 44 | ខ | 64 | ខ | 84 | ក |
| 5 | ខ | 25 | ក | 45 | ក | 65 | គ | 85 | ក |
| 6 | ខ | 26 | គ | 46 | ក | 66 | ក | 86 | ខ |
| 7 | ខ | 27 | ក | 47 | ខ | 67 | ក | 87 | ក |
| 8 | ក | 28 | ក | 48 | ក | 68 | ខ | 88 | ក |
| 9 | ខ | 29 | ក | 49 | ក | 69 | ខ | 89 | ក |
| 10 | ខ | 30 | ក | 50 | ខ | 70 | ខ | 90 | ក |
| 11 | ក | 31 | ក | 51 | ខ | 71 | ក | 91 | ក |
| 12 | គ | 32 | ខ | 52 | ក | 72 | ក | 92 | ក |
| 13 | ក | 33 | គ | 53 | ខ | 73 | ក | 93 | ក |
| 14 | ខ | 34 | ខ | 54 | ឃ | 74 | ខ | 94 | ក |
| 15 | ក | 35 | ក | 55 | ខ | 75 | ក | 95 | ក |
| 16 | គ | 36 | ខ | 56 | ខ | 76 | ក | 96 | ក |
| 17 | ឃ | 37 | ក | 57 | ខ | 77 | ក | 97 | ក |
| 18 | ខ | 38 | ខ | 58 | ខ | 78 | ក | 98 | ក |
| 19 | ខ | 39 | ខ | 59 | ខ | 79 | ក | 99 | ខ |
| 20 | ខ | 40 | ក | 60 | ខ | 80 | ខ | 100 | ខ |

# តារាងចម្លើយមេរៀនទី៤ (វិញ្ញាសាត្រៀមប្រឡងប្រជែង ៤៤ សណួរ)

| ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ | ល.រ | ចម្លើយ |
|---|---|---|---|---|---|---|---|---|---|
| 1 | ក | 11 | ខ | 21 | ខ | 31 | ខ | 41 | ក |
| 2 | ខ | 12 | គ | 22 | ឃ | 32 | គ | 42 | ខ |
| 3 | ក | 13 | ឃ | 23 | ខ | 33 | ក | 43 | ក |
| 4 | ក | 14 | គ | 24 | ខ | 34 | ក | 44 | ខ |
| 5 | ឃ | 15 | គ | 25 | ខ | 35 | គ | -- | -- |
| 6 | ក | 16 | ឃ | 26 | ខ | 36 | គ | -- | -- |
| 7 | ខ | 17 | គ | 27 | ក | 37 | ក | -- | -- |
| 8 | គ | 18 | ក | 28 | ខ | 38 | គ | -- | -- |
| 9 | ខ | 19 | ឃ | 29 | ក | 39 | ឃ | -- | -- |
| 10 | ឃ | 20 | ឃ | 30 | ក | 40 | ឃ | -- | -- |

មេរៀនទី ៥ ផ្នែកចម្លើយ

# ២ ដំណោះស្រាយលម្អិត លំហាត់អនុវត្តន៍មេរៀនទី១

### លំហាត់ ១៖ បំប្លែងជាចំនួននិមិត្ត

**រូបមន្តគន្លឹះ៖** ចំពោះ $a>0$ គេបាន $\sqrt{-a}=\sqrt{a\cdot(-1)}=i\sqrt{a}$ ដែល $i^2=-1$។

ក. $\sqrt{-4}=\sqrt{4}\cdot\sqrt{-1}=2i$

ខ. $-\sqrt{-121}=-\sqrt{121}\cdot i=-11i$

គ. $\sqrt{-6}=\sqrt{6}\cdot i=i\sqrt{6}$

ឃ. $\sqrt{-12}=\sqrt{4\cdot 3}\cdot i=2i\sqrt{3}$

ង. $\sqrt{-144}=\sqrt{144}\cdot i=12i$

ច. $-\sqrt{-17}=-\sqrt{17}\cdot i=-i\sqrt{17}$

ឆ. $\sqrt{-64}=\sqrt{64}\cdot i=8i$

ជ. $\sqrt{-169}=\sqrt{169}\cdot i=13i$

### លំហាត់ ២៖ កំណត់តម្លៃ $x$ និង $y$

**ទ្រឹស្តីបទ៖** ចំនួនកុំផ្លិចពីរស្មើគ្នា $A+Bi=C+Di \iff \begin{cases}A=C\\B=D\end{cases}$ $(A,B,C,D\in\mathbb{R})$។

ក. $(1+i)x+(3-5i)y=1-3i$
$\iff x+xi+3y-5yi=1-3i$
$\iff (x+3y)+(x-5y)i=1-3i$
តាមសមភាពចំនួនកុំផ្លិច គេទាញបានប្រព័ន្ធសមីការ៖
$\begin{cases}x+3y=1 \quad (1)\\ x-5y=-3 \quad (2)\end{cases}$
យក $(1)-(2)$ គេបាន៖ $8y=4 \implies y=\frac{1}{2}$
ជំនួស $y=\frac{1}{2}$ ក្នុង $(1)$៖ $x+3\left(\frac{1}{2}\right)=1 \implies x=1-\frac{3}{2}=-\frac{1}{2}$
**ដូចនេះ** $x=-\frac{1}{2},\ y=\frac{1}{2}$

ខ. $-4-\sqrt{-8}=-x-iy$
$\iff -4-i\sqrt{8}=-x-iy \iff -4-2i\sqrt{2}=-x-iy$
$\implies \begin{cases}-x=-4\\-y=-2\sqrt{2}\end{cases} \iff \begin{cases}x=4\\y=2\sqrt{2}\end{cases}$
**ដូចនេះ** $x=4,\ y=2\sqrt{2}$

គ. $(x-1)+(y+3)i=1-3i$
$\implies \begin{cases}x-1=1 \implies x=2\\ y+3=-3 \implies y=-6\end{cases}$
**ដូចនេះ** $x=2,\ y=-6$

ឃ. $(x+iy)^2=8-6i$
ពន្លាត៖ $x^2-y^2+2xyi=8-6i$
ម្យ៉ាងទៀត យកម៉ូឌុលសងខាង៖
$|(x+iy)^2|=|8-6i| \implies x^2+y^2=\sqrt{8^2+(-6)^2}=10$
គេបានប្រព័ន្ធសមីការ៖
$\begin{cases}x^2-y^2=8 \quad (1)\\ 2xy=-6 \implies xy=-3<0 \quad (2)\\ x^2+y^2=10 \quad (3)\end{cases}$
បូក $(1)+(3)$៖ $2x^2=18 \implies x^2=9 \implies x=\pm 3$
ដក $(3)-(1)$៖ $2y^2=2 \implies y^2=1 \implies y=\pm 1$
ដោយ $xy=-3<0 \implies x,y$ មានសញ្ញាផ្ទុយគ្នា៖
**ដូចនេះ** $(x,y)\in\{(3,-1),\ (-3,1)\}$

ង. $(x+iy)^2=-5+12i$
ប្រព័ន្ធសមីការ៖
$\begin{cases}x^2-y^2=-5 \quad (1)\\ xy=6>0 \quad (2)\\ x^2+y^2=\sqrt{(-5)^2+12^2}=13 \quad (3)\end{cases}$
បូក $(1)+(3)$៖ $2x^2=8 \implies x^2=4 \implies x=\pm 2$
ដក $(3)-(1)$៖ $2y^2=18 \implies y^2=9 \implies y=\pm 3$
ដោយ $xy>0 \implies x,y$ មានសញ្ញាដូចគ្នា៖
**ដូចនេះ** $(x,y)\in\{(2,3),\ (-2,-3)\}$

ច. $(x+iy)^2=24-10i$
ប្រព័ន្ធសមីការ៖
$\begin{cases}x^2-y^2=24\\ xy=-5<0\\ x^2+y^2=\sqrt{24^2+(-10)^2}=26\end{cases}$
$\implies 2x^2=50 \implies x=\pm 5$
$\implies 2y^2=2 \implies y=\pm 1$
ដោយ $xy<0$៖
**ដូចនេះ** $(x,y)\in\{(5,-1),\ (-5,1)\}$

### លំហាត់ ៣៖ ដោះស្រាយសមីការ $x^2=-a$

**រូបមន្ត៖** ចំពោះ $a>0$ សមីការ $x^2=-a$ មានឫសកុំផ្លិចពីរគឺ $x=\pm i\sqrt{a}$។

ក. $x^2=-18 \iff x=\pm i\sqrt{18}=\pm 3i\sqrt{2}$

ខ. $x^2=-24 \iff x=\pm i\sqrt{24}=\pm 2i\sqrt{6}$

គ. $x^2=-81 \iff x=\pm i\sqrt{81}=\pm 9i$

ឃ. $x^2=-75 \iff x=\pm i\sqrt{75}=\pm 5i\sqrt{3}$

ង. $x^2=-625 \iff x=\pm i\sqrt{625}=\pm 25i$

ច. $x^2=-10^{-4} \iff x=\pm i\sqrt{10^{-4}}=\pm 10^{-2}i=\pm 0.01i$

ឆ. $x^2=-\frac{48}{121} \iff x=\pm i\frac{\sqrt{48}}{\sqrt{121}}=\pm\frac{4\sqrt{3}}{11}i$

ជ. $x^2=-\frac{3}{100} \iff x=\pm i\frac{\sqrt{3}}{\sqrt{100}}=\pm\frac{\sqrt{3}}{10}i$

### លំហាត់ ៤៖ ប្រមាណវិធីលើ $z_1,z_2$

ក. $z_1=2+5i,\ z_2=1-7i$៖

- $z_1+z_2=(2+1)+(5-7)i=3-2i$
- $z_1-z_2=(2-1)+(5-(-7))i=1+12i$

- $z_1z_2=(2+5i)(1-7i)=2-14i+5i-35i^2$
  $=2-9i+35=37-9i$
- $\frac{z_1}{z_2}=\frac{(2+5i)(1+7i)}{(1-7i)(1+7i)}=\frac{2+14i+5i+35i^2}{1^2+7^2}$
  $=\frac{2+19i-35}{50}=-\frac{33}{50}+\frac{19}{50}i$

ខ. $z_1=\sqrt{2}-i\sqrt{3},\ z_2=\sqrt{2}+i\sqrt{3}$៖

- $z_1+z_2=2\sqrt{2}$
- $z_1-z_2=-2i\sqrt{3}$
- $z_1z_2=(\sqrt{2})^2-(i\sqrt{3})^2=2-3(-1)=5$
- $\frac{z_1}{z_2}=\frac{(\sqrt{2}-i\sqrt{3})^2}{5}=\frac{2-2i\sqrt{6}-3}{5}=-\frac{1}{5}-\frac{2\sqrt{6}}{5}i$

គ. $z_1=3+4i,\ z_2=-1+2i$៖

- $z_1+z_2=2+6i$
- $z_1-z_2=4+2i$
- $z_1z_2=-3+6i-4i-8=-11+2i$
- $\frac{z_1}{z_2}=\frac{(3+4i)(-1-2i)}{(-1)^2+2^2}=\frac{-3-6i-4i+8}{5}=\frac{5-10i}{5}=1-2i$

ឃ. $z_1=5-2i,\ z_2=2+3i$៖

- $z_1+z_2=7+i$
- $z_1-z_2=3-5i$
- $z_1z_2=10+15i-4i+6=16+11i$
- $\frac{z_1}{z_2}=\frac{(5-2i)(2-3i)}{2^2+3^2}=\frac{10-15i-4i-6}{13}=\frac{4-19i}{13}=\frac{4}{13}-\frac{19}{13}i$

## លំហាត់ ៥៖ សរសេរជាទម្រង់ $a+bi$

ក. $A=\frac{13+12i}{6i-8}+\frac{(2i+1)^2}{2+i}$៖
- ភាគទី១៖ $\frac{13+12i}{-8+6i}=\frac{(13+12i)(-8-6i)}{(-8)^2+6^2}=\frac{-32-174i}{100}=-\frac{8}{25}-\frac{87}{50}i$
- ភាគទី២៖ $\frac{(1+2i)^2}{2+i}=\frac{-3+4i}{2+i}=\frac{(-3+4i)(2-i)}{2^2+1^2}=\frac{-2+11i}{5}=-\frac{4}{10}+\frac{22}{10}i=-\frac{20}{50}+\frac{110}{50}i$
- បូកបញ្ចូលគ្នា៖
$A=(-\frac{16}{50}-\frac{87}{50}i)+(-\frac{20}{50}+\frac{110}{50}i)=-\frac{36}{50}+\frac{23}{50}i=-\frac{18}{25}+\frac{23}{50}i$

ខ. $B=\frac{(i\sqrt{2}-\sqrt{3})(i\sqrt{3}-\sqrt{2})}{1-i}$៖
ភាគយក៖ $i^2\sqrt{6}-2i-3i+\sqrt{6}=-\sqrt{6}-5i+\sqrt{6}=-5i$
$\Longrightarrow B=\frac{-5i}{1-i}=\frac{-5i(1+i)}{1^2+(-1)^2}=\frac{-5i+5}{2}=\frac{5}{2}-\frac{5}{2}i$

គ. $C=\frac{1+i}{\sqrt{2}-i}+\frac{1-i}{\sqrt{2}+i}$៖
តម្រូវភាគបែងរួម៖
$C=\frac{(1+i)(\sqrt{2}+i)+(1-i)(\sqrt{2}-i)}{(\sqrt{2})^2-i^2}$
$=\frac{(\sqrt{2}-1+i(\sqrt{2}+1))+(\sqrt{2}-1-i(\sqrt{2}+1))}{2+1}=\frac{2\sqrt{2}-2}{3}$

ឃ. $D=\frac{3+i}{2-i}+\frac{1-2i}{1+i}$៖
$\frac{3+i}{2-i}=\frac{(3+i)(2+i)}{5}=\frac{5+5i}{5}=1+i$
$\frac{1-2i}{1+i}=\frac{(1-2i)(1-i)}{2}=\frac{-1-3i}{2}=-\frac{1}{2}-\frac{3}{2}i$
$\Longrightarrow D=(1+i)+(-\frac{1}{2}-\frac{3}{2}i)=\frac{1}{2}-\frac{1}{2}i$

ង. $E=\frac{4-3i}{2+3i}+\frac{2+i}{1-i}$៖
$=\frac{(4-3i)(2-3i)}{13}+\frac{(2+i)(1+i)}{2}=\frac{-1-18i}{13}+\frac{1+3i}{2}$
$=\frac{-2-36i+13+39i}{26}=\frac{11+3i}{26}=\frac{11}{26}+\frac{3}{26}i$

ច. $F=\frac{5-2i}{1+i}-\frac{3+4i}{2-i}$៖
$=\frac{(5-2i)(1-i)}{2}-\frac{(3+4i)(2+i)}{5}=\frac{3-7i}{2}-\frac{2+11i}{5}$
$=\frac{15-35i-(4+22i)}{10}=\frac{11-57i}{10}=\frac{11}{10}-\frac{57}{10}i$

## លំហាត់ ៦៖ គណនា $i^n$

**រូបមន្ត៖** $i^1=i,\ i^2=-1,\ i^3=-i,\ i^4=1$។ សម្រាប់ $n=4q+r$
នោះ៖ $i^n=(i^4)^q\cdot i^r=i^r$។

ក. $i^5=i^{4(1)+1}=i$

ខ. $i^{12}=i^{4(3)+0}=1$

គ. $i^{23}=i^{4(5)+3}=i^3=-i$

ឃ. $i^{34}=i^{4(8)+2}=i^2=-1$

ង. $i^{47}=i^{4(11)+3}=i^3=-i$

ច. $i^{56}=i^{4(14)+0}=1$

ឆ. $i^{63}=i^{4(15)+3}=i^3=-i$

ជ. $i^{78}=i^{4(19)+2}=i^2=-1$

ឈ. $i^{91}=i^{4(22)+3}=i^3=-i$

ញ. $i^{104}=i^{4(26)+0}=1$

## លំហាត់ ៧៖ ពន្លាតជាទម្រង់ $a+bi$

ក. $(2+i)^3=2^3+3(2^2)(i)+3(2)(i^2)+i^3$
$=8+12i-6-i=2+11i$

ខ. $(1-i)^4=[(1-i)^2]^2=(1-2i-1)^2=(-2i)^2=4i^2=-4$

គ. $(3+2i)^3=3^3+3(3^2)(2i)+3(3)(2i)^2+(2i)^3$
$=27+54i-36-8i=-9+46i$

ឃ. $(2-3i)^4=[(2-3i)^2]^2=(4-12i-9)^2=(-5-12i)^2$
$=25+120i-144=-119+120i$

ង. $(1+3i)^3=1+9i-27-27i=-26-18i$

ច. $(4-i)^4=[(4-i)^2]^2=(15-8i)^2=225-240i-64=161-240i$

ឆ. $(2-i)^3=8-12i-6+i=2-11i$

ជ. $(3-2i)^4=[(3-2i)^2]^2=(5-12i)^2=-119-120i$

## លំហាត់ ៨៖ កំណត់ $x$ ឲ្យកន្សោមជាចំនួនពិត

ចំនួនកុំផ្លិច $Z$ ជាចំនួនពិត $\Longleftrightarrow \operatorname{Im}(Z)=0$។
កន្សោមដើម៖ $Z=\frac{3+i}{1+i}+\frac{x-i}{1-i}=\frac{(3+i)(1-i)+(x-i)(1+i)}{2}$
$=\frac{(4-2i)+(x+1+(x-1)i)}{2}=\frac{(x+5)+(x-3)i}{2}$
ដើម្បីឲ្យ $Z\in\mathbb{R}\Longleftrightarrow x-3=0\Longleftrightarrow x=3$។

ក. $Z=\frac{2+i}{1-i}+\frac{x+3i}{1+2i}=\frac{1+3i}{2}+\frac{x+6+(3-2x)i}{5}$
$\operatorname{Im}(Z)=\frac{3}{2}+\frac{3-2x}{5}=\frac{15+6-4x}{10}=\frac{21-4x}{10}$
$Z\in\mathbb{R}\Longleftrightarrow 21-4x=0\Longleftrightarrow x=\frac{21}{4}$

ខ. $Z=\frac{1-2i}{1+i}+\frac{x-i}{2-i}=\frac{-1-3i}{2}+\frac{2x-1+(x-2)i}{5}$
$\operatorname{Im}(Z)=-\frac{3}{2}+\frac{x-2}{5}=\frac{-15+2x-4}{10}=\frac{2x-19}{10}$
$Z\in\mathbb{R}\Longleftrightarrow 2x-19=0\Longleftrightarrow x=\frac{19}{2}$

គ. $Z=\frac{3+4i}{2-i}+\frac{x+2i}{1+i}=\frac{2+11i}{5}+\frac{x+2+(2-x)i}{2}$
$\operatorname{Im}(Z)=\frac{11}{5}+\frac{2-x}{2}=\frac{22+10-5x}{10}=\frac{32-5x}{10}$
$Z\in\mathbb{R}\iff 32-5x=0\iff x=\frac{32}{5}$

ឃ. $Z=\frac{5-3i}{3+2i}+\frac{x-i}{2-i}=\frac{9-19i}{13}+\frac{2x-1+(x-2)i}{5}$
$\operatorname{Im}(Z)=-\frac{19}{13}+\frac{x-2}{5}=\frac{-95+13x-26}{65}=\frac{13x-121}{65}$
$Z\in\mathbb{R}\iff 13x-121=0\iff x=\frac{121}{13}$

## លំហាត់ ៩៖ សំណុំចំណុចក្នុងប្លង់កុំផ្លិច

ចំណុចរូបភាព $M(a,b)$ តំណាងឱ្យចំនួនកុំផ្លិច $z=a+bi$៖

- $z_1=-1-3i\implies A(-1,-3)$
- $z_2=-1+3i\implies B(-1,3)$
- $z_3=2=2+0i\implies C(2,0)$
- $z_4=4i=0+4i\implies D(0,4)$
- $z_5=2-3i\implies E(2,-3)$
- $z_6=1+i\implies F(1,1)$

## លំហាត់ ១០៖ រូបភាពវ៉ិចទ័រ

គេឱ្យ $z_1=3+2i\implies\vec{u}(3,2)$ និង $z_2=2+4i\implies\vec{v}(2,4)$។

ក. $z_1+z_2=5+6i\implies\vec{w}_1(5,6)$

ខ. $z_1-z_2=1-2i\implies\vec{w}_2(1,-2)$

គ. $2z_2=4+8i\implies\vec{w}_3(4,8)$

ឃ. $z_2+2z_1=(2+4i)+(6+4i)=8+8i\implies\vec{w}_4(8,8)$

ង. $-z_1=-3-2i\implies\vec{w}_5(-3,-2)$

ច. $-2z_1+z_2=(-6-4i)+(2+4i)=-4\implies\vec{w}_6(-4,0)$

ឆ. $z_1+3z_2=(3+2i)+(6+12i)=9+14i\implies\vec{w}_7(9,14)$

ជ. $2z_1-3z_2=(6+4i)-(6+12i)=-8i\implies\vec{w}_8(0,-8)$

## លំហាត់ ១១៖ រូបភាពវ៉ិចទ័រ $z_1,z_2$

គេឱ្យ $z_1=2+i\implies(2,1)$, $z_2=-2+i\implies(-2,1)$៖

ក. $z_1+z_2=2i\implies(0,2)$

ខ. $z_1-z_2=4\implies(4,0)$

គ. $-2z_2=4-2i\implies(4,-2)$

ឃ. $3z_1+z_2=(6+3i)+(-2+i)=4+4i\implies(4,4)$

## លំហាត់ ១២៖ ផ្ទៀងផ្ទាត់លក្ខណៈកុំផ្លិចឆ្លាស់

ក. $z=2-i,\ w=1+3i$៖
$z+w=3+2i\implies\overline{z+w}=3-2i$
$\bar z=2+i,\ \bar w=1-3i\implies\bar z+\bar w=3-2i$
**ដូចនេះ** $\overline{z+w}=\bar z+\bar w$ (ផ្ទៀងផ្ទាត់)

ខ. $z=3+i,\ w=2-2i$៖
$z-w=1+3i\implies\overline{z-w}=1-3i$
$\bar z=3-i,\ \bar w=2+2i\implies\bar z-\bar w=1-3i$
**ដូចនេះ** $\overline{z-w}=\bar z-\bar w$ (ផ្ទៀងផ្ទាត់)

គ. $z=1+i,\ w=2-i$៖
$zw=(1+i)(2-i)=3+i\implies\overline{zw}=3-i$
$\bar z\bar w=(1-i)(2+i)=3-i$
**ដូចនេះ** $\overline{zw}=\bar z\bar w$ (ផ្ទៀងផ្ទាត់)

ឃ. $z=3-2i,\ w=1+2i$៖
$\frac{z}{w}=\frac{(3-2i)(1-2i)}{5}=\frac{-1-8i}{5}\implies\overline{\left(\frac{z}{w}\right)}=-\frac{1}{5}+\frac{8}{5}i$
$\frac{\bar z}{\bar w}=\frac{3+2i}{1-2i}=\frac{(3+2i)(1+2i)}{5}=\frac{-1+8i}{5}$
**ដូចនេះ** $\overline{\left(\frac{z}{w}\right)}=\frac{\bar z}{\bar w}$ (ផ្ទៀងផ្ទាត់)

## លំហាត់ ១៣៖ គណនា $z\cdot\bar z$ និង $|z|$

**រូបមន្ត៖** ចំពោះ $z=a+bi$ គេបាន $z\cdot\bar z=a^2+b^2$ និង $|z|=\sqrt{a^2+b^2}=\sqrt{z\cdot\bar z}$។

ក. $z=3-4i\implies z\bar z=3^2+(-4)^2=25\implies|z|=5$

ខ. $z=1+2i\implies z\bar z=1^2+2^2=5\implies|z|=\sqrt5$

គ. $z=-2+3i\implies z\bar z=(-2)^2+3^2=13\implies|z|=\sqrt{13}$

ឃ. $z=2-5i\implies z\bar z=2^2+(-5)^2=29\implies|z|=\sqrt{29}$

ង. $z=4+i\implies z\bar z=4^2+1^2=17\implies|z|=\sqrt{17}$

ច. $z=-3-4i\implies z\bar z=(-3)^2+(-4)^2=25\implies|z|=5$

## លំហាត់ ១៤៖ សមីការដឺក្រេទីពីរមេគុណពិត

ក. $x^2+2x+5=0$៖
$\Delta'=1^2-5=-4=(2i)^2$
$\implies x=-1\pm2i$

ខ. $x^2-4x+13=0$៖
$\Delta'=(-2)^2-13=-9=(3i)^2$
$\implies x=2\pm3i$

គ. $2x^2+3x+4=0$៖
$\Delta=3^2-4(2)(4)=9-32=-23=(i\sqrt{23})^2$
$\implies x=\frac{-3\pm i\sqrt{23}}{4}$

ឃ. $x^2+x+1=0$៖
$\Delta=1-4=-3=(i\sqrt3)^2$
$\implies x=-\frac12\pm i\frac{\sqrt3}{2}$

ង. $x^2-2x+2=0$៖
$\Delta'=1-2=-1=i^2\implies x=1\pm i$

ច. $x^2+6x+13=0$៖
$\Delta'=9-13=-4=(2i)^2\implies x=-3\pm2i$

## លំហាត់ ១៥៖ កំណត់តម្លៃ $a$ និង $b$

- ករណី $(a+bi)(1+i)=2+4i$៖
$a+bi=\frac{2+4i}{1+i}=\frac{(2+4i)(1-i)}{2}=\frac{2-2i+4i+4}{2}=3+i$
$\implies a=3,\ b=1$

- ករណី $(a+bi)^2=3+4i$៖
$a^2-b^2=3,\ 2ab=4 \implies ab=2,\ a^2+b^2=\sqrt{3^2+4^2}=5$
$\implies 2a^2=8 \implies a=\pm 2$ និង $b=\pm 1$
**ដូចនេះ** $(a,b)=(2,1)$ ឬ $(-2,-1)$

## លំហាត់ ១៦៖ កំណត់តម្លៃ $a$ និង $b$

- ករណី $(a+bi)(2-i)=7+i$៖
$a+bi=\frac{7+i}{2-i}=\frac{(7+i)(2+i)}{5}=\frac{14+7i+2i-1}{5}=\frac{13+9i}{5}$
$\implies a=\frac{13}{5},\ b=\frac{9}{5}$
- ករណី $\frac{a+bi}{1+i}=2-i$៖
$a+bi=(2-i)(1+i)=2+2i-i+1=3+i$
$\implies a=3,\ b=1$

## លំហាត់ ១៧៖ ប្រមាណវិធីចំនួនកុំផ្លិច

ក. $(3+2i)+(5-4i)=8-2i$

ខ. $(7-3i)-(2+5i)=5-8i$

គ. $(2+i)(4-3i)=8-6i+4i+3=11-2i$

ឃ. $(5-2i)(1+3i)=5+15i-2i+6=11+13i$

ង. $\frac{6+4i}{2-i}=\frac{(6+4i)(2+i)}{5}=\frac{12+6i+8i-4}{5}=\frac{8+14i}{5}=\frac{8}{5}+\frac{14}{5}i$

ច. $\frac{3-5i}{1+2i}=\frac{(3-5i)(1-2i)}{5}=\frac{3-6i-5i-10}{5}=\frac{-7-11i}{5}=-\frac{7}{5}-\frac{11}{5}i$

## លំហាត់ ១៨៖ រូបភាពវ៉ិចទ័រ $z_1, z_2$

$z_1=2+i \implies \vec{u}(2,1),\ z_2=1+2i \implies \vec{v}(1,2)$៖

- $z_1+z_2=3+3i \implies$ តំណាងដោយវ៉ិចទ័រ $(3,3)$
- $z_1-z_2=1-i \implies$ តំណាងដោយវ៉ិចទ័រ $(1,-1)$

## លំហាត់ ១៩៖ រូបភាពវ៉ិចទ័រ $2z$

- ចំពោះ $z=2+i \implies 2z=4+2i$ តំណាងដោយ $(4,2)$
- ចំពោះ $z=-1+3i \implies 2z=-2+6i$ តំណាងដោយ $(-2,6)$

## លំហាត់ ២០៖ សំណុំចំណុចក្នុងប្លង់កុំផ្លិច

- $z_1=1+i \implies A(1,1)$
- $z_2=-1+2i \implies B(-1,2)$
- $z_3=-2-i \implies C(-2,-1)$

## លំហាត់ ២១៖ សរសេរជាទម្រង់ $a+bi$

ក. $(3+i)(2-4i)=6-12i+2i+4=10-10i$

ខ. $\frac{5+2i}{2-i}=\frac{(5+2i)(2+i)}{5}=\frac{10+5i+4i-2}{5}=\frac{8}{5}+\frac{9}{5}i$

គ. $\frac{3-4i}{1+3i}=\frac{(3-4i)(1-3i)}{10}=\frac{3-9i-4i-12}{10}=-\frac{9}{10}-\frac{13}{10}i$

## លំហាត់ ២២៖ លក្ខណៈឆ្លាស់

គេឱ្យ $z_1=2-i,\ z_2=3+4i$៖

- $z_1+z_2=5+3i \implies \overline{z_1+z_2}=5-3i$
- $z_1-z_2=-1-5i \implies \overline{z_1-z_2}=-1+5i$
- $z_1z_2=(2-i)(3+4i)=10+5i \implies \overline{z_1z_2}=10-5i$
- $\frac{z_1}{z_2}=\frac{(2-i)(3-4i)}{25}=\frac{2-11i}{25} \implies \overline{\left(\frac{z_1}{z_2}\right)}=\frac{2+11i}{25}$

## លំហាត់ ២៣៖ កំណត់ $x$ ឲ្យកន្សោមជាចំនួនពិត

$Z=\frac{1+i}{2-i}+\frac{x-i}{1+i}=\frac{1+3i}{5}+\frac{x-1-(x+1)i}{2}$
$\text{Im}(Z)=\frac{3}{5}-\frac{x+1}{2}=\frac{6-5(x+1)}{10}=\frac{1-5x}{10}$
$Z\in\mathbb{R} \iff 1-5x=0 \iff x=\frac{1}{5}$

## លំហាត់ ២៤៖ ប្រមាណវិធី $z_1, z_2$

ក. $z_1=2+5i, z_2=1-7i$៖
$z_1+z_2=3-2i,\ z_1-z_2=1+12i,\ z_1z_2=37-9i,\ \frac{z_1}{z_2}=-\frac{33}{50}+\frac{19}{50}i$

ខ. $z_1=\sqrt{2}-i\sqrt{3}, z_2=\sqrt{2}+i\sqrt{3}$៖
$z_1+z_2=2\sqrt{2},\ z_1-z_2=-2i\sqrt{3},\ z_1z_2=5,\ \frac{z_1}{z_2}=-\frac{1}{5}-\frac{2\sqrt{6}}{5}i$

## លំហាត់ ២៥៖ ទម្រង់ពីជគណិត

ក. $A=\frac{13+12i}{6i-8}+\frac{(2i+1)^2}{2+i}=-\frac{18}{25}+\frac{23}{50}i$

ខ. $B=\frac{(i\sqrt{2}-\sqrt{3})(i\sqrt{3}-\sqrt{2})}{1-i}=\frac{5}{2}-\frac{5}{2}i$

គ. $C=\frac{1+i}{\sqrt{2}-i}+\frac{1-i}{\sqrt{2}+i}=\frac{2\sqrt{2}-2}{3}$

## លំហាត់ ២៦៖ គណនាស្វ័យគុណ

- $(1+2i)^3=1+3(2i)+3(2i)^2+(2i)^3=1+6i-12-8i=-11-2i$
- $(3i-4)^4=[(-4+3i)^2]^2=(16-24i-9)^2=(7-24i)^2$
$=49-336i-576=-527-336i$

## លំហាត់ ២៧៖ កំណត់ $x$ ឲ្យជាចំនួនពិត

$Z=\frac{3+i}{1+i}+\frac{x-i}{1-i}=\frac{(x+5)+(x-3)i}{2}$
$\text{Im}(Z)=\frac{x-3}{2}=0 \iff x=3$។

## លំហាត់ ២៨៖ រូបភាពសំណុំចំណុច

$A(-1,-3),\ B(-1,3),\ C(2,0),\ D(0,4),\ E(2,-3)$។

## លំហាត់ ២៩៖ រូបភាពវ៉ិចទ័រ

$z_1=3+2i, z_2=2+4i$៖
$z_1+z_2=(5,6),\ z_1-z_2=(1,-2),\ 2z_2=(4,8),\ z_2+2z_1=(8,8)$។

## លំហាត់ ៣០៖ រូបភាព $z_1, z_2$

$z_1=2+i, z_2=-2+i$៖
$z_1+z_2=(0,2),\ z_1-z_2=(4,0),\ -2z_2=(4,-2)$។

## លំហាត់ ៣១៖ គណនាកន្សោម $z_4$ ដល់ $z_9$

គេឱ្យ $z_1=3+2i,\ z_2=-1+3i,\ z_3=1-i$៖

ក. $z_4=z_1-3z_2=(3+2i)-3(-1+3i)=6-7i$

ខ. $z_5 = iz_1^2 = i(3+2i)^2 = i(5+12i) = -12+5i$

គ. $z_6 = -iz_3 = -i(1-i) = -1-i$

ឃ. $z_7 = z_1z_2 = (3+2i)(-1+3i) = -3+9i-2i-6 = -9+7i$

ង. $z_8 = z_2^4 = [(-1+3i)^2]^2 = (-8-6i)^2 = 64+96i-36 = 28+96i$

ច. $z_9 = \frac{z_1}{z_3} = \frac{3+2i}{1-i} = \frac{(3+2i)(1+i)}{2} = \frac{1+5i}{2} = \frac{1}{2}+\frac{5}{2}i$

### លំហាត់ ៣២៖ កន្សោម និងសមីការ

គេឱ្យ $Z_1 = 1+2i,\ Z_2 = 1,\ Z_3 = 2i$៖

ក. $A = 2Z_1 - 3Z_2 + Z_3 = 2(1+2i) - 3(1) + 2i = -1+6i$

ខ. $B = Z_1^2 - Z_2Z_3 = (1+2i)^2 - (1)(2i) = (-3+4i) - 2i = -3+2i$

គ. $C = \frac{Z_1+Z_3}{Z_2-Z_3} = \frac{1+4i}{1-2i} = \frac{(1+4i)(1+2i)}{5} = \frac{-7+6i}{5} = -\frac{7}{5}+\frac{6}{5}i$

### ដោះស្រាយសមីការក្នុង $\mathbb{C}$៖

ក. $z + (2-i)\bar{z} = 3+4i$

តាង $z = x+iy$ គេបាន៖

$(x+iy)+(2-i)(x-iy) = 3+4i$

$\iff (x+iy)+(2x-2iy-ix-y) = 3+4i$

$\iff (3x-y)-(x+y)i = 3+4i$

$\implies \begin{cases} 3x-y=3 \\ -(x+y)=4 \implies x+y=-4 \end{cases}$

បូកបញ្ចូលគ្នា៖ $4x = -1 \implies x = -\frac{1}{4}$

$y = -4-x = -4+\frac{1}{4} = -\frac{15}{4}$

**ដូចនេះ** $z = -\frac{1}{4} - \frac{15}{4}i$

ខ. $\frac{z-1}{z+1} = i \iff z-1 = i(z+1) \iff z(1-i) = 1+i$

$\implies z = \frac{1+i}{1-i} = \frac{(1+i)^2}{2} = \frac{2i}{2} = i$

**ដូចនេះ** $z = i$

គ. $z^2+(1-i)z+4-2i = 0$

$\Delta = (1-i)^2 - 4(4-2i) = -2i-16+8i = -16+6i$

រកឫសការេ $\delta = u+iv$ នៃ $\Delta$៖

$u^2-v^2 = -16,\ 2uv = 6 \implies uv = 3 > 0,\ u^2+v^2 = \sqrt{256+36} = \sqrt{292} = 2\sqrt{73}$

$\implies u = \pm\sqrt{\sqrt{73}-8},\ v = \pm\sqrt{\sqrt{73}+8}$

ឫសសមីការ៖ $z = \frac{-(1-i)\pm\delta}{2}$

ឃ. $\begin{cases} z_1+z_2 = 4-2i \\ z_1z_2 = 5-i \end{cases}$

$z_1, z_2$ ជាឫសនៃសមីការ $Z^2-(4-2i)Z+(5-i) = 0$៖

$\Delta' = (2-i)^2-(5-i) = (3-4i)-(5-i) = -2-3i$

ទាញរកឫសការេ និងទាញបានគូឫស $(z_1, z_2)$។

# ៣ ដំណោះស្រាយលម្អិត លំហាត់មេរៀនទី២

### លំហាត់ ១៖ គណនាម៉ូឌុល

**រូបមន្ត៖** ចំពោះ $z=a+bi$ គេបាន $|z|=\sqrt{a^2+b^2}$។

ក. $|-2i|=\sqrt{0^2+(-2)^2}=\sqrt{4}=2$

ខ. $|\sqrt{3}+i|=\sqrt{(\sqrt{3})^2+1^2}=\sqrt{3+1}=\sqrt{4}=2$

គ. $|4+3i|+|4-3i|=\sqrt{4^2+3^2}+\sqrt{4^2+(-3)^2}=5+5=10$

ឃ. $|(4+3i)+(4-3i)|=|8|=8$

ង. $|i^7|=|(i^4)(i^3)|=|-i|=1$

ច. $|i^{100}|=|(i^4)^{25}|=|1|=1$

### លំហាត់ ២៖ ស្រាយបញ្ជាក់លក្ខណៈកុំផ្លិចឆ្លាស់

តាង $z_1=a_1+b_1i$ និង $z_2=a_2+b_2i$ ដែល $a_1,b_1,a_2,b_2\in\mathbb{R}$។

ក. $\overline{z_1+z_2}=\overline{(a_1+a_2)+(b_1+b_2)i}$
$=(a_1+a_2)-(b_1+b_2)i$
$=(a_1-b_1i)+(a_2-b_2i)=\overline{z_1}+\overline{z_2}$ (ពិត)

ខ. $z_1z_2=(a_1a_2-b_1b_2)+(a_1b_2+a_2b_1)i$
$\Longrightarrow \overline{z_1z_2}=(a_1a_2-b_1b_2)-(a_1b_2+a_2b_1)i$
ម្យ៉ាងទៀត $\overline{z_1}\cdot\overline{z_2}=(a_1-b_1i)(a_2-b_2i)$
$=a_1a_2-a_1b_2i-a_2b_1i+b_1b_2i^2$
$=(a_1a_2-b_1b_2)-(a_1b_2+a_2b_1)i=\overline{z_1z_2}$ (ពិត)

គ. $\overline{\left(\frac{z_1}{z_2}\right)}=\frac{\overline{z_1}}{\overline{z_2}}$ $(z_2\neq 0)$៖
តាង $w=\frac{z_1}{z_2}\iff z_1=wz_2$
តាមលក្ខណៈ (b)៖ $\overline{z_1}=\overline{wz_2}=\overline{w}\cdot\overline{z_2}$
ដោយ $z_2\neq 0\Longrightarrow \overline{z_2}\neq 0$ គេទាញបាន៖
$\overline{w}=\frac{\overline{z_1}}{\overline{z_2}}\iff \overline{\left(\frac{z_1}{z_2}\right)}=\frac{\overline{z_1}}{\overline{z_2}}$ (ពិត)

### លំហាត់ ៣៖ គណនាអាគុយម៉ង់

**វិធីសាស្ត្រ៖** រក $r=|z|$ រួចទាញរក $\theta$ តាម $\cos\theta=\frac{a}{r}$, $\sin\theta=\frac{b}{r}$។

